ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ស្វែងរកយុត្តិធម៌នៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

◆ ប្រវត្តិសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ ៨៣ ខែវិច្ឆិកា ឆ្នាំ២០០៦

ស្វែងរកការពិត
លេខ៨៣ ខែវិច្ឆិកា ឆ្នាំ២០០៦

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ ស្វែងរកយុត្តិធម៌នៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ....១

**ផ្នែកឯកសារ**

◆ ដា កាក់ ៖ យុទ្ធជនសួរចម្លើយនៅមន្ទីរស-២១ ....១២

◆ បញ្ជីឈ្មោះជនរងគ្រោះដែលកម្ទេចនៅមន្ទីរ ស-២១ ....១៥

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គុកខ្មែរក្រហម ....១៧

◆ ចំណាងខុក្រិដ្ឋកម្មមន្ទីរសន្តិសុខភូមិភាគនិរតី ....២៣

◆ ភៀសខ្លួនទៅប្រទេសថៃប៉ុន្តែត្រូវសម្លាប់នៅមន្ទីរស-២១ ....២៦

◆ ម៉ាន ស្មេះ ៖ អតីតទាហាន លន់ នល់ ....២៨

◆ ការចូលរួមរបស់ជនរងគ្រោះ ....៣០

**ផ្នែកច្បាប់**

◆ ឧក្រិដ្ឋកម្មដែលវិនិច្ឆ័យដោយអង្គជំនុំជម្រះវិសាមញ្ញ ....៣៧

**វេទិកាពិភាក្សាសាធារណៈ**

◆ ប្រវត្តិសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ....៤៧

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ តស៊ូដើម្បីជីវិតថ្មីលើទឹកដីចាស់ ....៥៦

◆ ពីង ហៃចាវ ....៥៨

◆ កូនប្រុសប្រាំនាក់ស្លាប់ក្នុងរបបខ្មែរក្រហម ....៥៩






បន្ទប់សម្រាប់ឃុំខ្លួនជនជាប់ចោទនៃអង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្មេរលេខនេះ ៖** ផេង ពង្សរ៉ាស៊ី, យូសុះ អាម៉ាត់, អៀ ម៉េងទ្រី, ឡុង ដានី, កែវ ដាស៊ីល, អូប្រី អាដេម៉ា, ខែលី វ៉ាយលី, លី សម្បត្តិ, ពីង ហៃចាវ, ចាប ចិន្តាភក្តី **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** លី សុផល, ណយ សុផារី, ឌី ខាំបូលី **អ្នកបកប្រែ ៖** បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ ៖** គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន គារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

សំបុត្រ :

# ស្វែងរកយុត្តិធម៌នៅតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

## ផ្លូវដ៏វែងឆ្ងាយឆ្ពោះទៅរកសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម

បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យទើបនឹងដួលរលំ ប្រជាជនជាច្រើនក្តាប់យុត្តិធម៌នៅក្នុងដៃ ហើយបញ្ចេញកំហឹងសងសឹកជាមួយកម្មាភិបាលខ្មែរក្រហមដែលនៅក្នុងភូមិស្រុកជាមួយគ្នា ។ ទន្ទឹមនឹងនោះនៅក្នុងឆ្នាំ១៩៧៩ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបើកសវនាការមួយ ដើម្បីកាត់ទោស ប៉ុល ពត នាយករដ្ឋមន្ត្រី អៀង សារី ជា ឧបនាយករដ្ឋមន្ត្រី និង ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយ




តុលាការបានកាត់ទោសប្រហារជីវិតមេដឹកនាំទាំងនេះដោយកំបាំងមុខ ពីព្រោះមេដឹកនាំទាំងនេះពុំមានវត្តមាននៅក្នុងសវនាការនោះឡើយ ។

នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ក្នុងកិច្ចខំប្រឹងប្រែងបញ្ចប់សង្គ្រាមជាមួយនឹងក្រុមខ្មាំងខ្មែរក្រហមនៅតាមតំបន់ជនបទដាច់ស្រយាលនិងនាំមកនូវស្ថិរភាពនៅក្នុងប្រទេស រាជរដ្ឋាភិបាលកម្ពុជាបានដាក់លក្ខខណ្ឌថានឹងត្រូវបានលើកលែងទោស ប្រសិនបើព្រមចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ អតីតមេដឹកនាំខ្មែរក្រហម អៀង សារី បានឯកភាពនឹងលក្ខខណ្ឌនេះ និងបន្តរស់នៅយ៉ាងសុខស្រួលនិងយ៉ាងមានសេរីភាពនៅក្នុងប្រទេសកម្ពុជា ។ ក្នុងន័យធ្វើឲ្យប្រទេសកម្ពុជាមានសន្តិភាពនិងស្ថិរភាព រាជរដ្ឋាភិបាលកម្ពុជាយល់ឃើញថាការ“ជីករណ្តៅកប់រឿងរ៉ាវអតីតកាល”ជាការចាំបាច់ណាស់ ។ ក្នុងន័យនេះ ប្រជាជនកម្ពុជាមិនទាមទារឲ្យមានការទទួលខុសត្រូវចំពោះអំពើដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។

មានមេដឹកនាំខ្មែរក្រហមបីរូបតែប៉ុណ្ណោះដែលជាប់នៅក្នុងមន្ទីរឃុំឃាំង ។ មេបញ្ជាការយោធាភូមិភាគនិរតី និងជាលេខាធិការរងនៃបក្សកុម្មុយនិស្តកម្ពុជា តាម៉ុក ត្រូវបានចាប់ដាក់គុកនៅក្នុងឆ្នាំ១៩៩៩ ពីបទប្រឆាំងមិនចុះចូលជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ។ អនុលេខាធិការរបស់ តាម៉ុក ឈ្មោះ សំ បិត ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ២០០២ ពីបទជាប់ទាក់ទិននឹងការលបវាយប្រហាររថភ្លើងដែលបណ្តាលឲ្យបាត់បង់ជីវិតជនបរទេសចំនួនបីនាក់ និងអ្នកដំណើរជនជាតិខ្មែរ១១នាក់ ។ ក្នុងចំណោមមេដឹកនាំខ្មែរក្រហមទាំងអស់ មានតែកម្មាភិបាលខ្មែរក្រហមម្នាក់

គាត់ឈ្មោះ ឌុច ដែលជាប្រធានគុកមជ្ឈិម ស-២១ ត្រូវបានឃុំខ្លួនពីបទប្រព្រឹត្តអំពើឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឌុច ត្រូវបានចាប់ខ្លួនក្នុងឆ្នាំ១៩៩៩ ។ មេដឹកនាំខ្មែរក្រហមទាំងពីររូបនេះត្រូវបានឃុំខ្លួនដោយមិនបានឆ្លងកាត់សវនាការកាត់ក្តីឡើយ ។

នៅឆ្នាំ២០០៧ខាងមុខនេះ មេដឹកនាំខ្មែរក្រហមមួយចំនួនដូចជា អៀង សារី, ខៀវ សំផន និង នួន ជា ទំនងជានឹងត្រូវអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម) ចេញដីកាចោទប្រកាន់ ។ អ្នកវិភាគជាច្រើនរូបបានព្យាករណ៍ថា ប្រធានកងពលនៃបក្សកុម្មុយនិស្តកម្ពុជា ស៊ូ ម៉េត និង មាស មុត ក៏នឹងត្រូវធ្វើការកាត់ទោសដែរ ។ ដោយឡែកនៅក្នុងឆ្នាំ១៩៩៨ ប៉ុល ពត បានស្លាប់នៅក្នុងព្រៃ ដោយមិនដឹងពីមូលហេតុពិតប្រាកដនៃការស្លាប់ ។ សមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា កែ ពក បានស្លាប់ក្នុងឆ្នាំ២០០២ ហើយ តាម៉ុក បានស្លាប់ក្នុងខែកក្កដា ឆ្នាំ២០០៦ ។

ដំណើរការក្នុងការនាំមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោស ត្រូវបានចំណាយពេលវេលាជិតមួយទសវត្សរ៍ ដោយសារតែវិបត្តិនយោបាយ ការគំរាមកំហែងនៃការបន្តធ្វើសង្គ្រាមស៊ីវិលរបស់ខ្មែរក្រហម និងការពិភាក្សាគ្នាយ៉ាងចម្រូងចម្រាសរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ ដោយហេតុនេះ ប្រជាជនកម្ពុជាជាច្រើនបានចាប់ផ្តើមបាត់អស់ក្តីសង្ឃឹមចំពោះតុលាការនេះ ។

ដំណើរការពិភាក្សាបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមជាលើកដំបូង បានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៩៧ នៅពេលដែលគណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានអនុម័តលើសេចក្តីសម្រេចលេខ១៩៩៧/៤៩ ដែលអនុញ្ញាតឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ពិនិត្យសំណើសុំជំនួយស្តីអំពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។ ក្នុងខែមិថុនា ឆ្នាំដដែលនោះដែរ នាយករដ្ឋមន្ត្រីទី១ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងនាយករដ្ឋមន្ត្រីទីពីរ សម្តេច ហ៊ុន សែន បានស្នើសុំជំនួយពីអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិ «ក្នុងការនាំជនដែលត្រូវទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» ដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមកធ្វើការកាត់ទោស ។ អង្គការសហប្រជាជាតិបានឆ្លើយតបនឹងសំណើតាមសេចក្តីសម្រេចលេខ៥២/១៣៥ ដែលស្នើសុំឲ្យលោកអគ្គលេខាធិការពិនិត្យសំណើនេះ ។

ដំណើរការពិភាក្សាដើម្បីបង្កើតសាលាក្តីនេះបានវិវត្តន៍ដោយទទួលបាននូវលទ្ធផលតិចតួចបំផុត រហូតដល់ខែវិច្ឆិកា ឆ្នាំ១៩៩៨ នៅពេលដែលអង្គការសហប្រជាជាតិបានបញ្ជូនក្រុមជំនាញការរបស់ខ្លួន រួមមានលោក នីនាន ស្ទីហ្វិន (ជនជាតិអូស្ត្រាលី ជាប្រធាន) ចៅក្រម រ៉ាជស៊ូម័រ ឡាឡា (ជនជាតិម៉ូរីទី) និងលោកសាស្ត្រាចារ្យ ស្ទីវ រ៉ាត់ន័រ (ជនជាតិអាមេរិក) ដើម្បីវាយតម្លៃនូវលទ្ធភាពក្នុងការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ។ របាយការណ៍នៅខែកុម្ភៈ ឆ្នាំ១៩៩៩ របស់អង្គការសហប្រជាជាតិ បានស្នើសុំឲ្យបង្កើតតុលាការអន្តរជាតិ និងគណៈកម្មការស្វែងរកការពិតដើម្បីវិនិច្ឆ័យទោសឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

នៅខែសីហា ឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានប្រគល់សេចក្តីព្រាងច្បាប់ស្តីអំពីការបង្កើតសាលាក្តីកាត់ទោសមេដឹកនាំ


លលាដ៍ក្បាលជនរងគ្រោះមន្ទីរគុកទួលស្លែង

ខ្មែរក្រហមជូនគណៈប្រតិភូអង្គការសហប្រជាជាតិដែលដឹកនាំដោយ ហ៊ាល ហ្សាកលីន និងអនុអគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់ លោក ហេន កូរែល ។ គណៈប្រតិភូនេះ ក៏បានប្រគល់ជូនរាជរដ្ឋាភិបាលកម្ពុជានូវសេចក្តីព្រាងច្បាប់របស់ខ្លួនដែរ ។ ក៏ប៉ុន្តែ ភាគីទាំងពីរពុំបានឈានទៅដល់កិច្ចព្រមព្រៀងមួយនៅឡើយទេ ជាដំបូង ដោយមូលហេតុថា លោក ហ្សាកលីន ទាមទារឲ្យមានចៅក្រមអន្តរជាតិច្រើនជាង តែភាគីកម្ពុជាទាមទារឲ្យមានចំនួនចៅក្រមជាតិច្រើនជាង ។

បន្ទាប់ពីមួយសប្តាហ៍នៃការចរចាដែលឈានទៅដល់កិច្ចព្រមព្រៀងរួម លោក ហ្សាកលីន បញ្ជាក់ថា "អង្គការសហប្រជាជាតិនឹងបញ្ឈប់ដំណើរការនេះ" ប្រសិនបើរដ្ឋាភិបាលកម្ពុជាមិនអនុវត្តទៅតាមលក្ខខណ្ឌដែលអង្គការសហប្រជាជាតិយល់ថាចាំបាច់សម្រាប់តុលាការ ។ នៅខែកញ្ញា ភាពតាន តឹងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិកាន់តែខ្លាំងឡើង នៅពេលដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រគល់ឯកសារជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ដោយលើកឡើងនូវជម្រើសបីសំខាន់ៗសម្រាប់ការចូលរួមរបស់អង្គការសហប្រជាជាតិក្នុងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមមាន ៖ ១) ត្រូវផ្តល់ក្រុមអ្នកជំនាញការច្បាប់ និងចូលរួមក្នុងដំណើរការកាត់សេចក្តីនៅក្នុងតុលាការកម្ពុជាដែលមានស្រាប់ ២) ត្រូវផ្តល់ក្រុមអ្នកជំនាញការច្បាប់ ដែលមិនចូលរួមដោយផ្ទាល់នៅក្នុងដំណើរការ និង៣) ត្រូវដកខ្លួនចេញពីដំណើរការជំនុំជម្រះក្តីនេះ ។

នៅខែតុលា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឯកភាពសំណើដែលដាក់ជូនដោយសមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិកចន ឃែរី ដែលស្នើសុំឲ្យមានចៅក្រមកម្ពុជាចំនួនបីរូបនិងចៅក្រមពីររូបទៀតដែលតែងតាំងដោយអង្គការសហប្រជាជាតិសម្រាប់ដំណើរការជំនុំជម្រះក្តីនេះ ។ សេចក្តីសម្រេចនេះតម្រូវឲ្យមាន "មតិភាគច្រើនលើសលប់" ដែលយ៉ាងហោចណាស់មានមតិយល់ព្រមពីចៅក្រមអន្តរជាតិយ៉ាងតិចម្នាក់ចំពោះសេចក្តីសម្រេចដែលធ្វើឡើងដោយចៅក្រមកម្ពុជា ។ ក៏ប៉ុន្តែ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាមិនបានឈានទៅដល់កិច្ចព្រមព្រៀងស្តីអំពីបញ្ហាមួយចំនួនដូចជា ការលើកលែងទោស ការពិនិត្យឡើងវិញនូវយន្តការ និងដីកាចោទប្រកាន់បណ្តោះអាសន្ន ។ ការជាប់គាំងនេះបានអូសបន្លាយរហូតដល់ខែឧសភា ឆ្នាំ២០០០ នៅពេលដែលលោក កូហ្វី អាណាន់ សុំការបញ្ជាក់បន្ថែមពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលថាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឯកភាពទទួលយករូបមន្តតុលាការចម្រុះនេះ ហើយសម្តេចក៏បានឯកភាពនឹងសំណើសុំនេះដែរ ។

ថ្ងៃទី២ ខែមករា ឆ្នាំ២០០១ គឺជាថ្ងៃជាប្រវត្តិសាស្ត្រមួយដែលរដ្ឋសភាជាតិបានអនុម័តសេចក្តីព្រាងច្បាប់ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ។ ក៏ប៉ុន្តែ សេចក្តីរីករាយចំពោះការអនុម័តសេចក្តីព្រាងនេះត្រូវរលត់បាត់អស់ទៅវិញ មួយសប្តាហ៍បន្ទាប់ពីលោក ហេន កូរែល បានស្នើសុំរាជរដ្ឋាភិបាលកម្ពុជាកែប្រែ១៨មាត្រាក្នុងចំណោម ៤៩មាត្រានៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដោយលោក ហេន កូរែល បានបញ្ជាក់ថាសេចក្តីព្រាងច្បាប់នេះនៅមានកង្វះនូវ"ខ"ក្នុងការធានានូវការត្រួតពិនិត្យយ៉ាងត្រឹមត្រូវរបស់អង្គការសហប្រជាជាតិ ។ ព្រឹទ្ធសភានិងក្រុមប្រឹក្សារដ្ឋធម្មនុញ្ញកម្ពុជានៅតែបន្តការអនុម័តសេចក្តីព្រាងច្បាប់នេះនៅថ្ងៃទី១៥ ខែមករា និងថ្ងៃទី១២ ខែកុម្ភៈ រៀងៗខ្លួន ។

ក៏ប៉ុន្តែក្រោយមកទៀត សម្តេច ហ៊ុន សែន បានធ្វើអន្តរាគមន៍ដោយប្រកាសថាសេចក្តីព្រាងច្បាប់នេះត្រូវចាប់ផ្តើមជាថ្មី ដោយសារតែភាពមិនស្របគ្នាផ្នែកបច្ចេកទេសដែលរកឃើញដោយក្រុមប្រឹក្សារដ្ឋធម្មនុញ្ញដែលបានលើកឡើងនូវកំហុសឆ្គងបច្ចេកទេសនៅក្នុងនីតិកម្មដោយអនុលោមទៅតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលចែងអំពីទោសប្រហារជីវិត ។ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើវិសោធនកម្ម សេចក្តីព្រាងច្បាប់នេះនៅក្នុងខែមិថុនា ដោយជំនួសទោសប្រហារជីវិតដោយទោសជាប់ពន្ធនាគារអស់មួយជីវិតវិញដែលជាការផ្តន្ទាទោសកម្រិតធ្ងន់ធ្ងរបំផុត ។ ទាក់ទិននឹងការវិសោធនកម្មនេះ ព្រឹទ្ធសភាកម្ពុជាបានអនុម័តសេចក្តីព្រាងច្បាប់ជាថ្មីម្តងទៀតនៅថ្ងៃទី២៣ ខែកក្កដា ហើយក្រុមប្រឹក្សារដ្ឋធម្មនុញ្ញបានសម្រេចអនុម័តនៅថ្ងៃទី៧ ខែសីហា ។ បីថ្ងៃបន្ទាប់ សម្តេច ព្រះនរោត្តម សីហនុ ឡាយព្រះហស្តលេខាលើ

ច្បាប់នេះ ។ ដូចនេះ ការអនុម័តច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចំណាយអស់រយៈពេល៧ឆ្នាំគឺជារយៈពេលយូរជាងរបបកម្ពុជាប្រជាធិបតេយ្យដែលបានសម្លាប់និងបង្អត់អាហារមនុស្សប្រមាណពីរលាននាក់ដែលមានរយៈពេលជិតបួនឆ្នាំ ។

យ៉ាងហោចណាស់ចំពោះប្រជាជនកម្ពុជា អ្វីៗទាំងអស់ហាក់បីដូចវិលត្រឡប់ទៅរកគុចរចាម្តងទៀត នៅពេលដែលលោក ហេន ខូរែល បានជូនដំណឹងដល់រាជរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ថា ÷ *«តាមសេចក្តីណែនាំរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ អង្គការសហ-ប្រជាជាតិនឹងបញ្ឈប់ការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាសម្រាប់ការកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ»* ។

លោក ហេន កូរែល បានអះអាងថារាជរដ្ឋាភិបាលកម្ពុជាពុំមានសុឆន្ទៈនឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងដែលនឹងធានាការពារទៅដល់សុចរិតភាពរបស់តុលាការ ហើយថា អង្គការសហប្រជាជាតិមិនអាចយកឈ្មោះរបស់ខ្លួនទៅប្រឡូកប្រឡាក់ជាមួយនឹងតុលាការដែលខ្លួនមានការគ្រប់គ្រងដ៏តិចតួចបំផុត ។ លោក ហេន កូរែល ក៏បានអះអាងថាអង្គការសហប្រជាជាតិគ្មានបំណងចង់ចូលរួមនៅក្នុងដំណើរការកាត់សេចក្តីដែលមិនអាចផ្តល់នូវ«យុត្តិធម៌ដែលអាចជឿទុកចិត្តបាន» ចំពោះជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលមានកម្រិតទាបជាងបទដ្ឋានយុត្តិធម៌អន្តរជាតិ ។

ដោយសម្តែងនូវការសោកស្តាយចំពោះស្ថានភាពបែបនេះ សម្តេច ហ៊ុន សែន បានអំពាវនាវទៅដល់អង្គការអន្តរជាតិនានាសុំកុំឲ្យ«ដើរផ្លូវខុសម្តងទៀត» ជាមួយនឹងអតីតមេដឹកនាំខ្មែរក្រហម ។ សម្តេចបានមានប្រសាសន៍ថា កម្ពុជាអាចចំណាយពេល«ពីរបីខែទៀត» រង់ចាំអង្គការសហប្រជាជាតិ ធ្វើការផ្លាស់ប្តូរការសម្រេចចិត្តរបស់ខ្លួន ។

លោក កូហ្វី អាណាន់ បានផ្តល់ចម្លើយតបមកវិញនៅក្នុងខែមីនាថា «មានឯកអគ្គរដ្ឋទូតជាច្រើនរូបបានមកជួបខ្ញុំពិភាក្សាពីបញ្ហានេះ ។ ឯកអគ្គរដ្ឋទូតទាំងនោះមានចំណាប់អារម្មណ៍ថា យើងគួរតែថ្លឹងថ្លែងពិចារណាជាថ្មី ។ ខ្ញុំបានឲ្យយោបល់ទៅអស់លោកអគ្គរដ្ឋទូតទាំងនោះវិញថា ខ្ញុំគិតថាដើម្បីឲ្យកាន់តែមានប្រសិទ្ធភាពយកល្អអស់លោកគួរតែអញ្ជើញទៅទីក្រុងភ្នំពេញបញ្ចុះបញ្ចូលយ៉ាងណាឲ្យ សម្តេច ហ៊ុន សែន ផ្លាស់ប្តូរជំហរនិងឥរិយាបថព្រមទាំងបញ្ជូននូវសញ្ញាណឲ្យបានច្បាស់លាស់ថាសម្តេច ពិតជាមានចំណាប់អារម្មណ៍ចង់បានតុលាការមួយដែលគួរឲ្យទុកចិត្តបានដែលស្របទៅនឹងបទដ្ឋានអន្តរជាតិ ពោលគឺយើងត្រូវចាប់ផ្តើមពីទីនោះជាមុនសិន» *(អង្គការសហប្រជាជាតិ SG/SM/8160 ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០២ : កំហត់ហេតុជាលាយលក្ខណ៍អក្សរនៃសន្និសីទកាសែតរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិនៅអគារធិការដ្ឋានអង្គការសហប្រជាជាតិ)* ។ អស់រយៈពេលជាច្រើនខែ អង្គការសហប្រជាជាតិនៅតែបន្តការច្រានចោលសេចក្តីអំពាវនាវរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសុំឲ្យបន្តគម្រោងការបង្កើតតុលាការនេះឡើងវិញ ដោយនិយាយថាខ្លួនត្រូវការនូវការធានាអះអាងបញ្ជាក់ថាភាគីកម្ពុជានឹងកាត់សេចក្តីមេដឹកនាំ«ខ្មែរក្រហម»ដោយយុត្តិធម៌ ។

នៅខែសីហា លោក កូហ្វី អាណាន់ បានបង្ហាញពីឆន្ទៈរបស់លោកក្នុងការបន្តការពិភាក្សាអំពីការបង្កើតតុលាការកាត់ទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ប្រសិនបើរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិយល់ស្របនឹងទង្វើនេះ ។ លោកអគ្គលេខាធិការបានផ្ញើលិខិតជូន សម្តេច ហ៊ុន សែន ដោយមានប្រសាសន៍ថា ដើម្បីបន្តកិច្ចចរចានេះ លោកត្រូវការ«សេចក្តីសម្រេចចិត្តជាផ្លូវការពីមហាសន្និបាតឬក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ» ជាមុនសិន ។ នៅខែវិច្ឆិកា មហាសន្និបាទបានចេញសេចក្តីសម្រេចមួយអនុញ្ញាតឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិបន្តការចរចាដោយគ្មានការពន្យារពេលដោយធ្វើយ៉ាងណាឲ្យអង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្តើមដំណើរការបានឆាប់ ។ ការចរចាបានចាប់ផ្តើមបន្តទៅមុខ ។ នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ។

ភាពយឺតយ៉ាវនិងអូសបន្លាយពេលជាងបីឆ្នាំនោះ គឺកើត

ឡើងដោយសារបញ្ហាថវិកាមួយមុខទៀត ។ ក្នុងខណៈពេលដែលថវិកាកំពុងតែរៀបចំឡើងសម្រាប់សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម (ដែលតាមការប៉ាន់ស្មានមានចំនួនប្រមាណជាង ៥៦ លានដុល្លារសហអាមេរិកសម្រាប់រយៈពេលបីឆ្នាំ) រដ្ឋសភាជាតិបានធ្វើការបោះឆ្នោតផ្តល់សច្ចាប័នកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាស្តីអំពីការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០០៤ កិច្ចព្រមព្រៀងនេះត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយសម្តេច ជា ស៊ីម ជាប្រមុខរដ្ឋស្តីទី ។

នៅចុងខែមីនា ឆ្នាំ២០០៥ រដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិបានសន្យាផ្តល់ថវិកាសរុបចំនួន ៣៨,៥លានដុល្លារអាមេរិកទៅដល់ការរៃអង្គាសថវិការបស់អង្គការសហប្រជាជាតិក្នុងការរួមចំណែកឧបត្ថម្ភទៅដល់ដំណើរការអង្គជំនុំជម្រះវិសាមញ្ញ ដែលនៅខ្វះថវិកាចំនួន ៤,៥២លានដុល្លារនៃចំនួនថវិកាសរុប ៤៣លានដុល្លារ ដែលជាបន្ទុករបស់អង្គការសហប្រជាជាតិ ។ ក្រោយមក រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសថាខ្លួនអាចរ៉ាប់រងបានត្រឹមតែ ១,៥លានដុល្លារតែប៉ុណ្ណោះ ក្នុងចំណែកថវិកា ១៣,៣លានដុល្លារដែលបន្ទុករបស់ខ្លួន ។ រាជរដ្ឋាភិបាលកម្ពុជាបានអំពាវនាវរកថវិកាបន្ថែមពីបណ្តាប្រទេសដែលមានចំណាប់អារម្មណ៍ចូលរួមដំណើរការកាត់សេចក្តីនេះដើម្បីបគ្រប់ថវិកាដែលនៅខ្វះចំនួន ១១,៨លានដុល្លារទៀត(មកដល់ខែវិច្ឆិកា ឆ្នាំ២០០៦ កង្វះខាតថវិកាបានចុះមកនៅចំនួន ៤,៩៦លានដុល្លារ) ។

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិបានប្រកាសថាឥឡូវនេះ ការសន្យាឧបត្ថម្ភថវិកាមានគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ទៅដល់អង្គជំនុំជម្រះវិសាមញ្ញ ។ ក៏ប៉ុន្តែ នៅថ្ងៃទី១៥ ខែសីហា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថា បញ្ហាបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមបានធ្វើឲ្យសម្តេច"ឈឺក្បាល" និងបានក្រើនរំឭកថា ការរួមវិភាគឧបត្ថម្ភថវិកាដល់ការជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារបស់រាជរដ្ឋាភិបាលមិនមែនជាបន្ទុករបស់សហគមន៍អន្តរជាតិទេ ។

ដោយមិនរុញរា នៅខែវិច្ឆិកា ឆ្នាំ២០០៥ អង្គការសហប្រជាជាតិបានប្រកាសថាខ្លួនកំពុងតែធ្វើដំណើរឆ្ពោះទៅរកការបង្កើតតុលាការ និងបានបញ្ជូនបញ្ជីឈ្មោះចៅក្រមនិងសហព្រះរាជអាជ្ញាអន្តរជាតិសម្រាប់អង្គបុរេជំនុំជម្រះ ។ អង្គការសហប្រជាជាតិក៏បានពន្យល់បង្ហាញអំពីរចនាសម្ព័ន្ធតុលាការនេះថា ៖ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្នុងការបង្កើតសាលាដំបូង និងតុលាការកំពូល នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដើម្បីកាត់សេចក្តី"ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា និងច្បាប់អន្តរជាតិដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩" ។



រណ្តៅសាកសពនៅវាលពិឃាតបឹងជើងឯក

តុលាការត្រូវមានសមាសភាពចៅក្រមជាតិនិងអន្តរជាតិ ។ យោងតាមកិច្ចព្រមព្រៀងដែលសង្កត់ធ្ងន់លើឯករាជ្យភាពនិងភាពមិនលម្អៀងរបស់ចៅក្រម ការចេញសេចក្តីសម្រេចនៅក្នុងសាលាក្តីទាំងពីរថ្នាក់ ត្រូវយល់ព្រមដោយមតិភាគច្រើនលើសលប់ពោលគឺ

ចៅក្រមបួនរូបក្នុងចំណោមចៅក្រមប្រាំរូបសម្រាប់សាលាដំបូង និងចៅក្រមប្រាំរូបក្នុងចំណោមចៅក្រមប្រាំពីររូបសម្រាប់តុលាការកំពូល ។

### ចៅក្រមអន្តរជាតិ

មាត្រា៣នៃកិច្ចព្រមព្រៀងចែងថាសមាសភាពសម្រាប់អង្គជំនុំជម្រះសាលាដំបូងមានចៅក្រមខ្មែរបីរូបនិងចៅក្រមអន្តរជាតិពីររូប និងសមាសភាពសម្រាប់តុលាការកំពូលមានចៅក្រមខ្មែរបួនរូបនិងចៅក្រមអន្តរជាតិបីរូប ។

យោងតាមមាត្រា៣កថាខណ្ឌទី៥នៃកិច្ចព្រមព្រៀង ចៅក្រមអន្តរជាតិទាំង៥រូបនេះត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាចេញពីបញ្ជីឈ្មោះនៃចៅក្រម៧រូបដែលលោកអគ្គលេខាធិការបញ្ជូនមក ។

ចៅក្រមអន្តរជាតិពីររូបក្នុងបញ្ជីឈ្មោះដដែលនេះ ទុកបម្រុងសម្រាប់ការតែងតាំងចៅក្រមអន្តរជាតិក្នុងករណីដែលមានកន្លែងទំនេររបស់ចៅក្រមអន្តរជាតិណាមួយ ។ ចៅក្រមអន្តរជាតិពីររូបនេះ ក៏អាចចាត់តាំងជាចៅក្រមជំនុំជម្រះរឿងក្តីជាក់លាក់មួយចំនួន ដោយអនុលោមទៅតាមមាត្រា៣ កថាខណ្ឌទី៨នៃកិច្ចព្រមព្រៀង ។

### សហព្រះរាជអាជ្ញាអន្តរជាតិ

មាត្រា៦នៃកិច្ចព្រមព្រៀងចែងថា ព្រះរាជអាជ្ញាកម្ពុជាមួយរូបនិងព្រះរាជអាជ្ញាអន្តរជាតិមួយរូបត្រូវបម្រើការជាសហព្រះរាជអាជ្ញា ។

យោងតាមមាត្រា៦ កថាខណ្ឌទី៥ សហព្រះរាជអាជ្ញាអន្តរជាតិត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាចេញពីបញ្ជីឈ្មោះសហព្រះរាជអាជ្ញាពីររូបដែលលោកអគ្គលេខាធិការអង្គការសហប្រជាជាតិប្រគល់ជូន ។

សហព្រះរាជអាជ្ញាមួយរូបនឹងត្រូវតែងតាំងជាសហព្រះរាជអាជ្ញាអន្តរជាតិបម្រុងដើម្បីបំពេញតំណែងជាសហព្រះរាជអាជ្ញាអន្តរជាតិក្នុងករណីមានកន្លែងទំនេររបស់សហព្រះរាជអាជ្ញាណាមួយឬតម្រូវការចាំបាច់ណាមួយ ។

### សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

មាត្រា៥នៃកិច្ចព្រមព្រៀងចែងថា ចៅក្រមស៊ើបអង្កេតកម្ពុជាមួយរូបនិងចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ត្រូវបម្រើការជាសហចៅក្រមស៊ើបអង្កេត ។

យោងតាមមាត្រា៥ កថាខណ្ឌទី៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកម្ពុជាចេញពីបញ្ជីឈ្មោះនៃសហចៅក្រមស៊ើបអង្កេតអន្តរជាតិចំនួនពីររូបដែលលោកអគ្គលេខាធិការអង្គការសហប្រជាជាតិប្រគល់ជូន ។

សហចៅក្រមស៊ើបអង្កេតមួយរូបក្នុងបញ្ជីឈ្មោះដដែលនេះនឹងត្រូវតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងដើម្បីបំពេញតំណែងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងករណីមានកន្លែងទំនេររបស់សហចៅក្រមអន្តរជាតិណាមួយ ឬតម្រូវការចាំបាច់ណាមួយ ។

### ចៅក្រមអន្តរជាតិសម្រាប់អង្គបុរេជំនុំជម្រះ

មាត្រា៧នៃកិច្ចព្រមព្រៀងចែងថា អង្គបុរេជំនុំជម្រះត្រូវមានចៅក្រមបីរូបដែលជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនិងចៅក្រមអន្តរជាតិពីររូបជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បន្ទាប់ពីមានការជ្រើសរើសដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

អង្គបុរេជំនុំជម្រះនឹងត្រូវកោះប្រជុំ ហើយចៅក្រមនៃអង្គបុរេជំនុំជម្រះត្រូវដោះស្រាយការខ្វែងគំនិតគ្នារវាងសហព្រះរាជអាជ្ញាឬសហចៅក្រមស៊ើបអង្កេត ។ *(សេចក្តីប្រកាសព័ត៌មានរបស់លេខាធិការដ្ឋានក្រុមការងារចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០០៥)*

ក្រុមការងាររដ្ឋបាលដំបូងនៃអង្គការសហប្រជាជាតិបានផ្តើមដំណើរមកដល់ទីក្រុងភ្នំពេញក្នុងខែធ្នូ ឆ្នាំ២០០៥ ។ នៅខែមករា ឆ្នាំ២០០៦ មួយផ្នែកនៃទីបញ្ជាការជាន់ខ្ពស់នៃកងយុទ្ធពលខេមរភូមិន្ទ ដែលមានទីតាំងនៅកំបូលជាយទីក្រុងភ្នំពេញ ត្រូវបានប្រគល់ជូនក្រុមកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៦ ចៅក្រមនិងព្រះរាជអាជ្ញាជាតិនិងអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានតែងតាំងតាមព្រះរាជក្រឹត្យ ។

ចាប់តាំងពីថ្ងៃប្រកាសតែងតាំងចៅក្រមនិងព្រះរាជអាជ្ញា

អង្គជំនុំជម្រះវិសាមញ្ញចាប់ផ្តើមជ្រើសរើសបុគ្គលិក និងចាប់ផ្តើមធ្វើការស៊ើបអង្កេតប្រមូលភ័ស្តុតាងសម្រាប់សវនាការ ។ ប្រសិនបើដំណើរការនៃកិច្ចការងារទាំងនេះប្រព្រឹត្តបានយ៉ាងល្អ សវនាការដំបូងនឹងចាប់ផ្តើមនៅក្នុងឆ្នាំ២០០៧ ។

**របនាសម្ព័ន្ធតុលាការ ៖ អធិបតេយ្យភាពនិងបទដ្ឋានអន្តរជាតិ**

ពេញមួយទសវត្សរ៍នៃដំណើរការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការពិភាក្សាគ្នាទៅលើបញ្ហានេះតែងតែចោទទៅលើថាតើនរណាគួរតែជាអ្នកគ្រប់គ្រងដំណើរការកាត់សេចក្តីនេះ ។ ម្យ៉ាងវិញទៀតអារម្មណ៍របស់ប្រជាជនកម្ពុជា (បង្ហាញតាមរយៈរដ្ឋាភិបាលរបស់ខ្លួន) បានផ្តេកផ្តួលទៅរកតុលាការជាតិទាំងស្រុងក្រោមជំនួយឧបត្ថម្ភថវិកាពីសហគមន៍អន្តរជាតិ ។ នេះជាអំពើប្រល័យពូជសាសន៍នៅកម្ពុជា ហើយកម្ពុជាពិតជាមានលទ្ធភាពក្នុងការវិនិច្ឆ័យទោសឧក្រិដ្ឋកម្មដែលប្រព្រឹត្តមកលើជាតិសាសន៍ខ្លួនឯង ។ មតិខ្លះបានលើកឡើងថាសហគមន៍អន្តរជាតិមិនគួរយកអំណាចដើម្បីទាមទារសំឡេងនៅក្នុងសវនាការឡើយ ពីព្រោះសហគមន៍អន្តរជាតិបានធ្វើមិនដឹងមិនឮចំពោះរបាយការណ៍ស្តីពីការប្រល័យពូជសាសន៍ ដែលបានផ្សព្វផ្សាយទៅដល់លោកខាងលិចនៅចុងទសវត្សរ៍ឆ្នាំ១៩៧០ និងបានទទួលស្គាល់អសនៈរបស់ខ្មែរក្រហមនៅអង្គការសហប្រជាជាតិ «ដោយស្របច្បាប់អស់រយៈពេល១០ឆ្នាំពេញ បន្ទាប់ពីរបបនេះត្រូវបានបណ្តេញចេញពីអំណាច» ។ រាជរដ្ឋាភិបាលកម្ពុជាបានលើកឡើងអំពើប្រល័យពូជសាសន៍នៅកម្ពុជាជាច្រើនលើកច្រើនសាដើម្បីឲ្យពិភពលោកបានដឹងក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ។ នៅពេលឈានដល់ពិភាក្សាបញ្ហានេះ ការរអំពាវនាវសុំឲ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហមរបស់រាជរដ្ឋាភិបាលកម្ពុជាត្រូវបានធ្វើមិនដឹងមិនឮ ប្រការនេះបានធ្វើឲ្យទង្វើករណ៍ទាំងនេះកាន់តែមានលំបាកក្នុងការដោះស្រាយ ។

ផ្ទុយទៅវិញ អ្នកប្រាជ្ញ អង្គទូត និងអ្នកជំនាញការច្បាប់ជាច្រើនបានអះអាងថាកម្ពុជានៅមិនទាន់មានលទ្ធភាពគ្រប់គ្រងដំណើរការកាត់សេចក្តីបែបនេះបានឡើយទេ ។ កត្តាជាច្រើនដែលធ្វើឲ្យកម្ពុជាមិនអាចរៀបចំដំណើរការកាត់សេចក្តីដោយខ្លួនឯងបាននោះ មានដូចជាអំពើពុករលួយក្នុងប្រព័ន្ធតុលាការដែលអ្នកមានលុយនិងអំណាចមានឱកាសឈ្នះរឿងក្តី ភាពក្រខ្សត់ឯកសារស្តីអំពីសិទ្ធិមនុស្ស ប្រការដែលមន្ត្រីជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាលជាអតីតកម្មាភិបាលខ្មែរក្រហម និងកង្វះថវិកាឧបត្ថម្ភការជំនុំជម្រះក្តីរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ដោយមូលហេតុនេះ មានមនុស្សជាច្រើននៅក្នុងសហគមន៍អន្តរជាតិយល់ឃើញថា ប្រសិនបើខ្លួនផ្តល់ថវិកាឧបត្ថម្ភដំណើរការកាត់សេចក្តីនេះ អ្នកទាំងនោះក៏មានតួនាទីសំខាន់ក្នុងការធានានូវអាកប្បកិរិយារបស់ខ្លួនឲ្យសមស្របតាមច្បាប់និងបទដ្ឋានអន្តរជាតិ ។

គុណសម្បត្តិនិងគុណវិបត្តិនៃរចនាសម្ព័ន្ធរបស់តុលាការត្រូវបានពិភាក្សាអស់រយៈពេលជាង១០ឆ្នាំ ។ ឥឡូវនេះ ស្របពេលដែលដំណើរការជំនុំជម្រះក្តីឈានជិតមកដល់ ហាក់ដូចជាមតិយល់ស្របគ្នារវាងភាគីកម្ពុជានិងអន្តរជាតិដែលថារចនាសម្ព័ន្ធតុលាការ«ចម្រុះ»នេះ គឺជាការព្រមព្រៀងគ្នាដែលសម្រេចបានចេញពីទស្សនៈជាតិនិងអន្តរជាតិ ។

ជាងនេះទៅទៀត ដោយមានការរួមចំណែកផ្តល់ថវិកាឧបត្ថម្ភពីរដ្ឋាភិបាលផ្សេងៗទៀត សម្រាប់តុលាការ«ចម្រុះ»នេះ រាជរដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចធានាឲ្យបាននូវដំណើរការមួយដែលប្រកបដោយតម្លាភាព ។ សាធារណជនមានសិទ្ធិដឹងឮជាចំហអំពីប្រភពនិងមុខសញ្ញានៃការចំណាយ ។ ការអនុញ្ញាតឲ្យមានការគ្រប់គ្រងវិធីសាស្ត្រចំណាយថវិកានិងការបោះផ្សាយរបាយការណ៍ហិរញ្ញវត្ថុជាសាធារណៈ មុខជាអាចផ្តល់ទំនុកចិត្តបន្ថែមលើរាជរដ្ឋាភិបាលកម្ពុជាពីសំណាក់ប្រជាពលរដ្ឋ ក៏ដូចជាសហគមន៍អន្តរជាតិ ។ ជាងនេះទៅទៀត កម្ពុជាជាអ្នកគ្រប់គ្រងដំណើរការកាត់សេចក្តីនៅក្នុងក្រសែភ្នែករបស់ប្រជាជននៅលើពិភពលោក ។

លើសពីនេះទៀត ចៅក្រមកម្ពុជា១៧រូបនិងចៅក្រមអន្តរជាតិ១៣រូប ត្រូវទទួលខុសត្រូវការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ ម្យ៉ាងទៀត រូបមន្ត«មតិភាគច្រើនលើសលប់» ដែលតម្រូវឲ្យមានការឯកភាពយល់ព្រមពីចៅក្រមអន្តរជាតិយ៉ាងតិចមួយរូបជាមួយចៅក្រមកម្ពុជាដើម្បីធ្វើសេចក្តីសម្រេចចិត្ត និងធានាឲ្យបាននូវភាពត្រឹមត្រូវ ។

ជាងនេះទៅទៀត តុលាការចម្រុះនេះមិនផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជនកម្ពុជា តែផ្តល់ផលប្រយោជន៍សំខាន់

ដូចៗគ្នា ។ ការនិយាយថា តុលាការចម្រុះនឹងជួយកាត់បន្ថយភាពក្រីក្រនៅកម្ពុជាឬអំពើអយុត្តិធម៌ដែលញាំញីសង្គមខ្មែរ គឺជាការរំពឹងទុកការជំនុំជម្រះក្តីខុសពេក ។ ក៏ប៉ុន្តែ ប្រសិនបើកំហុសអតីតត្រូវបានដោះស្រាយតុលាការនេះនឹងក្លាយទៅជាគ្រឿងលើកទឹកចិត្តសម្រាប់បម្រើផលប្រយោជន៍សង្គមច្បាប់និងសេដ្ឋកិច្ចដែរ ។

## ផលប្រយោជន៍សង្គម

ជាង៨០ភាគរយនៃប្រជាជនកម្ពុជាអាយុលើសចាប់ពី៤០ឆ្នាំ ទទួលរងនូវជំងឺបាក់ស្បាត ភាពតានតឹងក្នុងអារម្មណ៍ ឬជំងឺប៉ះទង្គិចផ្លូវចិត្តដែលប្រជាជនកម្ពុជាបានឆ្លងកាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជំងឺនេះបង្កើតប្រទេសជាតិមួយដែលខ្វះចន្លោះតាមមធ្យោបាយជាច្រើន ពីព្រោះប្រជាជនយល់ថាខ្លួនសឹងតែមិនអាចរស់នៅក្នុងជីវិតបែបនេះ ។ ដោយសារតែមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យមិនទាន់ត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរបស់ខ្លួន ប្រជាជនកម្ពុជាមានអារម្មណ៍តែលគោលនិងបាក់ទឹកចិត្ត ដែលមានលក្ខណៈដូចគ្នាទៅនឹងរបៀបរស់នៅប្រចាំថ្ងៃរបស់ខ្លួន ជាការពិតណាស់ នេះជាការផ្សារយល់ស្ថានភាពរស់នៅរបស់ប្រជាជនកម្ពុជាប៉ុន្តែរហូតមកទល់ពេលនេះនៅមិនទាន់មានការជជែកគ្នាអំពីគណៈកម្មការស្វែងរកការពិត ឬមធ្យោបាយណាមួយសម្រាប់ប្រជាជនកម្ពុជាបង្ហាញនូវជំងឺប៉ះទង្គិចផ្លូវចិត្តដែលខ្លួនទទួលរងនិងបន្តឈឺចាប់រហូតដល់សព្វថ្ងៃ ។ ដូចនេះការស្វែងរកយុត្តិធម៌ដោយចំហនឹងជួយកាត់បន្ថយការចងចាំដែលប្រជាជនកម្ពុជាជួបប្រទះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អតីតកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមដែលរស់នៅក្នុងស្ថានភាពយ៉ាប់យ៉ឺនក្បែរជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមសារភាពកំហុសជាបណ្តើរៗ ហើយសង្គមជាតិទាំងមូលចាប់ផ្តើមផ្សះផ្សានិងធូរស្បើយ ។

## ផលប្រយោជន៍ប្រព័ន្ធតុលាការ

បើទោះបីជាមានការតវ៉ាក្នុងការតែងតាំងចៅក្រមកម្ពុជា (ដោយសំអាងលើហេតុផលអំពើពុករលួយ) សមាសភាពនៃអង្គជំនុំជម្រះវិសាមញ្ញទំនងជាដំណើរការដោយមានភាពឯករាជ្យនិងភាពមិនលម្អៀង ។ តុលាការឯករាជ្យពិតប្រាកដនឹងប៉ះពាល់ជាវិជ្ជមាននិងអនុភាពនៃ“វប្បធម៌លើកលែងទោស” របស់កម្ពុជា ។ អស់រយៈពេលជិត៣០ឆ្នាំមកហើយ អតីតមេដឹកនាំខ្មែរក្រហមបានបន្តរស់នៅយ៉ាងសប្បាយរីករាយ ដោយគ្មានការដាក់ទោសចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា ។ អតីតមេដឹកនាំខ្មែរក្រហមទាំងនោះរស់នៅយ៉ាងមានសេរីភាពនិងមិនខ្វល់ខ្វាយពីការដាក់ទោសអ្វីឡើយ ។ តួយ៉ាង ដូចជា អៀង សារី មិនត្រឹមតែទទួលបានការលើកលែងទោសពីសម្តេច ព្រះនរោត្តម សីហនុ តែប៉ុណ្ណោះទេ ថែមទាំងទទួលបានផលប្រយោជន៍ផ្សេងៗពីរាជរដ្ឋាភិបាលទៀត ។ ជនដែលស្មោះត្រង់ នឹង អៀង សារី ដោយរាប់បញ្ចូលទាំងកូនប្រុសគាត់ អៀង វុធ គ្រប់គ្រងតំបន់ស្វយ័តប៉ៃលិនដ៏ស្តុកស្តម្ភ ដែលរដ្ឋាភិបាលបានកាត់ឲ្យអតីតមេដឹកនាំខ្មែរក្រហមជាថ្នូរដោះដូរយកសន្តិភាព ។ ដូចគ្នានឹងជនដៃដល់ដទៃទៀតដែរ អៀង សារី និងអតីតមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាសុទ្ធតែបដិសេធមិនទទួលស្គាល់តួនាទីរបស់ខ្លួននៅក្នុងរបបប្រល័យពូជសាសន៍កម្ពុជា ។

ក៏ប៉ុន្តែវប្បធម៌លើកលែងទោសមិនទាន់ចប់ឡើយ ប្រជាពលរដ្ឋកម្ពុជាជាច្រើនត្រូវបង្ខំចិត្តស៊ូទ្រាំនឹងអំពើអយុត្តិធម៌និងការគំរាមកំហែងពីអ្នកនយោបាយមួយចំនួនដែលគិតថាខ្លួនឯងធំជាច្បាប់ ។ អ្នកមានអំណាចធ្វើអ្វីតាមតែអំពើចិត្ត ក៏ប៉ុន្តែប្រជាជនសាមញ្ញទទួលរងនូវការឈឺចាប់ និងពុំមាននរណាម្នាក់រំពឹងថា “ច្បាប់” នឹងជួយធ្វើអន្តរាគមន៍ដោះស្រាយស្ថានភាពបែបនេះឡើយ ។

ការដាក់មេដឹកនាំខ្មែរក្រហមឲ្យទទួលខុសត្រូវចំពោះមុខប្រជាជនកម្ពុជានិងពិភពលោកទាំងមូល គឺជាមធ្យោបាយដ៏មានប្រសិទ្ធ-ភាពដែលកម្ពុជាអាចចាប់ផ្តើមលុបបំបាត់វប្បធម៌លើកលែងទោសនិងបង្កើតប្រព័ន្ធច្បាប់ ។ ដោយផ្អែកទៅលើច្បាប់កិច្ចការដ៏សំខាន់នោះនឹងមានភាពងាយស្រួលតាមរយៈការចូលរួមពីសហគមន៍អន្តរជាតិក្នុងដំណើរការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ។

## ផលប្រយោជន៍ក្នុងវិស័យសេដ្ឋកិច្ច

ក្នុងខណៈពេលដែលកម្ពុជាបញ្ឈប់ដំណើរការបង្កើតតុលាការមានមន្ត្រីជាច្រើនបានសម្តែងមតិរបស់ខ្លួនជាមួយនឹងហេតុផលថា រដ្ឋាភិបាលបានផ្តល់សិទ្ធិជាអទិភាពដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាចំបង ជាជាងការស្វែងរកយុត្តិធម៌សម្រាប់អំពើប្រល័យពូជសាសន៍ ដូចនេះថវិកាដែលគ្រោងនឹងចំណាយលើការបង្កើត

តុលាការគួរតែបង្វែរមកចំណាយលើបញ្ហាភាពក្រីក្រប្រសើរជាង ។ ចំណូលប្រចាំថ្ងៃជាមធ្យមប្រជាជនកម្ពុជាអាចរកបានតែ១ដុល្លារ ប៉ុណ្ណោះក្នុងមួយថ្ងៃ ។ ប្រជាជនកម្ពុជាច្រើនគាំទ្រឲ្យមានការវិនិយោគនិងជំនួយជាថវិកានៃប្រទេសជាម្ចាស់ជំនួយ ។ ក៏ប៉ុន្តែសូម្បីតែប្រជាជនធម្មតាក៏ហាក់ដូចជាមិនមានជំនឿលើទន្និករណ៍នេះ ។ ផ្ទុយទៅវិញការស្ទាបស្ទង់មតិបានបង្ហាញថា តុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមគឺមានសារសំខាន់សម្រាប់


អគាររដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ប្រជាជនកម្ពុជាក្នុងវិស័យសេដ្ឋកិច្ច ។

ប៉ុន្តែ គម្រោងការអភិវឌ្ឍន៍សេដ្ឋកិច្ចនឹងខកខានមិនបានសម្រេចនៅក្នុងស្ថានភាពដែលគ្មានតម្លាភាព គ្មានការទទួលខុសត្រូវនិងគ្មានមូលដ្ឋានគ្រឹះដ៏រឹងមាំនៅក្នុងនីតិរដ្ឋ ។ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាមិនបង្ហាញឆន្ទៈដោះស្រាយករណីលើកលែងទោសទេ សហគមន៍អន្តរជាតិ ក៏ដូចជាប្រជាជនកម្ពុជានឹងគ្មានទំនុកចិត្តថារាជរដ្ឋាភិបាលកម្ពុជា នឹងចាត់វិធានការដោះស្រាយបញ្ហាជាក់ស្តែងនោះឡើយ ។ ប្រសិនបើសវនាការអាចនាំមកនូវយុត្តិធម៌នោះ ការនាំមកនូវយុត្តិធម៌នេះនឹងឆ្លុះបញ្ចាំងលទ្ធផលល្អទៅដល់រាជរដ្ឋាភិបាលកម្ពុជា និងអាចនាំមកនូវការវិនិយោគនិងការអភិវឌ្ឍន៍នៅក្នុងប្រទេស ។

ការយល់ដឹងនូវសកម្មភាពនៅក្នុងវិស័យសេដ្ឋកិច្ច និងការយល់ដឹងរបស់សហគមន៍អន្តរជាតិអាចផ្តល់ការគាំទ្របន្ថែមចំពោះដំណើរការបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ សហគមន៍អន្តរជាតិកំពុងតែបន្តកែតម្រូវប្រពន្ធ័ច្បាប់នៅកម្ពុជាឲ្យកាន់តែប្រសើរ ។ ប្រសិនបើសហគមន៍អន្តរជាតិទទួលបានជោគជ័យក្នុងកិច្ចការនេះ ការយល់ដឹងរបស់ប្រជាជនកម្ពុជាក៏នឹងផ្លាស់ប្តូរដែរ ។ នៅពេលប្រជាជនកម្ពុជាមានទំនុកចិត្តថាប្រទេសរបស់ខ្លួននឹងរុងរឿងនោះ ខ្លួននឹងមានឱកាសបញ្ចេញមតិអំពីជីវិតអនាគតរបស់ខ្លួន ប្រជាជនអាចមានជំនឿទុកចិត្តលើប្រពន្ធ័នយោបាយដែលខ្លួនកំពុងរស់នៅ ហើយប្រជាជនកម្ពុជានឹងឆ្លើយតបទៅវិញក្នុងផ្លូវជាវិជ្ជមាន ។ ក្រុមឈ្មួញអាចធ្វើការវិនិយោគទៅបានដរាបណាអ្នកវិនិយោគទុននោះយល់ច្បាស់អំពីច្បាប់ ។ ប្រជាជនកម្ពុជាចង់បង្កើតការងារនៅក្នុងប្រទេសប្រសើរជាងការបង្វែរធនធានផ្ទាល់ខ្លួន ឬចេញទៅបរទេស ដោយប្រជាជនកម្ពុជាជឿថា ប្រព័ន្ធគ្រប់គ្រងនេះនឹងផ្តល់ឱកាសស្មើៗគ្នា ។ ប្រសិនលើការជឿទុកចិត្តរបស់ប្រជាជនកម្ពុជាទៅលើរាជរដ្ឋាភិបាលកម្ពុជាត្រូវបានស្តារឡើងវិញ យើងក៏រំពឹងថាសេដ្ឋកិច្ចជាតិនឹងមានការរីកចម្រើន ។ ការអភិវឌ្ឍន៍នេះអាចមានប្រសិទ្ធភាពឆាប់រហ័ស និងស្ថិតស្ថេរយូរអង្វែងចំពោះប្រទេសជាតិដែលប្រជាជនកម្ពុជាជិត៤០ភាគរយអាយុក្រោម១៨ឆ្នាំ ។

## ផលប្រយោជន៍សម្រាប់លទ្ធិប្រជាធិបតេយ្យដែលទើបនឹងលូតលាស់

ប្រសិនបើចៅក្រមនៃភាគីរាជរដ្ឋាភិបាលកម្ពុជាដោះស្រាយបញ្ហាការលើកលែងទោសមេដឹកនាំខ្មែរក្រហមដោយត្រង់ៗ ហើយរាជរដ្ឋាភិបាលកម្ពុជាគាំទ្រចៅក្រមទាំងនោះ ប្រជាជនកម្ពុជានឹងបង្កើនទំនុកចិត្តកាន់តែខ្លាំងទៅលើកិច្ចការដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងតែធ្វើដើម្បីការពារប្រយោជន៍ប្រជាជនកម្ពុជា ។ ដោយប្រកាន់ភ្ជាប់នូវទំនុកចិត្តនេះ ប្រជាជនកម្ពុជាអាចបង្កើតនូវឥទ្ធិពលរបស់ខ្លួនដើម្បីអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។ សេចក្តីសម្រេចដែលប្រជាជនកម្ពុជាចាត់ទុកថាមានភាពត្រឹមត្រូវអាចមានអនុភាពជាច្រើនទាក់ទិននឹងអ្នកដែលខិតខំព្យាយាមធ្វើសម្រេចបាននូវដំណើរការច្បាប់ប្រកបដោយយុត្តិធម៌និងតម្លាភាព ដូចជា បញ្ហាសិទ្ធិកាន់កាប់ដីធ្លីនិងបណ្តឹងរដ្ឋប្បវេណី និងការទាមទារនូវសិទ្ធិពលរដ្ឋ ។ ការផ្តល់ទំនុកចិត្តឲ្យប្រជាជនកម្ពុជា ដែលភាពស្មោះត្រង់របស់គាត់ជួយកែលម្អជីវភាពរស់នៅរបស់គាត់កាន់តែប្រសើរឡើង និងធ្វើឲ្យប្រទេសជាតិទទួលបានការគាំទ្រដោយមិន

លម្អៀងពីប្រជាពលរដ្ឋនឹងជួយប្រជាពលរដ្ឋកម្ពុជាចូលរួមយ៉ាងសកម្មក្នុងរាជរដ្ឋាភិបាលកម្ពុជា ។

ការបង្កើតតុលាការចម្រុះនេះ គឺជាការបើកផ្លូវឲ្យមានការទទួលខុសត្រូវជាសាធារណៈ ដែលទង្វើនេះមិនមែនទម្លាប់នៅក្នុងសង្គមខ្មែរ ។ ជាឧទាហរណ៍ នៅខែមេសា ឆ្នាំ២០០៥ សាលាក្រុងភ្នំពេញបានអនុញ្ញាតឲ្យក្រុមហ៊ុនជប៉ុនមួយមានសិទ្ធិអភិវឌ្ឍន៍និងគ្រប់គ្រងវាលពិឃាតបឹងជើងឯក (ដែលមានចម្ងាយប្រមាណ ២៥គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ដែលជាទីកន្លែងដែលអ្នកទោសគុកទួលស្លែងប្រមាណជាង ១ម៉ឺននាក់ ត្រូវខ្មែរក្រហមយកមកសម្លាប់) និងមានសារសំខាន់សម្រាប់ប្រជាជនកម្ពុជា ។ ការព្រមព្រៀងអាជីវកម្មបានអនុញ្ញាតឲ្យក្រុមហ៊ុននេះប្រែក្លាយបូជនីយដ្ឋាននេះជាតំបន់ទេសចរណ៍សម្រាប់រយៈពេល៣០ឆ្នាំដើម្បីជាការដោះដូរការចំណាយដែលចំនួនសរុប១៥.០០០ដុល្លារក្នុងមួយឆ្នាំៗ ។ កិច្ចព្រមព្រៀងដែលធ្វើឡើងដោយសម្ងាត់នេះត្រូវបានបញ្ចប់ដោយមានការតវ៉ាពីសាធារណជន ។ ប្រសិនបើសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមបើកចំហនិងមានតម្លាភាព និងប្រសិនបើប្រជាជនកម្ពុជាមានឱកាសចូលរួមដំណើរការតុលាការដូចជាតាមរយៈការអនុញ្ញាតឲ្យរួមចូលស្តាប់សវនាការ ប្រជាជនកម្ពុជានឹងត្រូវបានផ្តល់ការលើកទឹកចិត្តចូលរួមយ៉ាងសកម្មនៅក្នុងវិស័យច្បាប់និងនយោបាយ ។ សកម្មភាពនេះអាចចាត់ទុកថា ជាផ្លូវឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យជាមួយកិច្ចសហប្រតិបត្តិការនិងការចូលរួមពីគ្រប់ផ្នែកទាំងអស់នៃសង្គមដែលនាំឆ្ពោះទៅអនាគតដែលប្រកបដោយយុត្តិធម៌ក្នុងការធានាឲ្យបាននូវការលើកស្ទួយនិងការការពារសិទ្ធិមនុស្សសម្រាប់យើងទាំងអស់គ្នា ។

នៅចុងបញ្ចប់ កម្ពុជាគឺជាកន្លែងដែលមានអង្គការសិទ្ធិមនុស្សនិងសិទ្ធិពលរដ្ឋមិនតិចជាង៥០០ឡើយ ។ ឥឡូវនេះ ក្នុងខណៈពេលដែលតុលាការគ្រោងនឹងចាប់ផ្តើមអង្គការក្រៅរដ្ឋាភិបាលតូចៗជាច្រើនកំពុងតែស្វែងរកការពិភាក្សាគ្នាស្តីអំពីរបៀបវារៈសិទ្ធិមនុស្ស ។ ទន្ទឹមនឹងនោះ ប្រសិនបើអង្គការទាំងនេះរៀបចំកិច្ចការរបស់ខ្លួនបានល្អប្រសើរ ហើយសកម្មភាពការងាររបស់ខ្លួនមានលក្ខណៈប្រុងប្រយ័ត្ននិងល្អឥតខ្ចោះ អង្គការមិនមែនរដ្ឋាភិបាលទាំងនេះ នឹងក្លាយទៅជាសំឡេងដ៏សំខាន់មួយក្នុងការគាំទ្រនូវនីតិរដ្ឋនិងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។

## ***ផលប្រយោជន៍នៃឯកសារប្រវត្តិសាស្ត្រដ៏ល្អប្រសើរ***

ការរួមវិភាគទានដ៏មានតម្លៃមួយទៀតនៃតុលាការចម្រុះនេះគឺការបង្កើនជំនឿទុកចិត្តដែលថា "ការពិត"លាតត្រដាងចេញយ៉ាងច្បាស់ ។ អ្នកសិក្សាស្រាវជ្រាវជាច្រើនបានគិតថាការស្ទាក់ស្ទើររបស់រាជរដ្ឋាភិបាលក្នុងការបង្កើតតុលាការ និងការខិតខំប្រឹងប្រែងជាច្រើនក្នុងការបញ្ឈប់ដំណើរការកាត់សេចក្តីនេះ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងបិតបាំងនូវទំនាក់ទំនងរបស់កម្មាភិបាលជាច្រើនជាមួយនឹងបក្សកុម្មុយនិស្តកម្ពុជា ។ មិនខុសគ្នាពីប្រជាជនកម្ពុជាជាច្រើនទៀត កម្មាភិបាលទាំងនេះភាគច្រើនត្រូវបម្រើការឲ្យខ្មែរក្រហមដោយបង្ខំ ឬស្ម័គ្រចិត្តបម្រើខ្មែរក្រហមដើម្បីជួយដល់ប្រទេសជាតិ ។ ទោះជាយ៉ាងក៏ដោយ កម្មាភិបាលទាំងនេះ មិនចង់ឲ្យទំនាក់ទំនងរបស់ខ្លួនក្លាយជាឯកសារផ្លូវការសម្រាប់ឲ្យពិភពលោកដឹងឮឡើយ (ទំនាក់ទំនងពីមុនរបស់កម្មាភិបាលទាំងនោះគឺជា"ការសម្ងាត់បើកចំហ" នៅកម្ពុជា) ។ ម្យ៉ាងទៀត មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមភៀសខ្លួនពីការទទួលខុសត្រូវចំពោះមុខច្បាប់ ដោយជ្រកកោនក្រោមពាក្យថា "ការផ្សះផ្សាជាតិ" ។ ទស្សនៈ"កប់រឿងរ៉ាវអតីតកាល"នេះជាទស្សនៈមួយដែលជះឥទ្ធិពលអាក្រក់ទៅដល់ប្រទេសជាតិនិងត្រូវបានប្រើប្រាស់ដើម្បីរារាំងការកសាងប្រទេសជាតិឡើងវិញដោយផ្អែកលើនីតិរដ្ឋ ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។

ជាការពិតណាស់ តុលាការនេះពិតជាអាចដើរតួនាទីជាអ្នកក្រើនរំឭកដើម្បីនាំប្រទេសជាតិធ្វើដំណើរឆ្ពោះទៅមុខ ។ បច្ចុប្បន្នក្មេងជំនាន់ក្រោយភាគច្រើនមិនជឿថា ឪពុកម្តាយរបស់ខ្លួនធ្លាប់ឆ្លងកាត់ការឈឺចាប់ បានបាត់បង់សេរីភាព ការស្រេកឃ្លាន និងការធ្វើទារុណកម្មឡើយ ។ សៀវភៅសិក្សានៅសាលារៀនក៏លែងមានសរសេរពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាការរាំងស្កាត់កូនចៅជំនាន់ក្រោយមិនបានរៀនសូត្រអំពីកំហុសដែលប្រទេសបានធ្វើនៅក្នុងអតីតកាល ។ (ហេតុការណ៍នេះជាលទ្ធផលនៃនយោបាយ ។ គ្រប់ផ្នែកទាំងអស់នៃប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើបត្រូវបានដកចេញពីសៀវភៅសិក្សា ក្រោយពីការប្រកាសលទ្ធផលបោះឆ្នោតឆ្នាំ២០០៣) ។ ទន្ទឹមនិងនេះដែរ សៀវភៅសិក្សាប្រវត្តិ

សាស្ត្រកម្ពុជាប្រជាធិបតេយ្យត្រូវបានរំពឹងថានឹងបោះពុម្ពផ្សាយនៅឆ្នាំក្រោយ) ។

## ទស្សនៈប្រជាជនកម្ពុជាស្តីអំពីសវនាការ

នៅប្រទេសកម្ពុជា ដែលអត្រានៃអ្នកចេះអាននិងសរសេរប្រហែល៦៥ភាគរយ និងឱកាសស្វែងយល់ព័ត៌មានតាមរយៈការអានកាសែតនិងប្រព័ន្ធផ្សព្វផ្សាយមិនអាចផ្សព្វផ្សាយទៅដល់តំបន់ឆ្ងាយៗជាច្រើន ។ កម្ពុជាត្រូវការជាចាំបាច់ឲ្យមានការអប់រំស្តីពីតុលាការនិងអត្ថន័យនៃដំណើរការកាត់សេចក្តីនេះ ។ រាជរដ្ឋាភិបាលកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងតុលាការកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើន បានចាប់ផ្តើមធ្វើការផ្សព្វផ្សាយទូទាំងប្រទេសដើម្បីឲ្យប្រជាជនកម្ពុជាធ្វើការស្វែងយល់អំពីច្បាប់ ដើម្បីផ្សព្វផ្សាយព័ត៌មានស្តីអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងដំណើរការអង្គជំនុំជម្រះវិសាមញ្ញកម្ពុជានេះ និងដើម្បីឆ្លើយនូវសំណួររបស់អ្នកស្រុកអ្នកភូមិ ដូចជា តើអ្នកណាខ្លះនឹងត្រូវយកមកធ្វើការកាត់ទោស (អតីតកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមមានការចង់ដឹងចង់ឮអំពីបញ្ហានេះ ហើយយុទ្ធនាការផ្សព្វផ្សាយព័ត៌មានធ្វើឡើងយ៉ាងទូលំទូលាយដើម្បីផ្តល់ចម្លើយតបទៅវិញថា មានតែ"មេដឹកនាំជាន់ខ្ពស់និងជនទទួលខុសត្រូវខ្ពស់បំផុតនៃរបបខ្មែរក្រហមតែប៉ុណ្ណោះដែលនឹងត្រូវយកមកធ្វើការកាត់ទោស" ។

ឆ្លងតាមការសម្ភាសន៍អស់រយៈពេលជាង១០ឆ្នាំ ស្តីពីសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ក្នុងចំណោមប្រជាជនរាប់ពាន់នាក់ មានតែមួយចំនួនតូចបំផុតប៉ុណ្ណោះដែលទាមទារឲ្យមានសំណងជំងឺចិត្តជាលុយកាក់ចំពោះអ្វីដែលខ្មែរក្រហមបានប្រព្រឹត្តមកលើខ្លួននិងក្រុមគ្រួសាររបស់គាត់ ។ ផ្ទុយទៅវិញ ជនរងគ្រោះប្រាថ្នាត្រឹមតែចង់ដឹងចម្លើយពីសំណួរ "តើហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនខ្លួនឯងដូច្នេះ?" ។ ទោះបីជាជនរងគ្រោះត្រូវបានផ្តល់នូវសំណងជំងឺចិត្ត ក៏ជនរងគ្រោះដឹងថាសំណងនេះមិនគ្រប់គ្រាន់នឹងជួសជុលនូវការឈឺចាប់ដែលខ្លួនបានឆ្លងកាត់នៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ ការទាមទាររបស់ជនរងគ្រោះមិនច្រើនទេ ។ ជនរងគ្រោះគ្រាន់តែចង់បានការទទួលខុសត្រូវចំពោះមុខច្បាប់ដែលគាត់ទន្ទឹងរង់ចាំដោយក្តីអត់ធ្មត់អស់រយៈពេលជាង២៨ឆ្នាំមកហើយ ។

តាមការសម្ភាសន៍និងការចូលរួមដំណើរទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនរងគ្រោះមានសំណួរជាច្រើន ។ គាត់ចង់ដឹងថាតើអ្នកណាខ្លះនឹងយកមកកាត់ទោសតាមផ្លូវច្បាប់ តើនៅពេលណាទើបសវនាការចាប់ផ្តើមដំណើរការ តើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងដំណើរការដោយរបៀបណា ។ តើជនរងគ្រោះយល់យ៉ាងដូចម្តេចអំពីការកាត់សេចក្តីនេះ និងតើជនរងគ្រោះអាចដាក់ពាក្យបណ្តឹងចោទប្រកាន់ជនជាប់ចោទដោយរបៀបណា ។ ជាក់ស្តែងជនរងគ្រោះនឹងទទួលបាននូវចម្លើយនៃសំណួរទាំងនេះ និងសំណួរផ្សេងៗទៀតនៅពេលសវនាការបានលាតត្រដាងការពិត ។

ក៏ប៉ុន្តែមានសំណួរជាច្រើនទៀត ដែលប្រជាជនកម្ពុជាបានចែករំលែកជាមួយប្រជាជននៅជុំវិញពិភពលោកនៅមិនទាន់អាចស្វែងរកចម្លើយត្រឹមត្រូវនៅក្នុងតុលាការនៃច្បាប់ ។ ពុំមានអ្នកណាម្នាក់ដឹងច្បាស់ថាតើហេតុអ្វីបានជាប្រជាជនកម្ពុជាសម្លាប់ជាតិសាសន៍ខ្លួនឯងទេ ។ សព្វថ្ងៃប្រជាជនកម្ពុជាជាច្រើននាក់នៅបន្តជឿថា គឺជនបរទេសជាអ្នកបញ្ជាឲ្យខ្មែរសម្លាប់ខ្មែរគ្នាឯង ។ ប្រជាជនកម្ពុជាងឿងឆ្ងល់អំពីតួនាទីនយោបាយនៃប្រទេសលោកខាងលិចមួយចំនួន និងថាតើប្រទេសទាំងនេះនឹងត្រូវយកមកជំនុំជម្រះដែរឬទេ? ប្រជាជនកម្ពុជាបានសួរនូវសំណួរថា តើហេតុអ្វីបានជាអង្គការសហប្រជាជាតិនិងប្រទេសដទៃទៀតមិនជួយអន្តរាគមន៍បញ្ឈប់អំពើប្រល័យពូជសាសន៍នៅកម្ពុជា ។

មានតែការសិក្សាស្រាវជ្រាវទេដែលអាចជួយយើងលាតត្រដាងអាថ៌កំបាំងជុំវិញរបបកម្ពុជាប្រជាធិបតេយ្យដែលកន្លងទៅជិតបីទសវត្សរ៍មកហើយ ។ សំណួរទាំងនេះអាចនឹងបន្តវិលវល់ក្នុងអារម្មណ៍ប្រជាជនខ្មែរពីមួយជំនាន់ទៅមួយជំនាន់ ក៏ប៉ុន្តែមានតែសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមដែលអាចជួយយើងចាប់ផ្តើមស្វែងរកចម្លើយតាមរយៈការយកការពិតមកលាតត្រដាង ។ ខ្មែរក្រហមជាចោរនៃប្រវត្តិសាស្ត្ររបស់យើង ហើយនេះជាពេលវេលាយើងបានត្រឡប់មកវិញនូវប្រវត្តិសាស្ត្រ យើងសិក្សាប្រវត្តិសាស្ត្រយើងនិងផ្សះផ្សាខ្លួនយើងនិងអ្នកផ្សេងៗទៀត ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ជា កាក់ : យុទ្ធជនសួរចម្លើយនៅមន្ទីរស-២១

ជា កាក់ ជាយុទ្ធជនសួរចម្លើយនៅមន្ទីរស-២១នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ កាក់ មានស្រុកកំណើតនៅភូមិស្អាងភ្នំ ឃុំស្អាងភ្នំ ស្រុក២០ តំបន់២៥ ខេត្តកណ្តាល ។ មុនធ្វើជាយុទ្ធជនសួរចម្លើយ កាក់ ជាគ្រូបង្រៀនកុមារតូចៗនៅក្នុងភូមិ ។ នៅដើមឆ្នាំ១៩៧៥ កាក់ បានចូលបម្រើការងារនៅក្នុងអង្គភាពយោធានៅវរសេនាតូច១២៧ វរសេនាធំ២៦៨ កងពល៧០៣ រហូតដល់ខែកញ្ញា អង្គការបានបញ្ជូនឲ្យទៅធ្វើការនៅមន្ទីរស-២១ផ្នែកកងការពារនិងផ្នែកសួរចម្លើយ ក្រោយមកត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី២៥ខែមីនា ឆ្នាំ១៩៧៨ ពីបទធ្វើទារុណកម្មអ្នកទោសឲ្យគ្រាំគ្រារហូតដល់បាត់ចម្លើយ ។

កាក់ បានរៀនសូត្រត្រឹមថ្នាក់៨ចាស់នៅសាលាវត្តស្អាងស្រែក្នុងស្រុកស្អាងភ្នំ ។ កាក់ ឈប់រៀននៅក្រោយថ្ងៃរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ។ នៅខែធ្នូ ឆ្នាំ១៩៧០ កាក់ ទទួលការចាត់តាំងពីសន្តិសុខភូមិឈ្មោះ ម៉ៃ និង ជូ ឲ្យធ្វើជាសន្តិសុខភូមិដើម្បីតាមដាននិងចាប់ប្រជាជនណាដែលលួចដឹកសម្ភារលក់ឲ្យខ្មាំង ។

នៅខែកក្កដាឆ្នាំ១៩៧២ ប្រធានភូមិស្អាងភ្នំឈ្មោះ គ្រង់ បានចាត់តាំង កាក់ ធ្វើជាគ្រូបង្រៀនកុមារនៅក្នុងភូមិ ដែលមាន គ្រង់ និង នារីផល ជាអ្នកមើលការខុសត្រូវ ។

នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៥ អង្គការបានចាត់តាំង កាក់ ឲ្យបម្រើក្នុងជួរកងទ័ព ។ មុនឡើងសមរភូមិ កាក់ ត្រូវបានចាត់តាំងឲ្យទៅរៀនវគ្គនយោបាយរបស់កងពល៧០៣ នៅវត្តកំពតពលរយៈពេល១៣ថ្ងៃ និងបន្តហ្វឹកហាត់បច្ចេកទេសយោធានៅកោះខ្សាច់ទន្លេរយៈពេលជិត៣សប្តាហ៍ទៀត ។ ក្រោយពីបញ្ចប់វគ្គរៀនសូត្រ កាក់ ត្រូវបានបញ្ជូនទៅនៅវរសេនាតូច១២៧ វរសេនាធំ២៦៨ កងពលលេខ៧០៣ ។

នៅចុងខែមេសា ឆ្នាំ១៩៧៥ យ៉ន បញ្ជាការកងរយ វរសេនាតូច១២៧ បានចាត់តាំង កាក់ ឲ្យទៅធ្វើខាងសេដ្ឋកិច្ចកងរយ ។ យ៉ន តែងតែយកចិត្តទុកដាក់និងសួរនាំអំពីក្រុមគ្រួសាររបស់ កាក់ ជាញឹកញាប់ដើម្បីទាក់ទាញ កាក់ ឲ្យចូលក្នុងក្រុមរបស់ខ្លួន ។ ក្រោយមក យ៉ន ណែនាំ កាក់ ឲ្យស្គាល់ សូត ។ អ្នកទាំងពីរបានចាប់ផ្តើមអប់រំ កាក់ ឲ្យមានគោលជំហរប្រឆាំងនឹងបដិវត្តន៍ ។

៥ថ្ងៃក្រោយមក អ្នកទាំងពីរបានហៅ កាក់ ទៅជួបម្តងទៀតដើម្បីណែនាំឲ្យឈប់ធ្វើការនៅផ្នែកសេដ្ឋកិច្ច ហើយទៅធ្វើការជាមួយ ថា ជាលេខាកងហានៃកងធំ៧១វិញ ។ ថា បានបើកអង្គប្រជុំមួយនៅសាលាបឹងត្របែកដើម្បីណែនាំ កាក់ ឲ្យស្គាល់មនុស្សដែលត្រូវធ្វើការជាមួយ (មាន គាំង, សរិត, ម៉ាប់ និង ហួត) និងរៀបចំអនុវត្តតាមផែនការថ្មីពីរគឺ ១) រកវិធីបំផ្លាញសម្ភារបដិវត្តន៍តាមលទ្ធភាពដែលអាចធ្វើបាន និង២) ទិតទំកសាងកម្លាំងបន្ថែម ។ ក្រោយពីទទួលភារកិច្ច កាក់ និង ហួត ដើរបំផ្លាញសម្ភារតាមផ្ទះវាយកញ្ចក់ទូ យកសម្លៀកបំពាក់ល្អៗបោះចោលក្នុងគំនរសំរាម និងលួចបើកទឹកចោលតាមផ្ទះជាញឹកញាប់ ។

បន្ទាប់មក អង្គការចាត់តាំងអង្គភាពរបស់ កាក់ ឲ្យទៅធ្វើស្រែនៅព្រៃស ។ ពេលទៅដល់ទីនោះបានពីរថ្ងៃ កាក់ និង ម៉ាប់ បានទទួលការណែនាំពី សូត ទៅធ្វើសកម្មភាពរាំងស្ទះចលនាផលិតស្រូវ ។ ជាបន្តបន្ទាប់ កាក់, ផាន, អ៊ួ និង ម៉ាប់ ដើរនិយាយបំផុសបំផុលក្នុងជួរយុទ្ធជនឲ្យអស់ជំនឿលើបដិវត្តន៍ ។

មួយរយៈក្រោយមក ថា បានបើកការប្រជុំនៅក្នុងវិហារវត្តព្រៃសជាមួយ កាក់, អ៊ួ, ផាន និង ម៉ាប់ ដាក់ផែនការថ្មីនិងពិភាក្សាពីផែនការរបស់ សុន និង ឈឹន ដែលកំណត់ឲ្យយុទ្ធជននូវរបបអង្ករមួយកំប៉ុងក្នុងមួយថ្ងៃ ដើម្បីឲ្យយុទ្ធជនអស់កម្លាំង និងមើលបដិវត្តន៍ក្នុងផ្លូវអវិជ្ជមាន ។ ចំពោះផែនការថ្មីដែលត្រូវយកមកអនុវត្តគឺ ១) បំផុសពីការលំបាកធ្វើការធ្ងន់និងស៊ីមិនឆ្អែតក្នុងបដិវត្តន៍ ២) បំផុសឲ្យយុទ្ធជនមានគំនិតអាត្មានិយម ដើរលួចម្ហូបអាហារនិងបេះបោចផ្លែឈើរបស់កងទ័ពនិរតីដែលមានទីតាំងនៅក្បែរនោះ និង៣) ជំរុញឲ្យធ្វើសកម្មភាពបំផ្លាញបន្ថែមទៀត ។

ក្រោយពីទទួលភារកិច្ច កាក់, ថន និង គុល តែងនាំគ្នាលួចបេះត្របែកនិងដកដំឡូងពួកទ័ពនិរតីជាញឹកញាប់ដើម្បីបង្កទំនាស់ជាមួយកងទ័ពនិរតី ។ ជាលទ្ធផលកងទ័ពនិរតីខឹងសម្បានិងផ្តាច់ការទាក់ទងជាមួយអង្គភាពយុទ្ធជនដែលមកពីភ្នំពេញ ។ ក្រៅពីនេះ អ្នកទាំងបីបំផុសឲ្យយុទ្ធជនរើសគ្រោតទុំយកទៅដុតហូបឲ្យខុសពីវិន័យកងទ័ពនិងបង្កភាពអនាធិបតេយ្យនៅក្នុងជួរកងទ័ព ។

នៅខែកញ្ញា ឆ្នាំ១៩៧៥ អង្គការស្នើសុំយុទ្ធជនពីវរសេនាតូច១២៧ដើម្បីទៅធ្វើការនៅមន្ទីរសន្តិបាលនៅភ្នំពេញ ។ តាមការណែនាំរបស់ សុន, សូត ចាត់តាំង កាក់ និងយុទ្ធជនពីរនាក់ឈ្មោះ នី និង រ៉ា ឲ្យទៅបង្កប់ខ្លួននៅក្នុងមន្ទីរ ។ នៅថ្ងៃបន្ទាប់ កាក់, នី និង រ៉ា បានទៅបង្កប់ខ្លួនស៊ីរូងផ្ទៃក្នុង ធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍នៅគ្រប់កន្លែង ។ ក្រោយមក កាក់,នី និង រ៉ា ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើកងការពារនៅមន្ទីរស-២១ ។ អ្នកទាំងបីនៅក្នុងក្រុមជាមួយគ្នា និងមាន សារឿន ជាមេក្រុម ។

រយៈពេលមួយខែដំបូងអ្នកទាំងបីមិនទាន់ធ្វើសកម្មភាពនៅឡើយទេ ។ ក្រោយមក កាក់ ត្រូវ សារឿន អូសទាញឲ្យធ្វើសកម្មភាពខុសប្លែកប្រឆាំងនឹងបដិវត្តន៍ ។ ពីមួយថ្ងៃទៅមួយថ្ងៃ កាក់ កាន់តែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ សារឿន ។

ក្រោយពីស៊ើបដឹងអំពីសមាសភាពរបស់ កាក់, សារឿន ចាប់ផ្តើមអប់រំ កាក់ មិនឲ្យយកចិត្តទុកដាក់ក្នុងការងារ និងគំរាម កាក់ ឲ្យស្តាប់បញ្ជានិងសហការជាមួយខ្លួន ។ ដោយភ័យខ្លាចជាប់គុក កាក់ បានប្រាប់ពីសកម្មភាពក្បត់របស់ខ្លួនតាំងពីនៅកង១២៧ ។ សារឿន ក៏បានណែនាំ កាក់ ឲ្យស្គាល់មេដឹកនាំខ្លួនឈ្មោះ ចាន់ និងកម្លាំងនៅក្នុងក្រុមឈ្មោះ វិន និង ស្រេង ជាខ្សែទាក់ទងនៅខាងលើ ។

ពីរបីថ្ងៃក្រោយមក កាក់, នី និង រ៉ា បានទៅប្រជុំជាមួយ សារឿន, ស្រេង, ថា និង គ្រី ដើម្បីទទួលផែនការនិងសមាជិកថ្មីៗទៀត ។ ក្រោយពីទទួលផែនការហើយ កាក់, នី និង សារឿន នាំគ្នាចូលរើឃ្លាំងកងពល១១លួចយកម៉ាស៊ីនដេរនិងក្រមាយកមកចែកគ្នាប្រើប្រាស់ ។ ពេលយាម កាក់ ឆែកឆេរយុទ្ធជនកងពល១១ដែលដើរចល័តនិងហាមប្រាមមិនឲ្យអ្នកនោះដើររហេតរហូត ។ ក្រៅពីនេះ កាក់ ទុកកាំភ្លើងចោលមិនឆែកឆេរខ្មាំង ។

បន្ទាប់មក អង្គការដកអង្គភាពទៅនៅតាខ្មៅ ។ នៅទីនោះបានរយៈពេល១០ថ្ងៃ សារឿន រៀបចំប្រជុំដោយសម្ងាត់ជាមួយ កាក់, ស្រេង, ថា, គ្រី, នី និង រ៉ា ។ ស្រេង បានណែនាំឲ្យកម្លាំងដើរបង្កទំនាស់ជាមួយអង្គភាពនៅជិតខាងនិងដើរបេះបោចដំណាំប្រជាជន ។

នៅឆ្នាំ១៩៧៦ កាក់ និង គ្រី ត្រូវបានផ្លាស់មកយាមល្បាតនៅផ្សារថ្មីវិញ ក៏ប៉ុន្តែការទាក់ទងជាមួយខ្សែរបស់ខ្លួននៅដដែល ។ មេក្រុមរបស់ កាក់ ឈ្មោះ សុង លី និង សឿន ។ កាក់ ណែនាំកុមារដែលយាមល្បាតឲ្យលួចសម្រាកក្នុងពេលយាមល្បាត ។ ពេលយកអ្នកទោសទៅងូតទឹក កាក់ ធ្វើជាធ្វេសប្រហែលចាក់សោរខុសរន្ធ ។ នៅក្នុងឆ្នាំដដែលនេះ អង្គភាពការពារនៅផ្សារថ្មីបានផ្លាស់មកទួលស្វាយព្រៃ ហើយ កាក់ មកនៅក្នុងក្រុមរបស់ សឿន និង សុងលី ។ សុងលី បានណែនាំ កាក់ ឲ្យស្គាល់ខ្សែដទៃទៀត និងចាត់តាំងឲ្យបំពេញភារកិច្ចចំនួនបី ១) ពេលយាមធ្វើជាងងុយដេក ដើរបុកជញ្ជាំងឬបង្អួច ២) ណែនាំក្រុមកុមារឲ្យខ្ជិលយាម និង៣) បន្តធ្វើសកម្មភាពបំផ្លាញថែមទៀត ។

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៧៦ អង្គការបញ្ជូន កាក់ មកនៅក្នុងអង្គភាពសួរចម្លើយ ហើយពេលនោះ ថា, រ៉េត និង គ្រី ក៏មកនៅក្នុងអង្គភាពនោះដែរ ។ ក្រោយពេលមានក្រុមនិងពួកច្បាស់លាស់ហើយ កាក់ បានទទួលផែនការថ្មី គឺត្រូវធ្វើទារុណកម្មអ្នកទោសខ្លាំងៗរហូតដល់បាត់ចម្លើយ ។

កងការពារទាំងអស់ដែលនៅតាខ្មៅក្រោយមកក៏ផ្លាស់មកនៅមន្ទីរស-២១វិញ ។ កាក់ បានស្គាត់ជួប ថន ដើម្បីសួរនាំអំពីសភាពការណ៍នៅកងវរសេនាតូច១២៧ និងផែនការដែល សូត បានណែនាំ ។

ក្នុងឆ្នាំ១៩៧៧ តាមការណែនាំរបស់ ស្រេង កាក់, ថា, រ៉េត និង គ្រី បានជួបប្រជុំគ្នាពិភាក្សាអំពីសកម្មភាពបង្កទំនាស់រវាងកងការពារនិងកងសួរចម្លើយនិងអំពីការធ្វើទារុណកម្មខ្លាំងឲ្យទន់ទុរាដើម្បីកុំឲ្យផ្តល់ចម្លើយបាន ។ តាំងពីពេលនោះមក នៅពេលយកខ្មាំងទៅសួរចម្លើយ កាក់ តែងស្រែកឡូឡានិងស្តីបន្ទោសឲ្យអ្នកយាមជានិច្ច ។

ក្រោយមក អង្គការចាប់ខ្លួន ស្រេង និងកងការពារជាបន្ត

បន្ទាប់ ។ ឃើញស្ថានការណ៍ដូច្នេះ កាក់ បានបញ្ឈប់សកម្មភាពរបស់ខ្លួនមួយរយៈ ។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ អង្គការរៀបចំអង្គភាពសួរចម្លើយជាថ្មី ។ កាក់ ត្រូវបានដកមកនៅក្រុមធ្វើឯកសារវិញ ។ កាក់ ខំប្រឹងធ្វើការនិងកសាងខ្លួនឲ្យល្អដើម្បីលាក់កំបាំងសមាសភាពរបស់ខ្លួន ។ ក្រុមធ្វើឯកសាររបស់ កាក់ ទៅធ្វើឯកសារនៅផ្ទះ២៣ ។ ដោយឃើញឱកាសស្វាត់ល្អ កាក់ ចាប់ផ្តើមធ្វើសកម្មភាពឡើងវិញ ដោយណែនាំខ្មាំងឆ្លើយឲ្យពុៗ ដើម្បីឲ្យអ្នកទោសដែលនៅបន្ទប់ក្បែរនោះស្តាប់ឮនិងសរសេរចម្លើយតាម ។ កាក់ នៅតែបន្តបង្កទំនាស់ជាមួយកងការពារអំពីការដូរវេនយាមយឺត និងមិនយកធុងលាមកឲ្យខ្មាំងធ្វើឲ្យអ្នកទោសខ្លះបន្ទោរបង់ដាក់ក្នុងបន្ទប់ ។ ពេលខ្លះ កាក់ នាំអ្នកធ្វើឯកសារនិងនិយាយគ្នាលេងធ្វើឲ្យខាតពេលវេលាធ្វើការ និងធ្វេសប្រហែសឲ្យខ្មាំងធ្វើសកម្មភាពបាន ។

នៅក្នុងក្រុម កាក់ មានបែងចែកបក្ខពួកជាបី គឺពួកឯកសារ ពួកសរសេរនិងពួកអន្ទៀម ។ កាក់ ធ្វើជាមិនសហការពេលពួកសរសេរមកយកអ្នកទោសចេញនិងចូលម្តងៗ និងរអ៊ូរទាំថាពួកអន្ទៀមសួរចម្លើយមិនទាន់ច្បាស់ផងប្រគល់ខ្មាំងទៅក្រុមធ្វើឯកសារ ។

នៅយប់មួយពេលត្រឡប់មកពីធ្វើឯកសារ កាក់ បានជួបនិងសួរនាំ រ៉េត អំពីសកម្មភាពនៅក្រុមអន្ទៀម និងណែនាំ រ៉េត ឲ្យលាក់ការសម្ងាត់ឲ្យបាន ពីព្រោះថាអង្គការកំពុងតាមដានយ៉ាងហ្មត់ចត់ពីការធ្វើទារុណកម្មអ្នកទោសឲ្យទុរន់ទុរាបស្លាប់ ។

ពេលឃើញ អឿន និង ហៀង វាយនារី ម៉ែន និងរកដុតក្រដាស កាក់ បានពន្យុះបន្ថែមនិងជួយយកក្រដាសខូចៗឲ្យអ្នកទាំងពីរដុតបន្ថែម ។ លើសពីនេះ កាក់ បានចូលរួមធ្វើបាបនារី ម៉ែន ទៀតផង ។ សកម្មភាពទាំងនេះ កាក់ មិនបានរាយការណ៍ទៅអង្គការទេ ។ ពេលដឹងរឿងនេះ ដល បានសួរនាំ កាក់ ហើយ កាក់ ឆ្លើយទម្លាក់កំហុសនេះទៅកងការពារ ។ កាក់ ចាប់ផ្តើមភ័យនិងព្រួយបារម្ភខ្លាចអង្គការដឹងពីសមាសភាពរបស់ខ្លួន ក៏ប៉ុន្តែអារម្មណ៍ទាំងនោះបានរលាយបាត់ទៅវិញបន្ទាប់ពី រ៉េត អះអាងថាមិនមានរឿងអ្វីកើតឡើងទេ ។

កងទ័ពវៀតណាមវាយចូលតាមព្រំដែនប្រទេស ។ កាក់ បាននាំដំណឹងនេះមកប្រាប់អ្នកធ្វើការនៅក្នុងមន្ទីរដើម្បីឲ្យមានភាពជ្រួលច្របល់ ។ មិនយូរប៉ុន្មាន អឿន ត្រូវអង្គការចាប់ខ្លួន ។ បន្តមកទៀតអង្គការចាប់ខ្លួន ថា ហើយអំពាវនាវឲ្យយុទ្ធជនដទៃទៀតចូលសារភាព ។ កាក់ កាន់តែភិតភ័យ ព្រោះខ្លាច ថា ឆ្លើយដាក់ខ្លួន ។ ពេលសភាពការណ៍ស្ងប់ស្ងាត់បន្តិច កាក់ បានទៅជួប រ៉េត នៅក្នុងបន្ទប់សួរដើម្បីបញ្ជាក់ពីការចាប់ខ្លួន ថា ។ នៅយប់ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧៨ កាក់ ត្រូវអង្គការចាប់ខ្លួនតែម្តង ។

**អំពីក្រុមគ្រួសារ**

កាក់ មានឪពុកឈ្មោះ ជា សេន និង ម្តាយឈ្មោះ ពត មិត ។ កាក់ មានប្អូន៥នាក់ ឈ្មោះ : ១) ជា ម៉ន (ស្រី) ២) ជា ណន (ស្រី) ៣) ជា កាន (ប្រុស) ៤) ជា កន (ស្រី) ៥) ជា កឿន (ស្រី) ។

**ការចាប់ខ្លួន និង ចម្លើយសារភាព**

កាក់ ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី២៥ ខែ៣ឆ្នាំ១៩៧៨ នៅមន្ទីរស-២១ ។ ចម្លើយសារភាពរបស់ កាក់ ជាឯកសារសរសេរដោយដៃមាន១៤ទំព័រ ធ្វើនៅថ្ងៃទី២១ ខែមេសា ឆ្នាំ ១៩៧៨ ។ នៅចុងបញ្ចប់នៃចម្លើយសារភាព មានហត្ថលេខានិងស្នាមផ្តិតមេដៃរបស់ កាក់ និងមានហត្ថលេខារបស់អ្នកសួរចម្លើយឈ្មោះ ទិត ដែលចុះកាលបរិច្ឆេទ ថ្ងៃទី៩ ខែឧសភា ឆ្នាំ ១៩៧៨ ។

**ណាយ សុផារី**


## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម :

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយ : យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ៣០០៧ | ម៉ម សាន ហៅ សឿន | ស្នងការកងហា | ផែកំពង់សោម | ២៧-៣-៧៧ | ២០-៦-៧៧ |
| ៣០០៨ | ហឿង ភឿន ហៅ ភី | អនុក្រុម | ផែកំពង់សោម | ២៧-៣-៧៧ | ២០-៦-៧៧ |
| ៣០០៩ | មុំ សារឿន ហៅ វ៉ាន់ | យុទ្ធជន | ផែកំពង់សោម | ២៧-៣-៧៧ | ២០-៦-៧៧ |
| ៣០១០ | ខៀវ តឹម ហៅ សាន | យុទ្ធជន | ផែកំពង់សោម | ២៧-៣-៧៧ | ២០-៦-៧៧ |
| ៣០១១ | សន ឃន ហៅ ភា | យុទ្ធជន | ផែកំពង់សោម | ២៧-៣-៧៧ | ២០-៦-៧៧ |
| ៣០១២ | ប៉ែន សុំ ហៅ សាន | មេក្រុម | ផែកំពង់សោម | ២៧-៣-៧៧ | ២០-៦-៧៧ |
| ៣០១៣ | សឿម កាន | យុទ្ធជន | ផែកំពង់សោម | ២៧-៣-៧៧ | ២០-៦-៧៧ |
| ៣០១៤ | ម៉ៅ ប៊ុនថេន ហៅ ណូ | ប្រធានកង | ផែកំពង់សោម | ២៧-៣-៧៧ | ២០-៦-៧៧ |
| ៣០១៥ | ចាន់ ហៀន ហៅ រិន | យុទ្ធជន | ផែកំពង់សោម | ២៧-៣-៧៧ | ២០-៦-៧៧ |
| ៣០១៦ | ណៃ រាំង ហៅ រឿម | យុទ្ធជន | ផែកំពង់សោម | ៣-៤-៧៧ | ២០-៦-៧៧ |
| ៣០១៧ | ព្រុំ កួន ហៅ វ៉ុន | យុទ្ធជន | ផែកំពង់សោម | ៣-៤-៧៧ | ២០-៦-៧៧ |
| ៣០១៨ | តូប អាត ហៅ ផល | យុទ្ធជន | ផែកំពង់សោម | ៣-៤-៧៧ | ២០-៦-៧៧ |
| ៣០១៩ | ដាន នៀវ | យុទ្ធជន | ផែកំពង់សោម | ៣-៤-៧៧ | ២០-៦-៧៧ |
| ៣០២០ | ឃិន ផេង | យុទ្ធជន | ផែកំពង់សោម | ៣-៤-៧៧ | ២០-៦-៧៧ |
| ៣០២១ | ពាញ រ៉ុម ហៅ រ៉ន | យុទ្ធជន | ផែកំពង់សោម | ៣-៤-៧៧ | ២០-៦-៧៧ |
| ៣០២២ | កែវ សូត្រ ហៅ រឿន | យុទ្ធជន | ផែកំពង់សោម | ៣-៤-៧៧ | ២០-៦-៧៧ |
| ៣០២៣ | អ៊ីវ ធី ហៅ ឈី | មេក្រុម | ផែកំពង់សោម | ៣-៤-៧៧ | ២០-៦-៧៧ |
| ៣០២៤ | អ៊ុំ ស្រី ហៅ ធុង | យុទ្ធជន | ផែកំពង់សោម | ៣-៤-៧៧ | ២០-៦-៧៧ |
| ៣០២៥ | ទួន ទី ហៅ ពន | យុទ្ធជន | ផែកំពង់សោម | ៣-៤-៧៧ | ២០-៦-៧៧ |
| ៣០២៦ | សៅ ហន ហៅ សាន | កងហា | ផែកំពង់សោម | ៣-៤-៧៧ | ២០-៦-៧៧ |
| ៣០២៧ | ង៉ែត ង៉ាន | ប្រធានកង | ផែកំពង់សោម | ៣-៤-៧៧ | ២០-៦-៧៧ |
| ៣០២៨ | ទូច ហ៊ាន | អនុក្រុម | ផែកំពង់សោម | ១៩-៤-៧៧ | ២០-៦-៧៧ |
| ៣០២៩ | លាង ដុស ហៅ ភាន់ | មេក្រុម | ផែកំពង់សោម | ២៥-៤-៧៧ | ២០-៦-៧៧ |
| ៣០៣០ | ស៊ុន ហ៊ាង ហៅ ហ៊ន់ | អនុកងតូច | ផែកំពង់សោម | ២៥-៤-៧៧ | ២០-៦-៧៧ |
| ៣០៣១ | ម៉ុក គ្រេង ហៅ ត្រី | អនុក្រុម | ផែកំពង់សោម | ១៩-៤-៧៧ | ២០-៦-៧៧ |
| ៣០៣២ | រស់ ពោន | យុទ្ធជន | ផែកំពង់សោម | ?-៤-៧៧ | ២០-៦-៧៧ |
| ៣០៣៣ | មៀច ចន ហៅ ណូ | អនុកងតូច | ផែកំពង់សោម | ២៤-៤-៧៧ | ២០-៦-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ៣០៣៤ | ប៊ុន ថាន | អនុក្រុម | ផែកំពង់សោម | ២៤-៤-៧៧ | ២០-៦-៧៧ |
| ៣០៣៥ | រស់ រិន ហៅ សឿន | អនុកងតូច | ផែកំពង់សោម | ២៥-៤-៧៧ | ២០-៦-៧៧ |
| ៣០៣៦ | ហេង ម៉េង ហៅ វី | ប្រធានកង | ផែកំពង់សោម | ២៥-៤-៧៧ | ២០-៦-៧៧ |
| ៣០៣៧ | ស៊ឹម ពាង ហៅ សែស | មេក្រុម | ផែកំពង់សោម | ២៥-៤-៧៧ | ២០-៦-៧៧ |
| ៣០៣៨ | ញ៉ែម ដេន ហៅ សារ៉េន | យុទ្ធជន | ផែកំពង់សោម | ១៩-៤-៧៧ | ២០-៦-៧៧ |
| ៣០៣៩ | តាន់ យុត ហៅ យឹម | អនុកងតូច | ផែកំពង់សោម | ៤-៥-៧៧ | ២០-៦-៧៧ |
| ៣០៤០ | ប៉ែន ដាន ហៅ សែន | អនុកងតូច | ផែកំពង់សោម | ៤-៥-៧៧ | ២០-៦-៧៧ |
| ៣០៤១ | ធូ ស្រេង ហៅ សាត | អនុក្រុម | ផែកំពង់សោម | ៤-៥-៧៧ | ២០-៦-៧៧ |
| ៣០៤២ | កី ឡេក ហៅ សារុន | យុទ្ធជន | ផែកំពង់សោម | ៤-៥-៧៧ | ២០-៦-៧៧ |
| ៣០៤៣ | ប៊ិច តឿន ហៅ វើង | ប្រធានកង | ផែកំពង់សោម | ៤-៥-៧៧ | ២០-៦-៧៧ |
| ៣០៤៤ | សំ ដួង ហៅ ចេក | អនុកងតូច | ផែកំពង់សោម | ៤-៥-៧៧ | ២០-៦-៧៧ |
| ៣០៤៥ | ចាន់ ជឿង ហៅ ណា | អនុកងតូច | ផែកំពង់សោម | ៤-៥-៧៧ | ២០-៦-៧៧ |
| ៣០៤៦ | ជិន ខេង ហៅ រើន | អនុក្រុម | ផែកំពង់សោម | ៤-៥-៧៧ | ២០-៦-៧៧ |
| ៣០៤៧ | ម៉ៅ ណាត | អនុក្រុម | ផែកំពង់សោម | ៤-៥-៧៧ | ២០-៦-៧៧ |
| ៣០៤៨ | សំ ស្រ៊ុន ហៅ ហាន | យុទ្ធជន | ផែកំពង់សោម | ៤-៥-៧៧ | ២០-៦-៧៧ |
| ៣០៤៩ | ណៃ លុន ហៅ នូ | យុទ្ធជន | ដឹកជញ្ជូនជើងទឹក | ២១-៥-៧៧ | ២០-៦-៧៧ |
| ៣០៥០ | គឹម យី ហៅ អឿន | យុទ្ធជន | ដឹកជញ្ជូនជើងទឹក | ២១-៥-៧៧ | ២០-៦-៧៧ |
| ៣០៥១ | ឡាច ហ៊ិត ហៅ ហន | យុទ្ធជន | ដឹកជញ្ជូនជើងទឹក | ៦-៤-៧៧ | ២០-៦-៧៧ |
| ៣០៥២ | កែវ សែត | មេក្រុម | ដឹកជញ្ជូនជើងទឹក | ៦-៤-៧៧ | ២០-៦-៧៧ |
| ៣០៥៣ | ខៀវ ម៉ុន ហៅ ប៉ុន | អនុក្រុម | ដឹកជញ្ជូនជើងទឹក | ៦-៤-៧៧ | ២០-៦-៧៧ |
| ៣០៥៤ | អុល អាត | យុទ្ធជន | ដឹកជញ្ជូនជើងទឹក | ៦-៤-៧៧ | ២០-៦-៧៧ |
| ៣០៥៥ | ជា នី | នីរសារ | ដឹកជញ្ជូនជើងទឹក | ៦-៤-៧៧ | ២០-៦-៧៧ |
| ៣០៥៦ | ម៉ៅ ស៊ុន ហៅ តី | យុទ្ធជន | ដឹកជញ្ជូនជើងទឹក | ៦-៤-៧៧ | ២០-៦-៧៧ |
| ៣០៥៧ | អុច ឈឿន | យុទ្ធជន | ដឹកជញ្ជូនជើងទឹក | ៦-៤-៧៧ | ២០-៦-៧៧ |
| ៣០៥៨ | គឹម សាំង ហៅ ទ្រី | កម្មករចាស់ | ដឹកជញ្ជូនជើងទឹក | ១៤-៤-៧៧ | ២០-៦-៧៧ |
| ៣០៥៩ | ង៉ែត ហៃ | យុទ្ធជន | ដឹកជញ្ជូនជើងទឹក | ៤-៤-៧៧ | ២០-៦-៧៧ |
| ៣០៦០ | ហាក់ យ៉ាន ហៅ ឆាំ | ជំនួយការ | ដឹកជញ្ជូនជើងទឹក | ៤-៤-៧៧ | ២០-៦-៧៧ |
| ៣០៦១ | ស្រី សុផាត | មេក្រុម | ដឹកជញ្ជូនជើងទឹក | ៤-៤-៧៧ | ២០-៦-៧៧ |
| ៣០៦២ | ឃួន ពៅ ហៅ ពុំ | យុទ្ធជន | ដឹកជញ្ជូនជើងទឹក | ១៣-៥-៧៧ | ២០-៦-៧៧ |
| ៣០៦៣ | កង ហយ | យុទ្ធជន | ដឹកជញ្ជូនជើងទឹក | ១៣-៥-៧៧ | ២០-៦-៧៧ |
| ៣០៦៤ | សន ហ៊ី ហៅ រិត | យុទ្ធជន | ដឹកជញ្ជូនជើងទឹក | ១៣-៥-៧៧ | ២០-៦-៧៧ |

(នៅមានត)

# គុកខ្មែរក្រហម

## ខេត្តកំពង់ធំ

## ស្រុកបារាយណ៍

### ១) សន្តិសុខវត្តបារាយណ៍ជាន់ដែក

នៅឆ្នាំ១៩៧៥ វត្តបារាយណ៍ជាន់ដែកត្រូវខ្មែរក្រហមប្រើប្រាស់ធ្វើជាមន្ទីរសន្តិសុខនិងជាទីតាំងសម្លាប់អ្នកទោស ។ ព្រះវិហារនិងសាលាបាលីក្នុងវត្តបារាយណ៍ជាន់ដែកគឺជាមន្ទីរឃុំឃាំង ហើយបរិវេណផ្សេងទៀតជាកន្លែងសម្លាប់ ។ អ្នកទោសទាំងអស់ដែលជាប់ឃុំឃាំងនៅក្នុងព្រះវិហារមិនត្រូវបានដាក់ខ្នោះទេ ដោយគ្រាន់តែចាក់សោទ្វារពីក្រៅ ដើម្បីការពារកុំឲ្យអ្នកទោសរត់ចេញប៉ុណ្ណោះ ។ ជនរងគ្រោះដែលជាប់នៅក្នុងមន្ទីរសន្តិសុខនេះ ជាប្រភេទអ្នកទោសដែលជាប់ខ្សែយួន ខ្សែចាម ខ្សែចិន អ្នក១៧មេសា អ្នកជាប់និន្នាការពីសង្គម និងមួយចំនួនទៀតជាអ្នកមូលដ្ឋាន ។ ខ្មែរក្រហមមិនឲ្យអ្នកទោសចេញទៅធ្វើពលកម្មខាងក្រៅឡើយ ។ គិន សាន អាយុ៥១ឆ្នាំ រស់នៅភូមិត្រស់ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ បាននិយាយថា ចាប់ពីដើមឆ្នាំរហូតដល់ចុងឆ្នាំ១៩៧៨ ការសម្លាប់បានកើនឡើងមួយទ្វេជាពីរ បើប្រៀបទៅនឹងការសម្លាប់នៅឆ្នាំមុនៗ ។ ទីតាំងសម្លាប់ដែលស្ថិតនៅខាងមុខព្រះវិហារមានរណ្តៅសរុបចំនួនពី១៥០ទៅ ២០០រណ្តៅ ។

ក្រោយឆ្នាំ១៩៧៩ សាកសពស្ទើរតែគ្រប់រណ្តៅត្រូវបានគាស់ឡើងនិងប្រមូលអដ្ឋិធាតុមកតម្កល់ទុកក្នុងបូជនីយដ្ឋានមួយដែលនៅក្បែរនោះ ។

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ វត្តបារាយណ៍ជាន់ដែកស្ថិតនៅក្នុងភូមិត្រស់ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

**ស្ថិតិ** ៖ នៅឆ្នាំ១៩៧៥ មន្ទីរសន្តិសុខនៅក្នុងបរិវេណវត្តបារាយណ៍ជាន់ដែកនេះបង្កើតឡើងដើម្បីឃុំឃាំងប្រជាជន១៧មេសា អ្នកជាប់ខ្សែចិន ចាម យួន និងប្រជាជនមូលដ្ឋានមួយចំនួន ។ អ្នកទោសប្រមាណពី១៥.០០០ទៅ២០.០០០នាក់ត្រូវបានសម្លាប់ដាក់ក្នុងរណ្តៅចំនួនពី១៥០ទៅ២០០រណ្តៅ



សន្តិសុខវត្តបារាយណ៍ជាន់ដែក ភូមិត្រស់ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ

ដែលអ្នកទោសគាស់ឃើញនៅពីមុខព្រះវិហារវត្តបារាយណ៍ជាន់ដែកនេះ ។

### ២) មន្ទីរសន្តិសុខវត្តទួល ហៅវត្តពោធិ៍រាម

មន្ទីរសន្តិសុខវត្តទួលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៧ ។ ខ្មែរក្រហមបង្កើតមន្ទីរនេះឡើងនៅក្នុងបរិវេណវត្តទួលនេះ និងជ្រើសរើសយកសាលាបាលី ព្រះវិហារ សាលារៀនដែលស្ថិតនៅក្នុងបរិវេណវត្តធ្វើជាកន្លែងឃុំឃាំងអ្នកទោស ។ កម្មាភិបាលនារីខ្មែរក្រហមឈ្មោះ ភឿក ជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខទាំងមូល ។ ភឿក ត្រូវបានប្រជាជនកាត់ទោសដោយសម្លាប់ចោលនៅក្រោយថ្ងៃ៧មករា ឆ្នាំ១៩៧៩ ។ ស្រី ថាន់ អាយុ៣៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ គឺជាអតីតអ្នកទោសក្នុងមន្ទីរសន្តិសុខវត្តទួល ។ គាត់ត្រូវបានចោទប្រកាន់ពីបទរស់នៅជាមួយឪពុកដែលខ្មែរក្រហម

ចោទថាជាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ។ ឪពុករបស់ ថាន់ ត្រូវកងឈ្លបសម្លាប់ ចំណែក ថាន់ បានលួចរត់ចេញពីមន្ទីរសន្តិសុខមកបន្តរស់នៅជាមួយប្រជាជននៅតាមសហករណ៍ ។

ជនរងគ្រោះដែលជាប់នៅក្នុងមន្ទីរសន្តិសុខវត្តទួលជាប្រជាជន១៧ មេសា និងប្រជាជនមូលដ្ឋានដែលប្រព្រឹត្តល្មើសនឹងមាគ៌ាបដិវត្តន៍ ។ ប្រជាជនទាំងនេះត្រូវខ្មែរក្រហមប្រមូលមកពីគ្រប់សហករណ៍ កងតូច កងធំ និងពីការដ្ឋាននានាទូទាំងឃុំ ។ អ្នកទោសភាគច្រើន ត្រូវបានសម្លាប់នៅខាងមុខវត្តប៉ែកខាងជើងឆៀងខាងកើត រួចទម្លាក់ចូលទៅក្នុងអណ្តូងទឹកចំនួន៤ ។ អណ្តូងទឹកនីមួយៗមានទំហំមុខកាត់ ២,៥០ម៉ែត្រ និងជម្រៅ១១ម៉ែត្រ ។


មន្ទីរសន្តិសុខវត្តទួលហៅវត្តពោធិ៍រាម ភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ

នៅក្រោយឆ្នាំ១៩៧៩ អដ្ឋិធាតុជនរងគ្រោះនៅក្នុងអណ្តូងទាំងប៉ុន្មានត្រូវបានគាស់ឡើងដើម្បីយកអដ្ឋិធាតុទៅតម្កល់ទុកនៅក្នុងបូជនីយដ្ឋានមួយដែលសាងសង់ឡើងក្នុងបរិវេណវត្តនេះ ។ តាមរបាយការណ៍របស់គណៈកម្មការវត្តទួលបានឲ្យដឹងថា ចំនួនជនរងគ្រោះមានប្រហែល៦០០នាក់ ។

**ទិន្នន័យសង្ខេប**

**ទីតាំង** : វត្តទួលហៅវត្តពោធិ៍រាមស្ថិតនៅក្នុងភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

**ស្ថិតិ** : នៅឆ្នាំ១៩៧៧ មន្ទីរសន្តិសុខមួយត្រូវបានបង្កើតឡើងនៅក្នុងបរិវេណវត្តទួលហៅវត្តពោធិ៍រាម ។ សាលាបាលី ព្រះវិហារ និងសាលារៀននៅក្នុងបរិវេណវត្តទួលត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរឃុំឃាំងអ្នកទោសដែលចាប់យកមកពីគ្រប់សហករណ៍ កងតូច កងធំ និងពីការដ្ឋាននានាក្នុងទូទាំងឃុំ ។

## ស្រុកកំពង់ស្វាយ

### ៣) មន្ទីរសន្តិសុខវត្តស្រដែ

វត្តនេះត្រូវខ្មែរក្រហមជ្រើសរើសយកធ្វើជាមន្ទីរសន្តិសុខនៅឆ្នាំ១៩៧៥ ។ មន្ទីរសន្តិសុខនេះគ្រប់គ្រងដោយសមមិត្ត គីន ជាប្រធាន និង ជន ជាអនុប្រធាន ។ ព្រះវិហារគឺជាទីតាំងសំខាន់សម្រាប់ឃុំឃាំងនិងសួរចម្លើយអ្នកទោស ។ ជនរងគ្រោះដែលជាប់នៅក្នុងមន្ទីរឃុំឃាំងនេះ ច្រើនជាប្រជាជនមូលដ្ឋានដែលមានបងប្អូនជាប់និន្នាការនយោបាយពីសង្គមមុន អ្នកខុសសីលធម៌ អ្នកធ្វើការបម្រើបដិវត្តន៍មិនបានល្អ អ្នកឈឺច្រើន អ្នកនិយាយស្តីផ្តេសផ្តាស អ្នកដើរហើរសេរី និងអ្នកជម្លៀសមកពីទីក្រុងភ្នំពេញ ។

ណុច អ៊ុន អាយុ៤៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិស្រដែ ឃុំត្បែង ស្រុកកំពង់ស្វាយ បាននិយាយថា អ្នកទោសត្រូវកងឈ្លបដឹកតាមរថយន្តខ្លះ រទេះគោខ្លះ និងចងបណ្តើរខ្លះចូលមកកាន់មន្ទីរសន្តិសុខវត្តស្រដែ ។ បន្ទាប់ពីសួរចម្លើយនៅក្រោមដើមចំបក់ពីរដើមរួច អ្នកទោសត្រូវខ្មែរក្រហមនាំយកទៅសម្លាប់នៅព្រៃឃ្មាំងមឿង (ចម្ងាយពីមន្ទីរសន្តិសុខប្រហែល១៧០ម៉ែត្រខាងមុខវត្តស្រដែ) និងនៅព្រៃដងវែង ។ ឃឹម ជឿង អាយុ៤៦ឆ្នាំ រស់នៅភូមិកំពង់ឈើទាល ឃុំសំបូរ ស្រុកប្រាសាទសំបូរ និងជាអតីតប្រធានកងសន្តិសុខប្រចាំនៅវត្តស្រដែកាលពីជំនាន់ខ្មែរក្រហម បានបញ្ជាក់ថា ការសម្លាប់អ្នកទោសបានផ្តើមឡើងជាហូរហែតាំងពីពេលបង្កើតមន្ទីរសន្តិសុខនេះម្ល៉េះ ប៉ុន្តែការសម្លាប់បានកើនឡើងយ៉ាងច្រើនលើសលប់នៅក្នុងឆ្នាំ១៩៧៨ ។

**ទិន្នន័យសង្ខេប**

**ទីតាំង** : វត្តស្រដែ ស្ថិតនៅក្នុងភូមិស្រដែ ឃុំត្បែង ស្រុក

កំពង់ស្វាយ ខេត្តកំពង់ធំ ។

**ស្ថិតិ** ៖ វត្តស្រង៉ែបានក្លាយទៅជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៥ ។ ព្រះវិហារជាទីតាំងសំខាន់សម្រាប់ឃុំឃាំងអ្នកទោសដែលចាប់មកពីកន្លែងនានាក្នុងខេត្តកំពង់ធំ និងប្រជាជនមកពីទីក្រុងភ្នំពេញ ។ នៅក្នុងឆ្នាំ១៩៧៨ អ្នកទោសត្រូវបានសម្លាប់ផ្តាច់ពូជនៅទីតាំងសម្លាប់ចំនួនពីរគឺ ព្រៃឃ្លាំងមឿង និងព្រៃដងវែង ។

## ស្រុកប្រាសាទសំបូរ

### ៤) មន្ទីរសន្តិសុខព្រៃអ្នកតាចាស់ស្រុក

កាលពីជំនាន់ខ្មែរក្រហមនៅភូមិច្រម៉ាស់ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ មានទីតាំងសម្លាប់មួយនិងមន្ទីរសន្តិសុខមួយដែលបង្កើតឡើងដោយខ្មែរក្រហមនៅក្នុងព្រៃអ្នកតាចាស់ស្រុក ដោយមានសមមិត្ត លីវ ជាប្រធាន និងសមមិត្ត ឡៃ ជាអនុប្រធាន ។ រោងធំមួយដែលមានទំហំទទឹង៧ម៉ែត្រនិងបណ្តោយ៣០ម៉ែត្រ ត្រូវបានសាងសង់ឡើងសម្រាប់ឃុំឃាំងអ្នកទោសជាទាហាន មន្ត្រីរដ្ឋការស៊ីវិលនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជន១៧មេសា និងប្រជាជនមូលដ្ឋានដែលបានធ្វើខុសនឹងវិន័យអង្គការ ។ អ្នកទាំងនេះត្រូវខ្មែរក្រហមប្រមូលមកពីភូមិឃុំនានាកាលពីឆ្នាំ១៩៧៧ ។ អ្នកទោសត្រូវកងឈ្លបដាក់ជា៣ជួរក្នុងរោងតែមួយ ដែលក្នុងមួយជួរៗមានពី៣០ទៅ១០០នាក់ ។ ក្រោយមកអ្នកទោសទាំងនេះត្រូវបានសម្លាប់ចោល ។ អ្នកទោសដែលជាប្រជាជន១៧មេសា ទាហាន និងមន្ត្រីរដ្ឋការជំនាន់សាធារណរដ្ឋខ្មែរ ត្រូវកងឈ្លបនាំយកទៅសម្លាប់មុនគេ ហើយប្រជាជនមូលដ្ឋានដែលអប់រំមិនបាននិងអ្នកដែលធ្វើសកម្មភាពប៉ះពាល់ដល់មាគ៌ាអង្គការដូចជា ខុសសីលធម៌ ខ្ជិលច្រអូសនឹងការងារ ឬឈឺច្រើន... ។ល ។ ត្រូវនាំយកទៅសម្លាប់នៅពេលក្រោយ ។ សូ ហង់ បានឃើញកងឈ្លបបណ្តើរអ្នកទោសទាំងខ្សែយកទៅសម្លាប់ចោល ដែលក្នុងមួយខ្សែៗមានអ្នកទោសពី១០ទៅ១២នាក់ ។

ដួន ជឿន អាយុ៣៦ឆ្នាំ សព្វថ្ងៃជាប្រជាជនរស់នៅភូមិច្រម៉ាស់ ឃុំសំបូរ ស្រុកប្រាសាទសំបូរ និងជាអតីតនីសារនៅមន្ទីរសន្តិសុខព្រៃអ្នកតាចាស់ស្រុក ។ ជឿន បាននិយាយថា គាត់បានទទួលបញ្ជាផ្ទាល់ពីប្រធានសន្តិសុខឲ្យស្រង់ឈ្មោះនិងចាប់ខ្លួនប្រជាជនម្តងពី១៥ទៅ២០នាក់ពីកន្លែងផ្សេងៗមកដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខព្រៃអ្នកតាចាស់ស្រុក ។ ក្នុងរវាងមួយឬពីរសប្តាហ៍ម្តង ជឿន បានទទួលបញ្ជាឲ្យទៅចាប់ប្រជាជនមកដាក់ឃុំឃាំងម្តងទៀត ។ ជឿន ធ្វើបែបនេះរហូតដល់មន្ទីរសន្តិសុខត្រូវដួលរលំ ។ ក្នុងការសួរចម្លើយអ្នកទោសគឺត្រូវបានប្រព្រឹត្តតាមវិធីធ្វើទារុណកម្មប្លែកៗនិងសាហាវបំផុតដូចជា វាយដែកគោលទម្លុះលើប្រអប់ដៃអ្នកទោសភ្ជាប់នឹងតុដើម្បីបង្ខំឲ្យឆ្លើយសារភាព ។ បន្ទាប់ពីទទួលបានចម្លើយ អ្នកទោសត្រូវបាននាំយកទៅសម្លាប់ ។ ការសម្លាប់បានកើនឡើងយ៉ាងខ្លាំងក្លា ចាប់ពីចុងឆ្នាំ១៩៧៧ រហូតដល់ចុងឆ្នាំ១៩៧៨ ។ នៅឆ្នាំ១៩៧៩ មន្ទីរសន្តិសុខព្រៃអ្នកតាចាស់ស្រុកបានបញ្ចប់អត្ថិភាពរបស់ខ្លួនបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ។


សូ ហង់ មន្ទីរសន្តិសុខព្រៃអ្នកតាចាស់ស្រុក ខេត្តកំពង់ធំ

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ មន្ទីរសន្តិសុខព្រៃអ្នកតាចាស់ស្រុកស្ថិតនៅក្នុងភូមិច្រម៉ាស់ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។

**ស្ថិតិ** ៖ ព្រៃអ្នកតាចាស់ស្រុកជាមន្ទីរសន្តិសុខនិងជាកន្លែងសម្លាប់កាលពីជំនាន់ខ្មែរក្រហម ។ អ្នកទោសរាប់រយនាក់ត្រូវបានសម្លាប់ ហើយខ្លះស្លាប់នៅ

នឹងទីតាំងនេះបន្ទាប់ពីសួរចម្លើយរួច ។ សមមិត្ត លីវ ជាប្រធានមន្ទីរសន្តិសុខនៅព្រៃអ្នកតាចាស់ស្រុក (បច្ចុប្បន្នស្លាប់) និងសមមិត្ត ឡៃ ជាអនុប្រធាន ។ ពីឆ្នាំ១៩៧៧ដល់ចុងឆ្នាំ១៩៧៨ ការសម្លាប់បានកើនឡើងលើសពីធម្មតា ។

## ស្រុកសណ្តាន់

### ៥) មន្ទីរសន្តិសុខព្រៃកន្ទែង

ព្រៃស្រោងធំមួយស្ថិតនៅក្នុងភូមិព្រៃកន្ទែង ឃុំសុចិត្រ ស្រុកសណ្តាន់ បានក្លាយទៅជាបរិវេណមន្ទីរសន្តិសុខស្រុកសណ្តាន់ តាំងពីឆ្នាំ១៩៧០ ។ មន្ទីរសន្តិសុខនេះមានតួនាទីឃុំឃាំងប្រជាជនមូលដ្ឋានដែលរឹងរូសមិនព្រមបញ្ជូនកូនចៅឲ្យចូលបម្រើក្នុងជួរបដិវត្តន៍កាលពីឆ្នាំ១៩៧១ ។ សៅ យឿន អតីតប្រធានធម្មការស្រុកសណ្តាន់បានរំឭកថា នៅឆ្នាំ១៩៧០ចលនាឃោសនាមួយបានកើតឡើងនៅក្នុងស្រុកសណ្តាន់ ។ ហង់ បានដើរឃោសនាដោយអះអាងខ្លួនឯងថា ជាអ្នកតស៊ូដើម្បីទាមទារឲ្យសម្តេចឪចូលស្រុកវិញ ។ មិនយូរប៉ុន្មាន ប្រជាជនភាគច្រើនបានបែរទៅចូលខាងបក្សរបស់សមមិត្ត ហង់ ដែលមានចំនួនស្មើនឹង៩០ភាគរយនៃប្រជាជនដែលរស់នៅក្នុងស្រុកសណ្តាន់ទាំងមូល ។ ដោយសារតែមានកម្លាំងល្មមគ្រប់គ្រាន់ ទើបសមមិត្ត ហង់ ចាប់ផ្តើមអនុវត្តនយោបាយកៀបសង្កត់ប្រជាជនដែលមិនទាន់សម្រេចចិត្តចូលធ្វើបដិវត្តន៍ ។ សៅ យឿន និយាយបន្តថា មេភូមិ មេឃុំមួយចំនួនត្រូវកម្លាំងរបស់ ហង់ ធ្វើទារុណកម្មរហូតដល់ស្លាប់ ដោយសារតែឃាត់ឃាំងប្រជាជនមិនឲ្យចូលបម្រើបដិវត្តន៍ ។ ភាពចលាចលបានកើតមាននៅក្នុងទូទាំងស្រុកសណ្តាន់ ។ ការផ្លាស់ប្តូរសមាសភាពថ្នាក់ដឹកនាំឃុំតែងតែកើតមានជារឿយៗ ។ សមមិត្ត ហង់ ត្រូវជំនួសដោយសមមិត្ត អ៊ុន ហើយក្រោយមកមានសមមិត្ត ប៉ាន់, សមមិត្ត ណៃ និង សមមិត្ត គៀន ចូលមកកាន់កាប់មន្ទីរសន្តិសុខព្រៃកន្ទែងនេះជាបន្តបន្ទាប់ ។

ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ឈ្លើយសឹករបស់ លន់ នល់ ជាច្រើននាក់ដែលចាប់បាននិងបញ្ជូនមកមន្ទីរសន្តិសុខព្រៃកន្ទែងត្រូវកងឈ្លបខ្មែរក្រហមដឹកយកទៅសម្លាប់ចោលនៅបឹងធំ ស្ថិតនៅក្នុងភូមិស្រែចង់ ឃុំសណ្តាន់ ។ ចំណែកខាងខ្មែរក្រហមដែល សៅ យឿន អះអាងថា បានដើរលឿនមួយជំហានមុនអ្នកស្នេហាជាតិខាងសម្តេចឪនោះ បានប្រមែប្រមូលខ្មែរស្រឡាយនិងក្រុមញាតិសន្តានរបស់ ហ៊ូ យន់ និង ហ៊ូ នឹម យកទៅសម្លាប់ទាំងអស់នៅក្នុងព្រៃកន្ទែង ។ តាំងពីឆ្នាំ១៩៧៦មក មន្ទីរសន្តិសុខនេះបានទទួលអ្នកចំណូលថ្មីថែមទៀត ដូចជាប្រជាជនជម្លៀស(១៧មេសា)មកពីទីក្រុងភ្នំពេញ ទីរួមខេត្តកំពង់ធំ ប្រជាជនមូលដ្ឋាន កម្មាភិបាលខ្មែរក្រហមដែលប្រឆាំងនឹងបញ្ជារបស់អង្គការបដិវត្តន៍ជាដើម ។ អួង កាំង អាយុ៦៦ឆ្នាំ និយាយថា ប្រជាជន១៧មេសាទាំងអស់ដែលអង្គការបានយកទៅផ្ញើតាមសហករណ៍នានាក្នុងស្រុកសណ្តាន់ បានត្រូវកងឈ្លបក្មេងៗរបស់ខ្មែរក្រហមចាប់មកឃុំឃាំងនៅព្រៃកន្ទែងស្ទើររាល់


មន្ទីរសន្តិសុខព្រៃកន្ទែង ភូមិព្រៃកន្ទែង ឃុំសុចិត្រ ស្រុកសណ្តាន់ ខេត្តកំពង់ធំ

ថ្ងៃរហូតដល់អស់ពីសហករណ៍ ។ ទៃ អួន អាយុ ៥៦ឆ្នាំបានប្រាប់ថា គាត់បានឃើញខ្មែរក្រហមបណ្តើរមនុស្សចូលក្នុងមន្ទីរឃុំឃាំងព្រៃកន្ទែងនេះនៅពេលគាត់កំពុងធ្វើស្នោត ។ ចំណែកប្រជាជនមូលដ្ឋានដែលមានកំហុស ក៏ត្រូវបញ្ជូនមកមន្ទីរសន្តិសុខនេះដែរ ។ អួន និយាយថា ជួនកាលគាត់ស្គាល់ច្បាស់ថា ជាប្រជាជនរស់នៅភូមិទឹកម្លាង ឃុំសណ្តាន់ ហើយត្រូវខ្មែរក្រហមប្រដាប់ដោយអាវុធចងស្លាបសេកបណ្តើរមកកាន់មន្ទីរឃុំឃាំងនេះ ។

មន្ទីរសន្តិសុខព្រៃកន្ទែងហ៊ុមព័ទ្ធដោយរបងលួសបន្លាក្រាស់ដែលអ្នកទោសមិនងាយនឹងលួចរត់ចេញបានឡើយ ។ អួង កាំង និយាយថា គាត់ឃើញលួសបន្លាជាច្រើនជាន់ព័ទ្ធជុំវិញមន្ទីរ

និងមានផ្ទះសម្រាប់កងសន្តិសុខស្នាក់នៅសង់ហូរហែជាប់របងមន្ទីរសន្តិសុខនោះទៀតផង នៅពេលដែលគាត់ដឹកថ្នាំអង់ទ្រីនទៅកាន់ផ្ទះសន្តិសុខម្នាក់ដែលស្ថិតនៅក្បែរមន្ទីរសន្តិសុខធំ ។

អួង កាំង និង ទៃ អួន ប្រាប់ថា ស្រស់ ជាគ្រូបង្រៀននៅសាលាបឋមសិក្សាតាំងក្រសោ ភូមិស្រឡៅ (ចារពៅ) ឃុំផន ស្រុកសណ្តាន់ ខេត្តកំពង់ធំ ឡៃ រស់នៅភូមិបាជ័យ ឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ និង ជា សុខ រស់នៅភូមិអន្លង់ស្វែង ឃុំឈូក ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ គឺជាអតីតកងសន្តិសុខប្រចាំនៅមន្ទីរសន្តិសុខព្រៃកន្ទែង ។

រហូតមកដល់បច្ចុប្បន្នអតីតមន្ទីរសន្តិសុខព្រៃកន្ទែង គឺជាព្រៃស្រោងគ្មានមនុស្សរស់នៅដដែល ។ ប៉ុន្តែ នៅបរិវេណខាងក្រៅអតីតមន្ទីរនេះមានផ្ទះបី-បួនខ្នងដែលប្រជាជនទើបតែសង់ឡើងសម្រាប់ចាំចម្ការ ។ អតីតកន្លែងសួរចម្លើយដែលជាផ្នែកមួយនៃមន្ទីរសន្តិសុខព្រៃកន្ទែងត្រូវបានរុះរើកាលពីពេលថ្មីៗនេះដោយសារឈើសម្រាប់ព្យួរ-កអ្នកទោសក្នុងពេលសួរចម្លើយពុកផុយអស់ ។ ដើមស្វាយមួយដើមត្រូវបានម្ចាស់ដីឈ្មោះ អួង កាំង ដាំនៅចំកន្លែងព្យួរ-កនេះ ។



**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ មន្ទីរសន្តិសុខព្រៃកន្ទែង ស្ថិតនៅក្នុងភូមិព្រៃកន្ទែង ឃុំសុចិត្រ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

**ស្ថិតិ** ៖ ព្រៃស្រោងមួយកន្លែងដែលមានឈ្មោះថាព្រៃកន្ទែង ជាអតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ។ អ្នកទោសជាច្រើនត្រូវបានសម្លាប់បន្ទាប់ពីសួរចម្លើយ ។ មន្ទីរសន្តិសុខសាងសង់ឡើងយ៉ាងប្រយ័ត្នប្រយែងបំផុតតាំងពីឆ្នាំ១៩៧០រហូតមកដល់ចុងឆ្នាំ១៩៧៨ ដោយមានរបងឈើនិងហ៊ុមពទ្ធ័ពីក្រៅដោយបន្លាលួសថែមមួយជាន់ទៀត ។ គោលបំណងដំបូងក្នុងការបង្កើតមន្ទីរសន្តិសុខនេះគឺក្នុងន័យអប់រំណែនាំប្រជាជនណាដែលមិនទាន់ជ្រះស្រឡះក្នុងការចុះឈ្មោះចូលបម្រើបដិវត្តន៍ដើម្បីនាំសម្តេចឪចូលស្រុកវិញ ។ ប៉ុន្តែចាប់ពីថ្ងៃជ័យជម្នះទី១៧ ខែមេសា ឆ្នាំ១៩៧៥ មន្ទីរសន្តិសុខព្រៃកន្ទែងបានត្រូវខ្មែរក្រហមកែប្រែរចនាសម្ព័ន្ធទាំងស្រុង ។

## ស្រុកសន្ទុក

### ៦) មន្ទីរសន្តិសុខអកឆក

មន្ទីរសន្តិសុខអកឆក មានសង់រោងធំមួយនៅលើទួលខ្ពស់មួយទំហំទទឹង៦ម៉ែត្រនិងបណ្តោយ៤០ម៉ែត្រ ។ ខ្មែរក្រហមបានបញ្ជូនអ្នកទោសមកកាន់មន្ទីរសន្តិសុខអកឆកនៅគ្រប់ពេលដែលអ្នកទោសមុនៗត្រូវនាំយកទៅសម្លាប់ចោលនៅទីតាំងទួលមុំធ្លក ។

**ទិន្នន័យសង្ខេប**

**ទីតាំង** ៖ មន្ទីរសន្តិសុខអកឆកស្ថិតនៅក្នុងភូមិទីពោ ឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ និងមានចម្ងាយពីសាលាស្រុកសន្ទុក ១៥គីឡូម៉ែត្រប៉ែកខាងកើត ។

**ស្ថិតិ** ៖ មន្ទីរសន្តិសុខអកឆកត្រូវខ្មែរក្រហមបង្កើតឡើងនៅភូមិទីពោ ឃុំទីពោ ដើម្បីឃុំឃាំងអ្នកទោស ។ រាល់ពេលដែលអ្នកទោសមុនៗត្រូវនាំយកទៅសម្លាប់នៅទួលមុំធ្លក អ្នកទោសថ្មីនឹងត្រូវបញ្ជូនមកជំនួសអ្នកទោសចាស់វិញ ។

### ៧) មន្ទីរសន្តិសុខឈូកគួយ

នៅប៉ែកខាងជើងសាលាស្រុកសន្ទុកប្រហែល៣គីឡូម៉ែត្រ ត្រង់ចំណុចភូមិរាំងដើង ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ មានកន្លែងមួយជាអតីតមន្ទីរសន្តិសុខឈូកគួយរបស់ខ្មែរក្រហម ដែលមានបំណែកគ្រឿងបែកបាក់នៅរាយប៉ាយពេញដី និងស្ថិតនៅក្នុងសភាពស្ងាត់ជ្រងំ ។

មន្ទីរសន្តិសុខនេះបង្កើតឡើងនៅក្នុងឆ្នាំ១៩៧៦ ដែលមានអគារជាច្រើនធ្វើអំពីឈើប្រក់គ្រឿងសម្រាប់ឃុំឃាំងនិងសួរចម្លើយប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញ ខេត្តកំពង់ធំ និងប្រជាជនមូលដ្ឋាន ដែលមានចំនួនប្រមាណពី៩០០ទៅ១០០០នាក់ ។ អ្នកទោសទាំងនេះត្រូវកងសន្តិសុខនាំយកទៅសម្លាប់នៅនឹងរណ្តៅធំៗលើទួលមួយក្បែរមន្ទីរសន្តិសុខនេះ ។ ឡេង ណាវ អាយុ៦៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិសង្គមថ្មី ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ បាននិយាយប្រាប់ថារណ្តៅសាកសពនៅមានស្លាកស្នាមនៅឡើយ ។

នៅដើមឆ្នាំ១៩៧៩ មន្ទីរសន្តិសុខឈូកគួយត្រូវរលំរលាយ

ដោយសារកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ។ អ្វីៗដែលមាននៅក្នុងមន្ទីរសន្តិសុខត្រូវបានកម្ទេចចោលទាំងអស់ សូម្បីតែផ្ទះសម្រាប់ឃុំឃាំងអ្នកទោសក៏គ្មានសល់ដែរ ។

### ទិន្នន័យសង្ខេប

**ទីតាំង** ៖ មន្ទីរសន្តិសុខឈូកគួយស្ថិតនៅភូមិវាំងដើង ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ។

**ស្ថិតិ**៖ មន្ទីរសន្តិសុខឈូកគួយបង្កើតឡើងកាលពីឆ្នាំ១៩៧៦ ដែលមានអ្នកទោសប្រមាណពី៩០០ទៅ១០០០នាក់ជាប់ឃុំឃាំងនៅទីនោះ ហើយក្រោយមកត្រូវបានសម្លាប់នៅក្បែរមន្ទីរសន្តិសុខ បន្ទាប់ពីជាប់ឃុំឃាំងអស់មួយរយៈពេលមក ។

## ស្រុកស្ទោង

### ៨) មន្ទីរសន្តិសុខវិទ្យាល័យរស្មីសោភ័ណ

អគារតែមួយគត់នៅវិទ្យាល័យរស្មីសោភ័ណត្រូវខ្មែរក្រហមជ្រើសរើសយកធ្វើជាមន្ទីរសន្តិសុខ ។ បន្ទប់ចំនួនបួនរបស់អគារនេះត្រូវខ្មែរក្រហមបែងចែកជាកន្លែងឃុំឃាំងអ្នកទោសចំនួនបីនិងកន្លែងសួរចម្លើយមួយបន្ទប់ ។ បច្ចុប្បន្នអគារនេះគឺជាថ្នាក់រៀនរបស់សិស្សានុសិស្សនៅស្រុកស្ទោង ។

មន្ទីរសន្តិសុខវិទ្យាល័យរស្មីសោភ័ណត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៦ ។ កងឈ្លបខ្មែរក្រហមកម្រសម្លាប់មនុស្សនៅក្នុងមន្ទីរសន្តិសុខនេះណាស់ ច្រើនតែនាំយកទៅសម្លាប់នៅលើទួលមួយឈ្មោះថា ទួលតាភ្លងដែលជាទីតាំងសម្លាប់ដ៏ធំមួយនៅស្រុកស្ទោង ។ លួន ខុម អាយុ៣៦ឆ្នាំ រស់នៅភូមិត្រាច ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ បាននិយាយថា អ្នកទោសជាប្រជាជនជម្លៀសច្រើនណាស់ ដែលមកជាប់នៅក្នុងមន្ទីរសន្តិសុខនេះ ហើយត្រូវបានយកទៅសម្លាប់ចោលបន្ទាប់ពីសួរចម្លើយរួច ។ លួន ខុម បន្តថា ការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខវិទ្យាល័យរស្មីសោភ័ណ ត្រូវបែងចែកជាពីរលើកគឺនៅអំឡុងឆ្នាំ១៩៧៦ ការសម្លាប់បានកើតឡើងចំពោះប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញនិងកំពង់ធំ ។ លើកទីពីរគឺពីឆ្នាំ១៩៧៧ដល់ចុងឆ្នាំ១៩៧៨ ការសម្លាប់នេះកើតឡើងចំពោះប្រជាជនដែលខ្មែរក្រហមសង្ស័យថាក្បត់នឹងអង្គការ ។ នៅដើមឆ្នាំ១៩៧៩ មន្ទីរសន្តិសុខនេះត្រូវរដ្ឋអំណាចថ្មីរំលាយចោល ។

ជុំ វិន អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិត្រាច ឃុំកំពង់ចិនជើង ស្រុកសន្ទុក ខេត្តកំពង់ធំ បានជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខវិទ្យាល័យរស្មីសោភ័ណដោយសារគាត់បានលួចបូតស្រូវហូប ។ វិន ត្រូវខ្មែរក្រហមនាំយកទៅសួរចម្លើយពីទោសកំហុសរបស់គាត់ ហើយត្រូវពិការជើងម្ខាងរហូតមកដល់សព្វថ្ងៃ ដោយសារការធ្វើទារុណកម្មក្នុងពេលសួរចម្លើយ ។

### ទិន្នន័យសង្ខេប

**ទីតាំង** ៖ មន្ទីរសន្តិសុខនៅវិទ្យាល័យរស្មីសោភ័ណស្ថិតនៅក្នុងភូមិត្រាច ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ ។

**ស្ថិតិ** ៖ អគារមួយក្នុងចំណោមអគារផ្សេងទៀតរបស់វិទ្យាល័យរស្មីសោភណ័ ត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរសន្តិសុខដែលមានបីបន្ទប់ជាកន្លែងឃុំឃាំងអ្នកទោសនិងមួយបន្ទប់ទៀតជាកន្លែងសួរចម្លើយ ។ ការសម្លាប់មិនបានធ្វើឡើងនៅក្នុងបរិវេណមន្ទីរសន្តិសុខទេ គឺនាំយកទៅសម្លាប់នៅលើទួលតាភ្លងឯណោះ ។

**ផេង ពង្សរ៉ាស៊ី**



មន្ទីរសន្តិសុខនៅវិទ្យាល័យរស្មីសោភណ័ ភូមិត្រាច ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ

# ចំណោទឧក្រិដ្ឋកម្ម
# មន្ទីរសន្តិសុខភូមិភាគនិរតី
# ការកកើត ប្រតិបត្តិការ និង ទំនាក់ទំនង

***(តពីលេខមុន)***

## ***ការប្រហារជីវិត***

មិនយូរប៉ុន្មានបន្ទាប់ពីអ្នកទោសឆ្លើយសារភាពពីទោសកំហុសរបស់ខ្លួនជូនអង្គការ អ្នកទោសត្រូវអង្គការសម្រេចនាំយកទៅប្រហារជីវិតតែម្តង ។ កម្មាភិបាលមន្ទីរសន្តិសុខកាន់បញ្ជីឈ្មោះហៅអ្នកទោសដែលត្រូវប្រហារជីវិតចេញពីមន្ទីរឃុំឃាំងម្តងម្នាក់ៗ ។ កម្មាភិបាលមន្ទីរសន្តិសុខចងដៃអ្នកទោសបណ្តើរសំដៅទីតាំងប្រហារជីវិត ។ អ្នកដែលមានសិទ្ធិសម្រេចប្រហារជីវិតអ្នកទោសមន្ទីរសន្តិសុខតំបន់ គឺមានគណៈភូមិភាគ និងគណៈតំបន់ ។

លី អតីតអ្នកទោសមន្ទីរសន្តិសុខតំបន់៣៥ រៀបរាប់អំពីដំណើរការនាំអ្នកទោសទៅប្រហារជីវិតថា នៅពេលដល់ថ្ងៃត្រូវប្រហារជីវិតអ្នកទោស កម្មាភិបាលមន្ទីរសន្តិសុខចាប់ផ្តើមរៀបចំការងារនេះចាប់តាំងពីម៉ោង៤រសៀល ។ កម្មាភិបាលមន្ទីរសន្តិសុខតំបន់ដើរប្រមូលអ្នកទោសតាមបញ្ជីដែលថ្នាក់លើប្រគល់ឲ្យ យកទៅដាក់ក្នុងបន្ទប់មួយដាច់ដោយឡែក ។ អ្នកទោសទាំងនោះត្រូវជាប់ខ្នោះក្នុងបន្ទប់រហូតដល់ម៉ោង៦ព្រឹក ទើបមានរថយន្តមកដឹកយកទៅប្រហារជីវិត ។ អ្នកទោសត្រូវបាននាំយកទៅប្រហារជីវិតម្តងៗចំនួនពី២០ទៅ៣០នាក់ ។

ចំពោះការប្រហារជីវិតអ្នកទោសមន្ទីរសន្តិសុខតំបន់២៥វិញ មានភាពខុសប្លែកពីមន្ទីរសន្តិសុខតំបន់៣៥ត្រង់ថា កម្មាភិបាលមន្ទីរសន្តិសុខតំបន់២៥មិនចាំបាច់ប្រមូលអ្នកទោសដែលត្រូវប្រហារជីវិតដាក់នៅក្នុងបន្ទប់ដោយឡែកពីអ្នកទោសដទៃទេ ហើយក៏មិនចាំបាច់ដឹកអ្នកទោសទៅប្រហារជីវិតនៅទីឆ្ងាយដែរ គឺអ្នកទោសត្រូវនាំចេញទៅប្រហារជីវិតតែប្រមាណ២០០ម៉ែត្រពីមន្ទីរសន្តិសុខប៉ុណ្ណោះ ។ ប៉ាន អតីតកម្មាភិបាលមន្ទីរសន្តិសុខតំបន់២៥អះអាងថា គាត់បានឃើញការប្រហារជីវិតអ្នកទោសផ្ទាល់ភ្នែក ។ "វាកើតឡើងជាប្រចាំ ។ ពេលនាំទៅសម្លាប់ អ្នកទោសត្រូវចងដៃ រួចបណ្តើរទៅក្នុងព្រៃខាងកើតឆ្ងាយពីរួចម្ងាយប្រហែល២០០ម៉ែត្រ ។ អ្នកទោសត្រូវបានបញ្ជាឲ្យអង្គុយចុះ រួចឃាតករវាយពីក្រោយនឹងត្បូងចប ដែកភ្ជួររទេះ រួចរុញទម្លាក់រណ្តៅតែម្តង" ។ ថន អតីតអ្នកទោសនិងសព្វថ្ងៃជាអ្នកជិតខាងរបស់ ប៉ាន បន្ថែមថា ដំណើរការប្រហារជីវិតអ្នកទោសនៅមន្ទីរសន្តិសុខតំបន់២៥ច្រើនធ្វើឡើងនៅថ្ងៃបុណ្យជាតិ ។ ថន បញ្ជាក់ថា អ្នកចម្រៀងខ្មែរល្បីល្បាញមួយរូបឈ្មោះ ស៊ិន ស៊ីសាមុត ជាមួយស្ត្រីម្នាក់ និងកូនក្មេង២នាក់ត្រូវបានប្រហារជីវិតនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៧ ។ សាកសពអ្នកទាំងបួនកប់ក្រោមដើមស្វាយខាងជើងមន្ទីរសន្តិសុខ ។

សុង អតីតអ្នកទោសមន្ទីរសន្តិសុខតំបន់២៥ ក៏បានដឹងអំពីដំណើរការប្រហារជីវិតអ្នកទោសដែរ ។ សុង ប្រាប់ថា "យប់ដែលត្រូវប្រហារជីវិតអ្នកទោស កម្មាភិបាលមន្ទីរសន្តិសុខចូលមកហៅឈ្មោះអ្នកទោសចេញពីបន្ទប់ឃុំឃាំង ។ ខ្នោះមួយជួរមានអ្នកទោស២០នាក់ ដូច្នេះអ្នកទោសដែលគ្មានឈ្មោះត្រូវដោះខ្នោះចេញ រួចទៅអង្គុយនៅម្ខាង ចំណែកអ្នកដែលត្រូវឈ្មោះត្រូវចេញទៅក្រៅ ។ ទីតាំងប្រហារជីវិតអ្នកទោសមានចម្ងាយប្រហែល២០០ម៉ែត្រខាងកើតមន្ទីរសន្តិសុខដោយមានដាក់សញ្ញាក្បាលខ្មោចសម្គាល់ ។ ការប្រហារជីវិតធ្វើឡើងមួយសប្តាហ៍ម្តងពីម៉ោង៦យប់រហូតដល់ភ្លឺតាមចំនួនអ្នកទោសតិចឬច្រើន ។ មានយប់មួយ ប្រជាជនមកពីស្រុកលើកដែកចំនួន១៥០នាក់ត្រូវបានប្រហារជីវិតចោលរយៈពេលតែមួយយប់ ។ អ្នកទោសមួយចំនួនត្រូវកប់ចោល និងមួយចំនួនត្រូវរុញទម្លាក់ក្នុងទឹកទន្លេ" ។

លលាដ៍ក្បាលនិងឆ្អឹងសាកសពអ្នកទោសជាច្រើន បន្សល់ទុកនៅក្នុងបូជនីយដ្ឋានដែលសាងសង់ឡើងនៅខាងកើតមន្ទីរសន្តិសុខតំបន់២៥ ។ ទីនោះជាទីតាំងប្រហារជីវិតអ្នកទោសរបស់កម្មាភិបាលមន្ទីរសន្តិសុខតំបន់២៥ ។ ប្រជាជនមូលដ្ឋានដែលត្រឡប់មករស់នៅកោះថ្មីក្នុងឆ្នាំ១៩៧៩បានឲ្យដឹងថា ពេលឡើងមកដល់កោះនេះដំបូងមានក្លិនអសោចពេញព្រៃ ស្នាមឈាមនិងសាកសពទើបប្រហារជីវិតថ្មីៗនៅក្បែរមន្ទីរសន្តិសុខក៏មានជាពិសេសក្នុងព្រៃខាងកើតមន្ទីរសន្តិសុខ ។ សព្វថ្ងៃនេះនៅមានឆ្អឹងសេសសល់តិចតួច ដោយសារគោក្របីស៊ី និងកប់បាត់នៅក្នុងដី ។ ប៉ាន អះអាងថា ក្រៅពីព្រៃខាងកើតមន្ទីរនេះ នៅជុំវិញមានរណ្តៅតូចៗច្រើននិងនៅក្រោមដើមឈើខ្លះទៀត មិនមែនមាននៅតែមួយកន្លែងខាងកើតមន្ទីរទេ ។ ប៉ាន បញ្ជាក់ថា គាត់បានដឹងអំពីការប្រហារជីវិត ប៉ុន្តែចំពោះសកម្មភាពប្រហារជីវិតវិញ គាត់ដែលជាអ្នកយាមមិនដែលបានចូលរួមឡើយ ។

អតីតអ្នកទោសមន្ទីរសន្តិសុខតំបន់អះអាងថា អ្នកទោសចង់ស្លាប់ក៏ពិបាក ចង់រស់ក៏ពិបាក ។ អ្នកទោសត្រូវជាប់ខ្នោះក្នុងបន្ទប់ធុំក្លិនស្អុយឆ្អាប ទទួលរងទារុណកម្ម វាយធ្វើបាប របបហូបចុកមិនគ្រប់គ្រាន់ និងត្រូវបង្ខំឲ្យធ្វើការជាទម្ងន់ ។ អ្នកទោសខ្លះបានសម្រេចចិត្តធ្វើអត្តឃាតដោយសារមិនអាចទ្រាំរស់នៅក្នុងជីវិតដែលលំបាកលំបិនដូចសត្វធាតុ ។ លី ជ្រើសយកការស្លាប់ជាជាងរស់នៅក្នុងមន្ទីរសន្តិសុខតំបន់៣៥ ដោយព្យាយាមធ្វើអត្តឃាតជាច្រើនលើក ។ «ពេលនោះបើស្លាប់បាត់ទៅក៏អរដែរ ព្រោះពិបាកពេក គេវាយធ្វើបាបដូចសត្វ កើតខែពេញខ្លួន ពេលត្រូវខ្យល់អត់បានទេគឺដួលតែម្តង» ។ សុង ជាអ្នកទោសម្នាក់ក្នុងមន្ទីរសន្តិសុខតំបន់២៥ រៀបរាប់ថា «មួយថ្ងៃៗអត់មានគិតអីទេ វេទនាពេកលែងចង់រស់ នឹកថា បើងាប់ទៅល្អជាងនៅរស់ ។ មនុស្សក៏មិនមែនមនុស្ស គេវាយទាត់ធាក់ ខោអាវរហែករយ៉ៃ អត់មានខ្មាសអៀនអីទេ» ។ វិន ប្រាប់វិធីដែលគាត់ជ្រើសយកការស្លាប់ជាជាងត្រូវដំបងនិងទាត់ធាក់ថា «ឆ្លើយតាមវាថា បើវាថាខ្ញុំយ៉ាងតិចក៏ស័ក្តិ៤ ខ្ញុំថាខ្ញុំស័ក្តិ៤មែន ។ ពេលនោះថាតាមវាចោទទាំងអស់» ។ តាមចម្លើយសារភាពរបស់ប្រធានមន្ទីរសន្តិសុខតំបន់២៥ អ្នកទោសមួយចំនួនស្លាប់ក្នុងមន្ទីរសន្តិសុខនិងមួយចំនួនតូចត្រូវបញ្ជូនបន្តទៅមន្ទីរស-២១ ។

**ទំនាក់ទំនងមន្ទីរសន្តិសុខតំបន់ និង មជ្ឈិមបក្ស**

វត្តមានអ្នកទោសក្នុងមន្ទីរសន្តិសុខតំបន់កើតឡើងដោយសារទី១) អ្នកទោសត្រូវបានចាប់ខ្លួនតាមបញ្ជារបស់គណៈភូមិភាគនិងគណៈតំបន់ និងទី២) អ្នកទោសត្រូវបានបញ្ជូនបន្តពីមន្ទីរអប់រំស្រុក ។

អ្នកទោសដែលត្រូវបានចាប់ខ្លួនតាមបញ្ជារបស់គណៈភូមិភាគនិងគណៈតំបន់ ភាគច្រើនជាកងទ័ព និងមហាជនដែលបម្រើការងារក្នុងក្របខ័ណ្ឌតំបន់ ។ គណៈភូមិភាគនិងគណៈតំបន់ពិនិត្យសម្រេចចាប់ខ្លួនអ្នកទោសបន្ទាប់ពីបានពិនិត្យរបាយការណ៍របស់ប្រធាននិងគណៈគ្រប់គ្រងអ្នកទោសដែលរៀបរាប់ពីទោសកំហុសអ្នកទោស ។ អ្នកទោសមួយចំនួនពុំបានដឹងច្បាស់អំពីមូលហេតុដែលត្រូវចាប់ខ្លួនឡើយ ហើយមួយចំនួនបានដឹងនៅពេលដែលខ្លួនត្រូវបានសួរចម្លើយ ពេលនោះគណៈស៊ើបអង្កេតបានលើកយកមូលហេតុមកបញ្ជាក់ប្រាប់អ្នកទោសទៅវិញ ។ ហាក់, សុង, លី និង តេង សុទ្ធតែមិនបានដឹងអំពីមូលហេតុដែលគាត់ត្រូវចាប់ខ្លួនបញ្ជូនទៅមន្ទីរសន្តិសុខតំបន់២៥និងតំបន់៣៥ឡើយ ។

ចំពោះ ម៉ឹង តេង ប្រធានសន្តិសុខតំបន់២៥ បានដឹងច្បាស់អំពីទោសកំហុសរបស់អ្នកទោសដែលត្រូវចាប់ខ្លួនពីព្រោះគាត់ទទួលបញ្ជាពីថ្នាក់លើនិងរបាយការណ៍យ៉ាងច្បាស់អំពីអ្នកទោសមុនពេលគាត់ចុះទៅចាប់ ។ ម៉ឹង តេង តែងទទួលបញ្ជាពីគណៈតំបន់២៥ឲ្យចុះទៅចាប់និងប្រហារជីវិតអ្នកទោស ។ តេង បញ្ជាក់ថា «ខ្ញុំអនុវត្តតាមការសម្រេចរបស់ បងជា (លេខាតំបន់២៥) ដោយចាប់ស្ត្រីនោះទៅមន្ទីរសន្តិសុខរួចធ្វើសំណុំរឿង ហើយស្នើបងជា សម្រេច រួចកម្ទេច» ។

ទំនាក់ទំនងរវាងថ្នាក់លើនិងថ្នាក់ក្រោម មានបីដំណាក់កាលទើបឈានដល់ការប្រហារជីវិត ។ ទី១) អ្នកទោសត្រូវឃុំខ្លួនដើម្បីសួរចម្លើយ ។ ទី២) ចម្លើយសារភាពរបស់អ្នកទោសត្រូវផ្ញើជូនគណៈភូមិភាគពិនិត្យនិងសម្រេច ។ ទី៣) អ្នកទោសភាគច្រើនត្រូវបានសម្រេចឲ្យប្រហារជីវិត និងមួយចំនួនតូចបញ្ជូនទៅមន្ទីរស-២១ ។

ដំណើរការបញ្ជូនអ្នកទោសពីមន្ទីរសន្តិសុខតំបន់ទៅមន្ទីរ

ស-២១មានពីរ ÷ ទី១) គណៈភូមិភាគផ្ញើរបាយការណ៍ទៅគណៈមជ្ឈិមបក្ស និង២) គណៈមជ្ឈិមបក្សសម្រេចបញ្ជាគណៈមន្ទីរ ស-២១ ឬគណៈតំបន់ឲ្យចាត់វិធានការបញ្ជូន ។ ម៉ៅ អះអាងថា អ្នកទោសត្រូវដឹកតាមរថយន្តពីតំបន់២៥ ទៅមន្ទីរស-២១ ។ ម៉ៅ លើកករណី គាជ័យ និងកម្មាភិបាលតំបន់២៥ ដែលត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់និងបញ្ជូនតាមរថយន្តទៅមន្ទីរស-២១ ។ ចំណែក ម៉ៅ ត្រូវចាប់បញ្ជូនទៅមន្ទីរសន្តិសុខតំបន់២៥ ។

ន ហ៊ីង វ៉ាយ៉ា ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៥ពីព្រំប្រទល់ខាងត្បូងប្រទេសវៀតណាម ក្រោមការចោទប្រកាន់ថា ជាចារនារីនិងជាខ្សែចាត់តាំងរបស់ ថៅ យិញ ។ ន ហ៊ីង វ៉ាយ៉ា ឆ្លងកាត់ការសួចម្លើយអស់រយៈពេលមួយខែនៅក្នុងមន្ទីរសន្តិសុខតំបន់២៥ បន្ទាប់មកត្រូវបានបញ្ជូនតាមរថយន្តទៅមន្ទីរស-២១ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ។ អ្នកទោសម្នាក់ទៀតឈ្មោះ ស៊ីសុវត្ថិ បុត្រសាវ៉ា ហៅ ច្រឹង អាយុ៣៣ឆ្នាំ ចាប់ខ្លួននិងឃុំឃាំងក្នុងមន្ទីរសន្តិសុខតំបន់២៥ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ ។ ច្រឹង ត្រូវបានបញ្ជូនមកដល់មន្ទីរស-២១ នៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៧៦ ហើយត្រូវសមមិត្ត ឌុច ដកឈ្មោះជូនគណៈមជ្ឈិមបក្សនៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧៦ ។

ប្រាហ៊ឹម អតីតទាហានស័ក្តិ៤កន្ទះក្នុងរបប លន់ នល់ ត្រូវបានចាប់និងបញ្ជូនខ្លួនជាបន្តបន្ទាប់ពីមន្ទីរឈ្លបឃុំកោះធំទៅមន្ទីរអប់រំស្រុកកោះធំ ។ បន្ទាប់មកទៀតគាត់ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខតំបន់២៥និងមន្ទីរស-២១ ។ ចម្លើយសារភាពរបស់ ប្រាហ៊ឹម បានឲ្យដឹងថា ប្រាហ៊ឹម ត្រូវបញ្ជូនមកដល់មន្ទីរស-២១នៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៦ ។ ប្រាហ៊ឹម ត្រូវគណៈមជ្ឈិមបក្សសម្រេចកម្ទេចនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧៦ ។ អតីតសមាជិកព្រឹទ្ធសភារបប លន់ នល់ ឈ្មោះ យ៉ាស់យ៉ា ត្រូវបានចាប់ខ្លួននៅភូមិគោរហេ ឃុំរការកោង ស្រុកមុខកំពូល តំបន់២៥ នៅវេលាម៉ោង១០យប់នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៥ ។ បន្ទាប់ពីចាប់ខ្លួន យ៉ាស់យ៉ា ត្រូវបញ្ជូនចេញពីកន្លែងមួយទៅកន្លែងមួយ នៅទីបំផុត យ៉ាស់យ៉ា ត្រូវស្លាប់ដោយការធ្វើទារុណកម្មនៅមន្ទីរ ស-២១ ។ ការស្លាប់បាត់បង់ជីវិតរបស់ ហ៊ឹម ម៉ាន អតីតកម្មាភិបាលឡូត៍នេសាទក្នុងតំបន់២៥មានដំណើររឿងមិនខុសពី យ៉ាស់យ៉ា ឡើយ ។ ហ៊ឹម ម៉ាន ត្រូវបានចាប់ខ្លួនឃុំឃាំងនិងបញ្ជូនខ្លួនពីមន្ទីរ សន្តិសុខមួយទៅមន្ទីរសន្តិសុខមួយរហូតដល់មន្ទីរ ស-២១ដែរ ។ ទីបំផុតគាត់ត្រូវគណៈមជ្ឈិមបក្សសម្រេចឲ្យនាំទៅកម្ទេចនៅបឹងជើងឯក ។

**តារាងបង្ហាញពីទំនាក់ទំនងនៃមន្ទីរសន្តិសុខតំបន់ ភូមិភាគ មន្ទីរ ស-២១ និងគណៈមជ្ឈិមបក្ស**

**មន្ទីរសន្តិសុខតំបន់**

១) ចាប់ខ្លួន ឃុំឃាំង និងសួរចម្លើយអ្នកទោស ។

២) បញ្ជូនអ្នកទោសទៅឃុំឃាំងនៅក្នុងមន្ទីរស-២១ ។

៣) ផ្ញើរបាយការណ៍និងចម្លើយសារភាពរបស់អ្នកទោសជូនអង្គការភូមិភាគពិនិត្យ ។

**ភូមិភាគ**

១) បញ្ជាឲ្យចាប់ប្រជាជនឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខភូមិភាគ ។

២) ពិនិត្យរបាយការណ៍និងចម្លើយសារភាពរបស់អ្នកទោសក្នុងមន្ទីរសន្តិសុខតំបន់ ។

៣) ផ្ញើរបាយការណ៍ចម្លើយសារភាពរបស់អ្នកទោសដែលត្រូវបញ្ជូនទៅមន្ទីរស-២១ឲ្យគណៈមន្ទីរស-២១ពិនិត្យ ។

**មន្ទីរស-២១**

១) ទទួលយកអ្នកទោសមកពីមន្ទីរសន្តិសុខតំបន់ ។

២) ចាប់ខ្លួនអ្នកទោសដើម្បីឃុំឃាំង សួរចម្លើយ ប្រហារជីវិត ។

៣) ផ្ញើរបាយការណ៍និងចម្លើយសារភាពរបស់អ្នកទោសជូនគណៈមជ្ឈិមបក្សពិនិត្យ ។

៤) ផ្ញើឈ្មោះខ្មាំងដែលជាប់ក្នុងចម្លើយសារភាពជូនអង្គការភូមិភាគដើម្បីចាប់ខ្លួន ។

**គណៈមជ្ឈិមបក្ស**

១) ពិនិត្យចម្លើយសារភាពរបស់អ្នកពាក់ព័ន្ធមន្ទីរស-២១ ។

២) បញ្ជាឲ្យគណៈមន្ទីរស-២១ចុះទៅចាប់អ្នកទោសតាមចម្លើយសារភាពអ្នកទោស ។

៣) សម្រេចឲ្យគណៈមន្ទីរស-២១ នាំខ្មាំងទៅប្រហារជីវិត ។

**(នៅមានត) អៀ ម៉េងទ្រី**

# ភៀសខ្លួនទៅប្រទេសថៃប៉ុន្តែត្រូវសម្លាប់នៅមន្ទីរស-២១

ភូមិបត់ត្រង់ ស្ថិតនៅក្នុងឃុំសំរោង ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ ភូមិនេះមានចម្ងាយ២៥គីឡូម៉ែត្រពីទីរួមខេត្ត ។ ប្រជាជនដែលរស់នៅភូមិបត់ត្រង់បាននិយាយថា កាលពីអំឡុងឆ្នាំ១៩៧៦ អ្នកភូមិបត់ត្រង់ប្រហែល២០នាក់បានភៀសខ្លួនទៅប្រទេសថៃ ដោយសារតែភ័យខ្លាចខ្មែរក្រហមចាប់យកទៅសម្លាប់ ។ នៅក្នុងចំណោមអ្នកទាំង២០នាក់នោះ មាន១១នាក់ គឺជាអ្នកទោសគុកទួលស្លែង(ស-២១) ដែលត្រូវបានរកឃើញនៅក្នុងបញ្ជីសម្លាប់អ្នកទោស ។ ប្រវត្តិរូបរបស់អ្នកទោសទាំង១១នាក់នោះមានឈ្មោះ ឡៃ, យ៉ិន ប៊ិ, សៀវ គ្រប់, ខ្វែង សំរួត, គុយ សំអាត, ឈ្នាង ហ, ឈ្នាង ហឿន, ហុក ឈួត, ប្រុក យឹម, ដុំ ប៊ុនរឿន និង ហ៊ាវ ង៉ូវ ។ នៅក្នុងប្រវត្តិរូបនេះមានម្នាក់សរសេរថាឃាត់ខ្លួននៅប្រទេសថៃ និង១០នាក់ទៀតបានបញ្ជាក់ថាឃាត់ខ្លួននៅអូរជ្រៅនៅថ្ងៃទី២៣ ខែ១១ ឆ្នាំ១៩៧៦ ។ ខាងក្រោមនេះគឺជាការជួបសម្ភាសជាមួយសាច់ញាតិរបស់អ្នកទោសទាំង១១នាក់ ។

### ***១) ថង ឡៃ ៖ ជាអតីតទាហានលន់នល់ត្រូវបានឃាត់ខ្លួននៅអូរជ្រៅ នៅចុងឆ្នាំ១៩៧៦***

ថង ឡៃ គឺជាកូនប្រុសទី២របស់ យិន ឡៃ ។ យិន ឡៃ ដែលមានវ័យ៧៥ឆ្នាំ រស់នៅភូមិធ្មេញត្រី (អតីតភូមិបត់ត្រង់) បានប្រាប់ឲ្យដឹងថា បើគិតមកដល់បច្ចុប្បន្ន ឡៃ មានអាយុ៥០ឆ្នាំហើយ ។ ឡៃ រៀបការជាមួយនារីម្នាក់ឈ្មោះ ប្រាជ្ញ ជាអ្នកភូមិជាមួយគ្នា ។ ក្រោយពេលរៀបការ ឡៃ និងប្រពន្ធប្រកបមុខរបរធ្វើស្រែ ។ នៅដើមឆ្នាំ១៩៧៥ ឡៃ សម្រេចចិត្តចូលធ្វើទាហានលន់នល់នៅស្រុកស្វាយស៊ីសុផុន ។ ឡៃ បានត្រឡប់មករស់នៅភូមិកំណើតរហូតដល់ឆ្នាំ១៩៧៦ ទើបភៀសខ្លួនទៅប្រទេសថៃ ព្រោះខ្លាចគណៈសហករណ៍ខ្មែរក្រហមចាប់ខ្លួន ។ ឡៃ និងអ្នកភូមិបត់ត្រង់ជាច្រើននាក់ដែលជាអតីតទាហាននិងអ្នករដ្ឋការសម័យលន់នល់បានភៀសខ្លួនទៅជាមួយគ្នា ។ ក្នុងចំណោមអ្នកទាំងនោះ យិន ឡៃ ចាំឈ្មោះតែ៣នាក់ប៉ុណ្ណោះ គឺឈ្មោះ សាប់ អតីតមេឃុំសំរោង ស្រុកសេរីសោភ័ណ, ហាំ ជាមេភូមិ៥០ខ្នង និងម្នាក់ទៀតឈ្មោះ ចាន់ ថា ជាមន្ត្រីគយ ។ នៅអំឡុងឆ្នាំ១៩៨០ យិន ឡៃ បានភៀសខ្លួនទៅព្រំដែនខ្មែរ-ថៃ ហើយបានជួបនឹងឪពុកមាឈ្មោះ ថៃ ដែលរស់នៅក្នុងប្រទេសថៃតាំងពីមុនរបបខ្មែរក្រហម ។ តាមរយៈឪពុកមា យិន ឡៃ បានដឹងដំណឹងពីកូនថា នៅឆ្នាំ១៩៧៦ ឡៃ បានទៅស្នាក់នៅនិងមកជួយប្រក់ដំបូលផ្ទះឲ្យឪពុកមាទៀតផង ។ ក្រោយមក ចាន់ ថា ដែលភៀសខ្លួនទៅជាមួយដែរនោះ បានធ្វើដំណើរទៅទីក្រុងបាងកកដើម្បីប្តឹងថា តម្រួតថៃបានយកមាសនិងលុយកាក់ពីខ្លួន ។ តម្រួតថៃខឹងសម្បាយ៉ាងខ្លាំងក្រោយពីឮដំណឹងនេះ ហើយក៏បានចាប់ប្រជាជនខ្មែរដែលភៀសខ្លួនទៅប្រទេសថៃមួយជំនាន់ ឡៃ បញ្ជូនត្រឡប់មកស្រុកខ្មែរវិញ ។ ឡៃ ក៏បាត់ឈឹងតាំងពីពេលនោះមក ។


យិន ឡៃ អាយុ៧៥ឆ្នាំ

### ***២) យ៉ិន ប៊ិ អតីតទាហាន លន់ នល់, ៣) សៀវ គ្រប់ កសិករ, ៤) ខ្វែង សំរួត និង ទី៥) គុយ សំអាត ប្រជាជន***

ប៊ិ, គ្រប់, សំរួត និង សំអាត សុទ្ធតែមានស្រុកកំណើតនៅភូមិបត់ត្រង់ ហើយត្រូវបានឃាត់ខ្លួននៅចុងឆ្នាំ១៩៧៦ នៅស្រុកអូរជ្រៅ ។ ញិប ឈឿន អាយុ៦៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិបត់ត្រង់ បានរៀបរាប់ថា ៖ យិន ប៊ិ ជាប្តីទី១របស់គាត់ដែលបានរៀបការនៅចុងឆ្នាំ១៩៦០ ។ ប៊ិ មានស្រុកកំណើតនៅភូមិបត់ត្រង់ដែរ ។ ឪពុករបស់ម្តាយរបស់ ប៊ិ ស្លាប់មុនរបបខ្មែរក្រហម ។ ឈឿន និងស្វាមីប្រកបមុខរបបធ្វើស្រែ ។ នៅក្នុងរបបសាធារណរដ្ឋខ្មែរ ប៊ិ បានស្ម័គ្រចិត្តចូលធ្វើទាហាន ។ ក្រោយមកអ្នកទាំងពីរបានលែងគ្នាបន្ទាប់ពីបានកូន៣នាក់ (ប្រុស២នាក់និងស្រីម្នាក់) ។ ក្រោយមក ប៊ិ បានទៅរៀបការប្រពន្ធមួយទៀតឈ្មោះ រី ។ ចំណែក ឈឿន ក៏បានរៀបការ ប្តីថ្មីដែរឈ្មោះ សៀវ គ្រប់


ញិប ឈឿន អាយុ៦៣ឆ្នាំ

ដែលរស់នៅភូមិជាមួយគ្នា ។ ផុន ភិច អាយុ៥៧ឆ្នាំ រស់នៅភូមិបត់ត្រង់និងត្រូវជាបងស្រី សៀវ គ្រប់ បានអះអាងថា សៀវ គ្រប់ ជាបងប្រុសរបស់គាត់ ។ គ្រប់ ធ្លាប់បានរៀបការជាមួយនារីម្នាក់ឈ្មោះ ហម ឆាវ នៅភូមិចង្ហា ហើយបានកូនប្រុស២នាក់ ប៉ុន្តែក្រោយមកអ្នកទាំងពីរក៏បានលះលែងគ្នា ។ រយៈ៣ឆ្នាំក្រោយ គ្រប់ ក៏បានរៀបការជាមួយ ញិប ឈឿន ។

ឈឿន បន្ថែមថា គ្រប់, ប៊ិ, គុយ អែត (ជាក្មួយប្រុស) និង ខ្វែង សំរួត (ជាប្អូនជីដូនមួយ) និងអ្នកស្រុកប្រហែល ២០នាក់បាននាំគ្នាភៀសខ្លួនទៅប្រទេសថៃនៅឆ្នាំ១៩៧៦ ។ គ្រប់ មិនមែនជាទាហានឬអ្នករដ្ឋការអ្វីទេ ប៉ុន្តែនៅអំឡុងឆ្នាំ១៩៧៥ គ្រប់ ធ្លាប់បានឃើញខ្មែរក្រហមចាប់មនុស្សយកទៅសម្លាប់ដែលជាហេតុធ្វើឲ្យគាត់ភ័យខ្លាចយ៉ាងខ្លាំង ។ ដូនពេលដែលអ្នកភូមិបបួលរត់ទៅប្រទេសថៃ គ្រប់ ក៏សម្រេចចិត្តរត់ទៅជាមួយគេតែម្តង ។ ក្រោយឆ្នាំ១៩៧៩ ឈឿន បានទទួលដំណឹងពីបងប្អូនខ្មែរដែលរស់នៅប្រទេសថៃថា តម្រួតថៃបានកុហកអ្នកភៀសខ្លួនទាំង២០រូបនោះឲ្យទៅធ្វើប័ណ្ណសម្គាល់ខ្លួន ។ នៅពេលជួបជុំគ្នាហើយ តម្រួតថៃក៏ចាប់ដាក់ឡានហើយបញ្ជូនមកស្រុកខ្មែរវិញ ។

## ៦) ឈ្នាង ហាំ មេភូមិ៥០ខ្នង និង ៧) ឈ្នាង ហឿន អតីតទាហាន លន់ នល់

អ្នកទាំងពីរមានស្រុកកំណើតនៅភូមិបត់ត្រង់ដែរ ហើយត្រូវបានឃាត់ខ្លួននៅចុងឆ្នាំ១៩៧៦ នៅអូរជ្រៅ ។ ឈ្នាង ហាំ គឺជាឪពុក ហើយ ឈ្នាង ហឿន ជាបងប្រុសរបស់ ឈ្នាង ហម ។ ឈ្នាង ហម បាននិយាយថា ឪពុកនិងបងប្រុសគាត់បានភៀសខ្លួនទៅប្រទេសថៃជាមួយអ្នកភូមិ ដោយសារគាត់ជាប្រធានភូមិ៥០ខ្នងនៅក្នុងភូមិបង់ត្រង់ នៅក្នុងរបបសាធារណរដ្ឋខ្មែរ ។ ដោយមានការភ័យខ្លាច គាត់ក៏បាននាំបង ហឿន ភៀសខ្លួនទៅប្រទេសថៃជាមួយគាត់ ហើយក៏បាត់ដំណឹងរហូតមកដល់សព្វថ្ងៃនេះ ។

## ៨) ប្រុក យឹម អតីតទាហានលន់នល់

កែវ នួន អាយុ៧៥ឆ្នាំ មានប្រសាសន៍ថា ប្រុក យឹម ជាប្អូនប្រុសពៅរបស់គាត់ ។ យឹម រៀបការជាមួយនារីម្នាក់


កែវ នួន អាយុ៧៥ឆ្នាំ

ឈ្មោះ ខាំ សុឃឿន តាំងពីសម័យសង្គមរាស្ត្រនិយម ។ មកដល់ជំនាន់លន់នល់ យឹម បានស្ម័គ្រចូលធ្វើទាហាននៅស្រុកស្វាយសិសុផុន ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ យឹម និង ឃឿន ត្រូវខ្មែរក្រហមជម្លៀសឲ្យត្រឡប់មករស់នៅភូមិបត់ត្រង់វិញ ។ រយៈពេលដែល យឹម រស់នៅភូមិបត់ត្រង់នេះ យឹម បានឃើញខ្មែរក្រហមចាប់ទាហានលន់នល់និងសិស្សសាលារាល់ថ្ងៃ ។ យឹម ដឹងខ្មែរក្រហមកំពុងបន្តចាប់អតីតទាហាន, រដ្ឋការ និងសិស្សនិស្សិតទៀត ដូច្នេះ យឹម ក៏បបួលអ្នកភូមិបត់ត្រង់ប្រមាណ១០នាក់ដែលមានជាប់ពាក់ព័ន្ធនឹងរបបលន់នល់ភៀសខ្លួនទៅប្រទេសថៃ ។ នៅពេលភៀសខ្លួនដល់ប្រទេសថៃ ចាន់ ថា ដែលជាអតីតជាមន្ត្រីគយក្នុងរបបលន់នល់ បានទៅប្តឹងពួកអាមេរិកាំងនិងពួកបារាំងដែលចុះសម្ភាសន៍ជនភៀសខ្លួនខ្មែរ អំពីតម្រួតថៃបានយកលុយនិងមាសរបស់ខ្លួន ។ ដំណឹងនេះបានធ្វើតម្រួតថៃខឹងសម្បា ហើយបានចាប់បញ្ជូនខ្មែរដែលភៀសខ្លួនទាំង១០នាក់ឲ្យត្រឡប់មកស្រុកខ្មែរវិញ ។

## ៩) ហុក ឈួត អតីតពេទ្យ ទាហាន លន់ នល់


សាន់ លីមហ៊ួវ អាយុ៥២ឆ្នាំ

ហុក ឈួត គឺជាប្អូនថ្លៃរបស់ សាន់ លីមហ៊ួវ ។ តាមការរៀបរាប់របស់ សាន់ លីមហ៊ួវ ភេទស្រីអាយុ៥២ឆ្នាំបានឲ្យដឹងថា ៖ កាលពីក្មេង ឈួត រៀននៅសាលាវត្តសំរោង បន្ទាប់មក បានទៅរៀននៅស្វាយសិសុផុន ។ បន្ទាប់ពីឈប់រៀន

នៅឆ្នាំ១៩៧៣ ឈួត បានរៀបការជាមួយនារីម្នាក់ឈ្មោះ សាន់ លីមហៀក ។ ឈួត ធ្វើពេទ្យទាហានផ្នែកជំងឺទូទៅនៅកំពង់ស្វាយ ស្រុកសេរីសោភ័ណ ។ នៅឆ្នាំ១៩៧៥ ឈួត និងគ្រួសារបាន ត្រឡប់មករស់នៅភូមិបត់ត្រង់វិញ ។ នៅចុងឆ្នាំ១៩៧៦ ឈួត បានរត់ភៀសខ្លួនទៅប្រទេសថៃជាមួយអ្នកភូមិ២៦នាក់ទៀត ដែលរស់នៅខេត្តស្រះកែវ ។ ក្រោយមកពួដំណឹងអ្នកទាំងអស់ នោះត្រូវតម្រួតថៃចាប់បញ្ជូនមកស្រុកខ្មែរវិញ ។

### ១០) ជុំ ប៊ុនរឿន និង ១១) ហ៊ាវ ង៉ូវ

ប៊ុនរឿន និង ង៉ូវ ជាអតីតទាហាន លន់ នល់ មានស្រុកកំណើត នៅភូមិបត់ត្រង់ ។ បងស្រី ជួប សាម៉ន អាយុ៤៧ឆ្នាំ រស់នៅភូមិ បត់ត្រង់នេះបានឲ្យដឹងថា ៖ ជុំ ប៊ុនរឿន ជាបងប្រុសរបស់គាត់ ចំណែក ហ៊ាវ ង៉ូវ គឺជាអ្នកជិតខាង ។ បងប្អូនបង្កើតរបស់ ង៉ូវ ស្លាប់ ទាំងអស់ ។ ប៊ុនរឿន និង ង៉ូវ បានចូលធ្វើទាហានលន់នល់នៅស្រុក ស្វាយស៊ីសូផុននៅឆ្នាំ១៩៧២ ។ នៅឆ្នាំ១៩៧៥ ប៊ុនរឿន និង ង៉ូវ បានវិលត្រឡប់មករស់នៅភូមិបត់ត្រង់វិញ ។ នៅឆ្នាំ១៩៧៦ ដោយសារភ័យខ្លាចខ្មែរក្រហមស៊ើបដឹងប្រវត្តិរូប ហើយចាប់ខ្លួន យកទៅសម្លាប់ ប៊ុនរឿន និង ង៉ូវ បានភៀសខ្លួនទៅប្រទេសថៃ ជាមួយអ្នកភូមិ ។ អ្នកទាំងពីរក៏បាត់ដំណឹងចាប់តាំងពីពេលនោះដែរ ។

ក្រោយពេលទទួលដំណឹងថា សាច់ញាតិរបស់គាត់ត្រូវ អង្គការខ្មែរក្រហមចាប់យកទៅដាក់នៅក្នុងគុកទួលស្លែងនោះ អ្នកភូមិបត់ត្រង់មានការរន្ធត់យ៉ាងខ្លាំង ហើយគាត់គិតថាសាច់ញាតិ របស់គាត់ប្រហែលជាត្រូវអ្នកយាមគុកនៅទួលស្លែងធ្វើទារុណកម្ម ធ្ងន់ធ្ងរហើយទម្រាំតែយកទៅសម្លាប់នោះ ។ យិន ឡែ បានមាន ប្រសាសន៍ទាំងទឹកភ្នែកថា «កូនខ្ញុំវាភ័យខ្លាចខ្មែរក្រហមយកទៅ សម្លាប់ ទើបវារត់គេចទៅប្រទេសថៃ ប៉ុន្តែទីបញ្ចប់វានៅតែត្រូវ ខ្មែរក្រហមចាប់យកទៅដាក់គុកទួលស្លែងធ្វើទារុណកម្ម និងសម្លាប់ យ៉ាងខ្លោចផ្សាដដែល» ។ ចំណែក ឈ្នាង ហម និង កែវ នួន ក៏បាន និយាយថា «ឪពុកខ្ញុំនិងប្អូនប្រុសខ្ញុំសុខចិត្តរត់ទៅស្រុកថៃទុកឲ្យ ម្តាយនិងកូនតូចៗនៅលំបាកវេទនាក្នុងរបបខ្មែរក្រហមក៏ ព្រោះតែ ពួកគាត់ចង់គេចឲ្យផុតពីការចាប់យកទៅសម្លាប់ហ្នឹងឯង តែ ទីបំផុតពួកគាត់នៅតែត្រូវសម្លាប់ដោយការធ្វើទារុណកម្មយ៉ាង ឃោរឃៅដដែល» ។

ជាចុងក្រោយសាច់ញាតិរបស់អ្នកទោសទួលស្លែងទាំង១១ នាក់ បានសម្តែងពីទឹកចិត្តរបស់គាត់ចង់ឃើញពីទិដ្ឋភាពជាក់ស្តែង នូវទីកន្លែងដែលពួកខ្មែរក្រហមយកឪពុក, កូន និងបងប្អូនរបស់ គាត់ត្រូវបានឃុំខ្លួន ធ្វើទារុណកម្មនិងសម្លាប់ ។ ជាមួយនេះដែរ គាត់ក៏ទន្ទឹងរង់ចាំថ្ងៃបើកសវនាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ ខ្មែរក្រហមដែរ ដើម្បីរកយុត្តិធម៌ជូនសាច់ញាតិរបស់គាត់និង ជនរងគ្រោះនៃរបបខ្មែរក្រហម ។

**ឡុង ដានី**

# ម៉ាន ស្លេះ ៖ អតីតទាហាន លន់ នល់

ម៉ាន ស្លេះ អាយុ៥៥ឆ្នាំ ជាគ្រូបង្រៀនផ្នែកខាងសាសនា (ឥស្លាម) នៅស្រុកកំពត ខេត្តកំពត ។ ម៉ាន ស្លេះ ជាក្មេងកំព្រា ឪពុកតាំងពីសម័យសង្គមរាស្ត្រនិយម ហើយរស់នៅជាមួយ ម្តាយប្រកបមុខរបរធ្វើស្រែចម្ការ ។ ម៉ាន ស្លេះ គឺជាកូនច្បងនិង ជាកូនប្រុសតែម្នាក់គត់ក្នុងចំណោមបងប្អូន៦នាក់ ។

នៅឆ្នាំ១៩៦៩ ម៉ាន ស្លេះ ត្រូវបានម្តាយបញ្ជូនឲ្យទៅ រៀនសូត្រខាងផ្នែកសាសនា ជាមួយលោកគ្រូហាពី ម៉ាត់ ទូត នៅ ភូមិព្រែកប្រា សង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ ទីក្រុងភ្នំពេញ ។ ដោយសារតែជីវិតគ្រួសារក្រីក្រ ម៉ាន ស្លេះ មិនមានថវិកាដើម្បី ជួលផ្ទះស្នាក់នៅដើម្បីរៀនទេ ដូច្នេះ ម៉ាន ស្លេះ បានទៅសំណាក់ នៅក្នុងម៉ាស្ជិដ (វិហារអ៊ីស្លាម) ជាមួយសិស្សដូចគ្នាដែលមកពីបណ្តា ខេត្តផ្សេងៗ ។ សូម្បីតែថវិកាសម្រាប់ផ្គត់ផ្គង់ការសិក្សារៀនសូត្រ ក៏ ម៉ាន ស្លេះ បានទទួលតិចតួចបំផុត ពីម្តាយ ជាហេតុធ្វើឲ្យ ម៉ាន ស្លេះ ត្រូវរកថវិកាបន្ថែមដោយខ្លួនឯងដើម្បីផ្គត់ផ្គង់ការរស់នៅ និងទិញសម្ភារសិក្សា ។ នៅពេលទំនេរពីការសិក្សា ម៉ាន ស្លេះ និងមិត្តភក្តិដែលមានជីវភាពខ្វះខាតខ្សោយដូចគ្នា បានសម្រេចចិត្ត ដើរសុំទាននៅតាមភូមិអ៊ីស្លាម ។ អ្នកភូមិខ្លះ អាណិតអាសូរផ្តល់ ជាអង្ករ និងអ្នកខ្លះទៀតឲ្យជាលុយកាក់តាមលទ្ធភាពរបស់ខ្លួន ។

សិក្សាបានតែរយៈពេល៣ឆ្នាំ ម៉ាន ស្លេះ បានឈប់រៀន ដោយសារខ្លួនមិនមានលទ្ធភាពរកថវិកាគ្រប់គ្រាន់មកផ្គត់ផ្គង់ការ រៀនសូត្រតទៅទៀត ហើយ ម៉ាន ស្លេះ ក៏ត្រឡប់មកជួយធ្វើ ស្រែចម្ការម្តាយវិញ ។

ដោយមានភក្តីភាពចំពោះជាតិ នៅឆ្នាំ១៩៧០ ម៉ាន ស្វេះ បានសម្រេចចិត្តចូលធ្វើទាហានតាមការអំពាវនាវរបស់រដ្ឋាភិបាល លន់ នល់ ។ ម៉ាន ស្វេះ ជាទាហាននៅក្នុងកងវរសេនាតូច១៥៣ នៅទីក្រុងភ្នំពេញក្រោមឧិវាទរបស់ឧត្តមសេនីយ៍ ស្វេះ កសឹម និងក្រោមបញ្ជាការផ្ទាល់របស់លោក លី ស្មាន។ ម៉ាន ស្វេះ បានរៀនអំពីរបៀបប្រើកាំភ្លើងនិងក្បួនសាស្ត្រក្នុងការប្រយុទ្ធ ។ ក្រោយមក កងពលរបស់ ម៉ាន ស្វេះ បានទទួលការចាត់តាំងឲ្យទៅប្រយុទ្ធនៅបន្ទាយលង្វែកទល់នឹងកងទ័ពខ្មែរក្រហមដែលកំពុងអុកឡុក ។ សមរភូមិលើកនេះមានរយៈពេល៣ថ្ងៃ៣យប់ និងមានសភាពភាពតានតឹងជាខ្លាំង ទ័ពទាំងសងខាងមានរបួសនិងស្លាប់អស់ជាច្រើននាក់ ។ បន្ទាប់ពីប្រយុទ្ធចប់ កងពលរបស់ ម៉ាន ស្វេះ ត្រូវត្រឡប់មកបន្ទាយវិញ ហើយ ម៉ាន ស្វេះ ក៏បានសុំលាឈប់ពីទាហានដើម្បីជួយម្តាយធ្វើស្រែចម្ការនៅឯស្រុកកំណើត ។

នៅក្នុងឆ្នាំដដែល ខ្មែរក្រហម យៀកកុងនិងវៀតណាមខាងជើងធ្វើសកម្មភាពអុកឡុកគ្រប់ទីកន្លែង ហើយរដ្ឋាភិបាល លន់ នល់ បានប្រកាសជ្រើសរើសទ័ពបន្ថែមទៀត ។ ម៉ាន ស្វេះ ក៏បាន ចូលបម្រើកងទ័ពម្តងទៀត ប៉ុន្តែលើកនេះ ម៉ាន ស្វេះ ស្ថិតក្នុងវរសេនាតូចលេខ១៨១ នៅខេត្តកំពត និងក្រោមបញ្ជាការផ្ទាល់របស់លោក រស់ ស្មាន។ ម៉ាន ស្វេះ បម្រើទ័ពបានតែរយៈពេល៣ខែប៉ុណ្ណោះ សុំឈប់មកធ្វើជាប្រជាជនវិញ ។

នៅពាក់កណ្តាលឆ្នាំ១៩៧២ សភាពការណ៍ក្នុងស្រុកកាន់តែមានភាពចលាចលខ្លាំងឡើងៗ ម៉ាន ស្វេះ និងមិត្តភក្តិ បានបបួលគ្នារត់ភៀសខ្លួនទៅប្រទេសវៀតណាម ។ នៅពេលទៅដល់ប្រទេសវៀតណាម ចូលរៀនខាងផ្នែកសាសនា អ៊ីស្លាមបន្តទៀត ហើយ ម៉ាន ស្វេះ ក៏ដាច់ដំណឹងពីក្រុមគ្រួសារ នៅខេត្តកំពតតាំងពីពេលនោះមកដែរ ។

នៅឆ្នាំ១៩៧៧ កងទ័ពខ្មែរក្រហមបានវាយលុកចូលទឹកដីវៀតណាមបានរហូតដល់២០គីឡូម៉ែត្រពីព្រំដែន ។ ប្រជាជនកម្ពុជារត់ភៀសខ្លួនទៅប្រទេសវៀតណាមកាន់តែច្រើនឡើងៗ ដោយសារតែមិនអាចទ្រាំទ្រនឹងការធ្វើទារុណកម្មនិងធ្វើការការងារធ្ងន់ៗ ។

នៅក្នុងឆ្នាំដដែល រដ្ឋាភិបាលវៀតណាមបានធ្វើការបំផុសបំផុលឲ្យប្រជាជនខ្មែរដែលបានរត់ទៅជ្រកកោននៅប្រទេសវៀតណាមឲ្យចូលបម្រើកងទ័ពដើម្បីវាយរំដោះប្រទេសកម្ពុជាចេញពីការគ្រប់គ្រងរបស់ខ្មែរក្រហមវិញ ។ ម៉ាន ស្វេះ និងប្រជាជនខ្មែរជាច្រើនទៀតក៏ស្ម័គ្រចិត្តចូលបម្រើកងទ័ព ។ កងទ័ពរបស់រដ្ឋាភិបាលវៀតណាម បានបង្ហាត់បង្រៀនកងទ័ពស្ម័គ្រចិត្តខ្មែរអំពីក្បួនយុទ្ធសាស្ត្រប្រយុទ្ធនិងរបៀបប្រើប្រាស់កាំភ្លើងរហូតដល់បានចេះសព្វគ្រប់ ។

នៅចុងឆ្នាំ១៩៧៨ កងទ័ពខ្មែរដែលស្ម័គ្រចិត្តតស៊ូរួមប្រយុទ្ធជាមួយកងទ័ពវៀតណាម បានធ្វើការវាយប្រហារទៅលើពួកខ្មែរក្រហមនៅគ្រប់ច្រកព្រំដែនខ្មែរ-វៀតណាមទាំងអស់ ។ ជាលទ្ធផលក្នុងរយៈពេលមិនដល់មួយខែផងគឺនៅដើមខែមករា ឆ្នាំ១៩៧៩ កងទ័ពតស៊ូកម្ពុជា បានទទួលជ័យជម្នះក្នុងការប្រយុទ្ធនេះនិងវាយបណ្តេញកងទ័ពខ្មែរក្រហមរហូតដល់ទល់ដែនភាគខាងលិចប្រទេស ហើយដណ្តើមយកប្រទេសកម្ពុជាបានទាំងស្រុងនៅថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ម៉ាន ស្វេះ បានធ្វើដំណើរទៅស្រុកកំណើតវិញ ដើម្បីស្វែងរកក្រុមគ្រួសារនិងសាច់ញាតិ ។ ម៉ាន ស្វេះ មានការសោកស្តាយនិងកំហឹងជាខ្លាំងនៅពេលដឹងថាសាច់ញាតិមួយចំនួនរបស់គាត់បានបាត់បង់ជីវិតដោយសារតែពួកខ្មែរក្រហម ។ ម្តាយរបស់ ម៉ាន ស្វេះ បានរៀបរាប់ពីការដែលខ្មែរក្រហមយកប្អូនថ្លៃប្រុសពីរនាក់របស់ខ្លួនទៅសម្លាប់ថាកាលណោះ ឈ្លបខ្មែរក្រហមបានសួររក ម៉ាន ស្វេះ ប៉ុន្តែដោយមិនឃើញ ខ្មែរក្រហមក៏បានចោទប្រកាន់មកលើគ្រួសាររបស់គាត់ថាជា«អ្នកបម្រើពួកខ្មាំង» ។ ចំណែកក្មួយៗរបស់ ម៉ាន ស្វេះ ត្រូវបានសហករណ៍បន្ទុយរបបហូបចុករហូតដល់ស្លាប់ ។

រហូតមកដល់ឆ្នាំ២០០៦ ម៉ាន ស្វេះ បានមកទស្សនាសារមន្ទីរទួលស្លែង វាលពិឃាតជើងឯក និងអគារតុលាការខ្មែរក្រហម តាមរយៈដំណើរទស្សនកិច្ចដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាឱកាសមួយសម្រាប់ ម៉ាន ស្វេះ ស្វែងយល់បន្ថែមអំពីបទឧក្រិដ្ឋដែលប្រព្រឹត្តដោយរបបគ្រប់គ្រងខ្មែរក្រហម ដែលម្តាយ និងសាច់ញាតិរបស់គាត់បានប្រាប់ ។ ម៉ាន ស្វេះ សង្ឃឹមថាតុលាការនឹងជួយរកយុត្តិធម៌ដោយធ្វើការវែកញែករកមេខ្លោង និងជនដៃដល់ដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ម៉ាន ស្វេះ និយាយថា កំហឹងដែលមាននៅក្នុងចិត្តរបស់គាត់ជិត៣០ឆ្នាំមកនេះ មិនទាន់អាចរំសាយបានទេ ដរាបណាគាត់មិនទាន់ឃើញមេដឹកនាំខ្មែរក្រហមត្រូវបាននាំយកមកកាត់ទោស ។

**យូសុះ អាម៉ាត់**

# ការចូលរួមរបស់ជនរងគ្រោះ : ដំណើរទស្សនកិច្ចលើកទី៩ទៅកាន់អគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ប្រជាជនចំនួន៣៩៨នាក់ពីបណ្តាខេត្តនានានៃប្រទេសបានមកកាន់ទីក្រុងភ្នំពេញក្នុងដំណើរទស្សនកិច្ចលើទី៩ ដើម្បីទស្សនាទីតាំងប្រល័យពូជសាសន៍សំខាន់ៗជាច្រើន និងជួបជាមួយអ្នកច្បាប់និងមន្ត្រីជាន់ខ្ពស់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ រហូតមកដល់ពេលនេះ ដំណើរទស្សនិច្ចទៅកាន់អគារអង្គជំនុំជម្រះវិសាមញ្ញដែលរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជាបាននាំប្រជាជនទូទាំងប្រទេសចំនួន៤៦០០នាក់មកទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតបឹងជើងឯក អគារតុលាការ និងចូលរួមស្តាប់ការបកស្រាយរបស់ឯកឧត្តម ម៉ោញ សាផាន អំពីច្បាប់ខ្មែរក្រហមនិងឆ្លើយនូវសំណួរផ្សេងៗដែលទាក់ទងនឹងសាលាក្តីនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២ ។



សាកលវិទ្យាល័យភូមិន្ទភ្នំពេញ២

ប្រជាជនដែលចូលរួមក្នុងដំណើរទស្សនកិច្ចនេះ បានទទួលឯកសារចំនួនបួនប្រភេទពីបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលរួមមាន : សៀវភៅណែនាំអំពីតុលាការកាត់មេដឹកនាំខ្មែរក្រហម សៀវភៅណែនាំអំពីច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនិងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ទស្សនាវដ្តីស្វែងរកការពិតលេខពិសេសរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា និងសៀវភៅណែនាំអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សម្រាប់មនុស្សមួយចំនួន នេះជាដំណើរទស្សនកិច្ចលើកទី១ដែលអ្នកភូមិបានទស្សនាទីតាំងទាំងនោះ ។ ទីតាំងនីមួយៗដែលប្រជាជនបានទស្សនាមិនត្រឹមតែបញ្ជាក់ពីព្រឹត្តិការណ៍ដ៏គួររន្ធត់នៃរបបខ្មែរក្រហមប៉ុណ្ណោះទេ ថែមទាំងបាននាំមកនូវក្តីសង្ឃឹមនិងការស្ងប់ចិត្ត និងទទួលបាននូវការពន្យល់វែកញែកធ្វើឲ្យអ្នកស្រុកមានអារម្មណ៍ថាតុលាការនឹងនាំនូវយុត្តិធម៌សម្រាប់ជនរងគ្រោះដែលនៅរស់និងជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតទៀតផង ។ សម្រាប់ប្រជាជនដំណើរទស្សនកិច្ចនេះកាន់តែមានសារសំខាន់ជាងការចែកចាយព័ត៌មានដែលទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញទៅទៀត ។ អ្នកភូមិរំជួលចិត្តពេលឃើញរូបថតរបស់ពួកខ្មែរក្រហម"សត្រូវ" ឧបករណ៍ធ្វើទារុណកម្មអតីតទីតាំងសម្លាប់មនុស្សដ៏ធំនិងរូបភាពផ្សេងៗទៀតនៃអំពើប្រល័យពូជសាសន៍ដែលគេមិនអាចមើលរំលងបាន ។ ដំណើរទស្សនកិច្ចបានបង្កប់នូវការអប់រំ និងការព្យាបាលផ្លូវចិត្តដែលធ្វើឲ្យជនរងគ្រោះមានអារម្មណ៍ខ្លួនឯងថាមានសារសំខាន់តាមរយៈការបញ្ចេញសំ-ឡេង ។ ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍មិនត្រឹមតែមានតួនាទីសំខាន់ក្នុងការផ្តល់ជាភស្តុតាងនិងកសិណសាក្សីនៅក្នុងតុលាការប៉ុណ្ណោះទេ ពួកគាត់ថែមទាំងជាអ្នកគ្រប់គ្រងប្រទេសនិងផ្តល់នូវការអប់រំដល់ក្មេងជំនាន់ក្រោយដែលជាអ្នកចូលរួមស្ថាបនានិងដឹកនាំប្រទេសកម្ពុជាទៅថ្ងៃអនាគតផង ។ ដូច្នេះគោលបំណងនៃដំណើរទស្សនកិច្ចនេះ គឺដើម្បីអូសទាញការយកចិត្តទុកដាក់ទៅលើតួនាទីរបស់ជនរងគ្រោះ ។

នៅពេលព្រឹកព្រលឹមថ្ងៃច័ន្ទដែលមានភ្លៀងធ្លាក់ផង អ្នកភូមិបានទៅទស្សនាមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង នៅម៉ោង៧:៣០នាទីដោយគ្មានរួញរា ។ នៅក្នុងសារមន្ទីរគុកទួលស្លែងអ្នកចូលរួមបានដើរឆ្លងកាត់បន្ទប់អគារជាច្រើននៃអតីតសាលារៀន

ដែលប្រែក្លាយជាកន្លែងសួរចម្លើយនិងធ្វើទារុណកម្មនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ បន្ទប់ជាច្រើនដែលធ្លាប់ឃុំអ្នកទោសស្គមកំព្រីងនិងគ្មានកម្លាំងកំហែង ឥឡូវនេះបានតាំងរូបថតរបស់អ្នកទាំងនោះដោយរៀបចំដាក់ស៊ុមកញ្ចក់យ៉ាងត្រឹមត្រូវ។ វិន័យសន្តិបាលក្នុងការសួរចម្លើយនិងឧបករណ៍ធ្វើទារុណកម្មត្រូវបានដាក់តាំងបង្ហាញទាំងស្រុងនៅក្នុងបរិវេណអគារ។ នៅពេលដើរមើលតាមបន្ទប់នីមួយៗ អ្នកភូមិមួយចំនួនងឿងឆ្ងល់តាមរយៈអ្វីដែលពួកគាត់បានឃើញ ហើយមួយចំនួនទៀតចាប់ផ្តើមនឹកឃើញពីជីវិតរបស់ខ្លួននៅក្នុងអំឡុងពេលជាងបីឆ្នាំនៃរបបប្រល័យពូជសាសន៍។ អ្នកភូមិខ្លះទៀតបានរកឃើញនិងចំណាំមុខម្ចាស់រូបថតនៅក្នុងស៊ុមរូបថតជាច្រើនសន្ទឹក។




ឌិម សាត មកពីខេត្តព្រៃវែង បានរកឃើញរូបថតបងប្អូនជីទួតមួយរបស់គាត់។ ពីដំបូង សាត មិនទាន់ច្បាស់នៅក្នុងចិត្តថារូបថតរបស់យុវជនដែលមានអក្សរសរសេរនៅពីក្រោមថា "មុំ សុផល, ៧៩៦" ពិតជាសាច់ញាតិរបស់គាត់ដែលបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហមនៅឡើយទេ ក៏ប៉ុន្តែនៅពេលដែលគាត់ពិនិត្យមើលរូបថតម្តងហើយម្តងទៀតរយៈពេលពីរ-បីនាទីមកគាត់គិតច្បាស់ក្នុងចិត្តថា យុវជនដែលមានវ័យ១៩ឆ្នាំនេះពិតជាបងប្អូនជីទួតមួយរបស់គាត់ពិតមែន។ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានផ្តិតរូបថតនេះជូនគាត់និងសាច់ញាតិរបស់គាត់ដែលកំពុងរស់នៅឯខេត្តព្រៃវែង។ សាត បានរំឭកឡើងវិញនូវអនុស្សាវរីយ៍ដែលរូបគាត់និងបងប្អូនជីទួតមួយទៅរៀននៅសាលាបឋមសិក្សាជាមួយគ្នា។ បន្ទាប់ពីរបបប្រល័យពូជសាសន៍ដួលរលំ មុំ សុផល មិនឃើញត្រឡប់ទៅផ្ទះវិញទេ ហើយក្រុមគ្រួសាររបស់គាត់តែងតែធ្វើបុណ្យឧទ្ទិសដើម្បីបានទទួលដំណឹងអំពី សុផល។ នៅពេលដែល ឌិម សាត ត្រឡប់ទៅផ្ទះវិញគាត់នឹងនាំយករូបថតរបស់ មុំ សុផល ថតនៅមន្ទីរ ស-២១ ទៅឲ្យក្រុមគ្រួសាររបស់គាត់បានដឹងនូវរឿងរ៉ាវដែលកើតឡើងចំពោះ សុផល។ ចំពោះអ្នកភូមិផ្សេងទៀតដែលកំពុងទស្សនាមន្ទីរស-២១ បានបង្ហាញនូវអារម្មណ៍របស់ខ្លួនប្រាប់អ្នកភូមិដទៃទៀតថា ៖ ខ្លួនគាត់ក៏ធ្លាប់ត្រូវបានឃុំឃាំងនៅទីនេះដែរ។ លោក ថន សាឡៃ ដែលឥឡូវមានវ័យ ៤៨ឆ្នាំ នៅតែចងចាំយ៉ាងច្បាស់នូវថ្ងៃដែលគាត់ត្រូវបានបញ្ជូនមកកាន់គុកទួលស្លែងពីបទលួចអង្ករ។ នៅខែធ្នូ ឆ្នាំ១៩៧៧ វេលាម៉ោងប្រហែលជា៩យប់ កម្មាភិបាលខ្មែរក្រហមបានមកប្រាប់ សាឡៃ ថា គាត់ត្រូវទៅ"រៀន" មានន័យថា សាឡៃ ត្រូវទៅទទួលការអប់រំនៅក្នុងមន្ទីរសន្តិសុខមួយក្នុងចំណោមមន្ទីរសន្តិសុខទាំងនោះ។ សាឡៃ និងយុវជនពីរនាក់ទៀតនៅក្នុងភូមិត្រូវចងមុខជិតនិងបញ្ជូនទៅមន្ទីរស-២១។ សាឡៃ ត្រូវបិទមុខនិងឲ្យរង់ចាំនៅក្នុងបន្ទប់តូចតែម្នាក់ឯងរហូតដល់អ្នកយាមគុកមកយកគាត់ទៅបន្ទប់មួយដែលអ្នកសួរចម្លើយកំពុងរង់ចាំគាត់។ ក្នុងពេលសួរចម្លើយ សាឡៃ បានសារភាពនូវ"បទល្មើស"របស់គាត់ និងនិយាយថាគាត់មិនបានក្បត់នឹងអង្គការទេ។ សាឡៃ បានពន្យល់ថា គាត់យកអង្ករឲ្យបងប្អូនរបស់គាត់ដើម្បីឲ្យពួកគាត់មានកម្លាំងគ្រប់គ្រាន់ដើម្បីធ្វើការបម្រើអង្គការ។ បន្ទាប់មក សាឡៃ ត្រូវបានវាយដំនិងនាំយកទៅបន្ទប់របស់គាត់វិញ។ បន្ទាប់ពីធ្វើការលត់ដំនៅក្នុងគុកអស់រយៈពេល២ខែ សាឡៃ ត្រូវបានដោះលែងនៅខែកុម្ភៈ ឆ្នាំ១៩៧៨។ ថ្ងៃច័ន្ទ គឺជាលើកទីមួយដែល សាឡៃ


ប្រជាជនដើរទស្សនាអគារគុក នៅមន្ទីរ ស-២១

បានត្រឡប់មកទីតាំងគុកនេះម្តងទៀត ។ អ្វីដែលធ្វើឲ្យសាច់រឿងរបស់គាត់កាន់តែដក់ចិត្តទៀតនោះគឺថាអ្នកទោសដែលបាននាំយកមកមន្ទីរស-២១ កម្រត្រូវបានដោះលែងឲ្យចេញទៅវិញណាស់ គឺមានតែអ្នកទោសមួយចំនួនប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតឲ្យចាកចេញពីមន្ទីរគុក ។ សាឡៃ មិនដែលនិយាយពីបទពិសោធន៍ជីវិតនៅមន្ទីរស-២១ នេះប្រាប់ដល់កូនៗរបស់គាត់ទេ ។

សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង បង្ហាញអ្នកភូមិឲ្យក្រឡេកមើលទៅលើរចនាសម្ព័ន្ធនយោបាយ និងរចនាសម្ព័ន្ធដឹកនាំរបស់របបខ្មែរក្រហម តែទោះជាយ៉ាងណាក៏ដោយ មន្ទីរនេះបាននាំមកនូវភាពរស់រវើកនៃអតីតកាលដ៏សាហាវមួយដែលមិនសូវមានអ្នកនឹកនាដល់ឬបំភ្លេចចោលទៅហើយ នៅពេលឥឡូវនេះ ប្រជាជនអាចចាប់ផ្តើមផ្សះផ្សាផ្លូវចិត្តបាន (បន្ទាប់ពីបានទស្សនាមន្ទីរស-២១) ។


ប្រជាជនចូលរួមស្តាប់ការបកស្រាយរបស់ឯកឧត្តម ម៉ោញ សាផាន នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២


ប្រជាជនចូលរួមស្តាប់ការបកស្រាយរបស់ឯកឧត្តម ម៉ោញ សាផាន នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២

គោលដៅបន្ទាប់នៅក្នុងដំណើរទស្សនកិច្ចនេះ គឺសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២ ជាកន្លែងដែលអ្នកភូមិត្រូវជួបជាមួយ ឯកឧត្តម ម៉ោញ សាផាន ជាសមាជិកសភា និងទស្សនាខ្សែភាពយន្ត "មន្ទីរស-២១ : ក្បាលម៉ាស៊ីនសម្លាប់មនុស្សខ្មែរក្រហម" ។ ឯកឧត្តម ម៉ោញ សាផាន បានស្វាគមន៍អ្នកភូមិ និងបកស្រាយពីច្បាប់និងនីតិវិធីដែលត្រូវប្រើក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ ឯកឧត្តម ម៉ោញ សាផាន ជាប្រធានគណៈកម្មា-ធិការនីតិកម្មនៃរដ្ឋសភាជាតិ ហើយឯកឧត្តមបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការអនុម័តច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លោក រ៉ូប៊ឺត ពេទីត សហព្រះរាជអាជ្ញាអន្តរជាតិ ក៏ត្រូវបានអញ្ជើញឲ្យមកចូលរួមសម្តែងមតិដែរ ក៏ប៉ុន្តែ លោកត្រូវអាក់ខានមិនបានអញ្ជើញមកវិញ ដោយសារលោក ជាប់រវល់ ។ លោក វ៉ាន់ថាន់ ពៅដារ៉ា នាយករងមជ្ឈ-មណ្ឌលឯកសារកម្ពុជាក៏បានបកស្រាយពីចំណុចដែលទាក់ទងនឹងតុលាការខ្មែរក្រហមនេះដែរ ។ បន្ទាប់ពីអ្នកទាំងពីរបានរៀបរាប់ចប់ អ្នកភូមិបានលើកឡើងនូវសំណួរផ្សេងៗ ។ សំណួរជាច្រើន មានលក្ខណៈស្រដៀងគ្នាទៅនឹងសំណួរដែលអ្នកភូមិបានសួរនៅក្នុងដំណើរទស្សនកិច្ចមុនៗដែរ និងផ្តោតជាសំខាន់ទៅលើប្រធានបទផ្សេងៗគ្នាពីអំពើប្រល័យពូជសាសន៍រហូតទៅដល់បញ្ហានៃការទទួលខុសត្រូវ ។ អ្នកចូលរួមបានសួរអំពីតួនាទីរបស់សហគមន៍អន្តរជាតិក្នុងអំឡុងនិងក្រោយពេលដែលអំពើប្រល័យពូជសាសន៍កើតមាននៅកម្ពុជា អំពីការលើកលែងទោសរបស់ អៀង សារី អំពីថាតើរដ្ឋាភិបាលបរទេសជាអ្នកនៅពីក្រោយខ្នងការដឹកនាំរបស់ ប៉ុល ពត, អំពី"តុលាការបដិវត្តន៍"ក្នុងឆ្នាំ១៩៧៩ ដែលកាត់ទោស ប៉ុល ពត និង អៀង សារី, អំពីថាតើកម្មាភិបាលថ្នាក់ក្រោមអាចនឹងត្រូវនាំយកមកកាត់ទោសដែរឬយ៉ាងណា និងអំពីថាតើអ្នកដែលជាប់ចោទនោះនឹងត្រូវទទួលទោសតាមរបៀបណា? សំណួរទាំងនោះ ត្រូវបានស្រាយបំភ្លឺយ៉ាងល្អបំផុត ដោយ ឯកឧត្តម ម៉ោញ សាផាន និងលោក វ៉ាន់ថាន់ ពៅដារ៉ា ។ បន្ទាប់ពី

វគ្គសំណួរនិងចម្លើយ បានបញ្ចប់មជ្ឈមណ្ឌលឯកសារកម្ពុជាបាន រៀបចំអាហារថ្ងៃត្រង់ជូនអ្នកភូមិ ។ នៅអំឡុងពេលបាយថ្ងៃត្រង់ ក៏មានចែកថ្នាំសង្កូវមួយចំនួនដូចជា ថ្នាំគ្រុនក្តៅ ប្រេងកូឡា និង ថ្នាំពុលឡានចែកជូនដល់អ្នកភូមិដែរ ។

បន្ទាប់ពីបាយថ្ងៃត្រង់ ភាពយន្តឯកសារស្តីពីមន្ទីរស-២១ ដែលផលិតដោយអាណិកជនខ្មែរសញ្ជាតិបារាំង ឈ្មោះ ប៉ាន់ ឫទ្ធី ត្រូវបានបញ្ចាំងនៅក្នុងសាលប្រជុំធំនៃសាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ២ ។ ខ្សែភាពយន្តនេះ បានបង្ហាញពីសកម្មភាពនៅក្នុងមន្ទីរ ស-២១អំពី ៖ ការសួរចម្លើយ ការផ្ទៀងឯកសារចម្លើយសារភាព ដែលធ្វើឡើងដោយបង្ខំ ការធ្វើទារុណកម្ម ភាពមន្ទិលសង្ស័យ ការសម្ងាត់ និងការសម្លាប់ ។ ការជ្រើសរើសខ្សែភាពយន្តនេះ មកបញ្ចាំងគឺ ដើម្បីបង្ហាញពីអតីតអ្នកទោសមន្ទីរស-២១ដែល មកទស្សនាមន្ទីរគុកទួលស្លែងនិងបាននិយាយជាមួយអតីតឆ្មាំគុក របស់មន្ទីរគុកទួលស្លែងនេះ ។ ទិដ្ឋភាពដែលជនរងគ្រោះប្រឈម មុខជាមួយជនដៃដល់ គឺជាទិដ្ឋភាពដែលគួរឲ្យចងចាំសម្រាប់អ្នក ភូមិ ៖ អតីតអ្នកទោស និយាយថា វាជាការពិបាកណាស់សម្រាប់ គាត់ក្នុងការអនុគ្រោះឲ្យនរណាម្នាក់ដែលមិនទាន់បានសារភាពនូវ បទល្មើសរបស់ខ្លួនផងនោះ ។ អតីតជាងគំនូររបស់ ប៉ុល ពត ក៏បានចូលរួមនៅក្នុងខ្សែភាពយន្តនេះដែរ ហើយគាត់បានរៀប រាប់ពីរបៀបដែលគាត់ត្រូវបានបញ្ជាឲ្យគូររូប ប៉ុល ពត យ៉ាងណា ឲ្យទឹកមុខមើលទៅឃើញស្រទន់ ។ បច្ចុប្បន្ន ជាងគំនូររូបនេះបាន គូររូបអំពីអំពើហិង្សានិងភាពសាហាវឃោរឃៅដែលបានកើត ឡើងនៅក្នុងមន្ទីរសន្តិសុខនេះ ។

សកម្មភាពសំខាន់សម្រាប់ថ្ងៃច័ន្ទនេះត្រូវបញ្ចប់ដោយការ ទស្សនាវាលពិឃាតបឹងជើងឯកនៅម៉ោង៤និង៣០នាទីរសៀល ។ វាលពិឃាតបឹងជើងឯក គឺជាទីតាំងដែលគ្របដណ្តប់ដោយរណ្តៅ សពរួមជាច្រើន ។ បន្ទាប់ពីអ្នកទោសត្រូវបានសួរចម្លើយនៅ មន្ទីរស-២១ អ្នកទោសទាំងនោះនឹងត្រូវដឹកជញ្ជូនតាមឡាន យកមកសម្លាប់នៅទីនេះ ។ ប្រសិនបើមិនមានផ្លាកសញ្ញាបង្ហាញ ពីការសម្លាប់តាមរបៀបផ្សេងៗនិងបូជនីយដ្ឋានដ៏ខ្ពស់ត្រដឹម


អដ្ឋិធាតុជនរងគ្រោះនៅវាលពិឃាតបឹងជើងឯក

តម្កល់លលាដ៏ក្បាលរបស់អ្នកស្លាប់អតីតកាលដ៏គួរញញើត របស់ទីតាំងនេះនឹងមិនត្រូវបានដឹងឮឡើយ ។ ក្នុងខណៈដែល អ្នកភូមិដើរជុំវិញបរិវេណនេះ អ្នកភូមិជាច្រើនបានឈរជុំគ្នា នៅជុំវិញមាត់រណ្តៅធំៗ ដែលដុះដោយស្មៅពណ៌បៃតងខ្ចី ។ រណ្តៅសាកសពដែលរួមតូចនេះ គឺជាកន្លែងដែលអ្នកទោស ត្រូវបានកប់ ។ នៅក្នុងដំណាក់កាលទស្សនារណ្តៅសាកសព នេះយើងបានជួបសម្ភាសអ្នកភូមិមួយចំនួន ។ ក្នុងបទសម្ភាសន៍ ជាមួយ ចេន ស្រេង គាត់បានប្រាប់ពួកយើងថា ការចូលរួម ក្នុងដំណើរទស្សនកិច្ចលើកនេះ បាននាំមកនូវការធូរស្បើយ ចំពោះការឈឺចាប់និងទុក្ខវេទនារបស់គាត់ ។ ស្រេង បាន បញ្ចេញទស្សនៈថា តុលាការរកយុត្តិធម៌មិនត្រឹមតែសម្រាប់ ជនរងគ្រោះដែលនៅរស់ប៉ុណ្ណោះទេ ថែមទាំងសម្រាប់ជន រងគ្រោះដែលបានស្លាប់បាត់បង់ជីវិតទៀតផង ។ ជាមួយនឹង ទឹកភ្នែករលីងរលោង ស្រេង ប្រាប់ថា ព្រលឹងសាច់ញាតិរបស់ គាត់និងព្រលឹងរបស់អ្នកដែលបានស្លាប់នៅក្នុងរបបប្រល័យ ពូជសាសន៍ផ្សេងទៀត អាចទៅកាន់សុគតិភពហើយ ។ នៅ ពេលត្រឡប់ទៅភូមិវិញ ស្រេង មានបំណងថានឹងប្រាប់កូនៗ


បន្ទប់សម្រាប់ឃុំខ្លួនជនជាប់ចោទនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា


ប្រជាជនក្នុងអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា


ប្រជាជនក្នុងអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នូវអ្វីដែលគាត់បានឃើញ ប៉ុន្តែនេះជាការពិបាកសម្រាប់គាត់ក្នុងការចែករំលែកនូវបទពិសោធន៍ដ៏ឈឺចាប់ជាមួយកូនៗ ហើយក៏ជាការលំបាកក្នុងការធ្វើឲ្យកូនៗជឿគាត់ដែរ ។ ដំណើរដ៏វែងឆ្ងាយបានបញ្ចប់ជាមួយអាហារពេលល្ងាចនៅភោជនីយដ្ឋានស៊ីងមាស ។

ថ្ងៃទី២នៃដំណើរទស្សនកិច្ចនេះ ជាសកម្មភាពដែលបានរៀបចំទុកដ៏សំខាន់មួយ ៖ ទស្សនាទីតាំងអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជួបជាមួយមន្ត្រីសំខាន់របស់តុលា-ការ ។ លោក រាជ សម្បត្តិ អ្នកនាំពាក្យរបស់តុលាការ លោក ភីតធ័រ ហ្វូសធ័រ មន្ត្រីកិច្ចការសាធារណៈ និងលោក វ៉ាន់ថាន់ ពៅដារ៉ា បានផ្តល់នូវការបកស្រាយលើនីតិវិធីច្បាប់និងសមាសភាពដែលត្រូវចូលរួមក្នុងអង្គជំនុំជម្រះ (ដូចជា ចៅក្រម ព្រះរាជអាជ្ញានិងចុងចោទ) ។ នៅក្នុងបន្ទប់សវនាការដែលមានកៅអីគ្រប់គ្រាន់សម្រាប់មនុស្ស ៥០០នាក់ អ្នកភូមិស្តាប់យ៉ាងយកចិត្តទុកដាក់ និងចោទសំណួរឡើងជាបន្តបន្ទាប់ ។ ក្រៅពីសំណួរដែលសួរពីរបបប្រល័យពូជសាសន៍ និងអង្គជំនុំជម្រះវិសាមញ្ញ បរិយាកាសនៅក្នុងបន្ទប់សវនាការមានសភាពរស់រវើក ។ លោក រាជ សម្បត្តិ បានពន្យល់យ៉ាងច្បាស់អំពីចំណុចសាំញ៉ាំដើម្បីឲ្យអ្នកភូមិយល់បាន ។ លោកបានលើក រឿងតុលាការចម្រុះនិងពាក្យបច្ចេកទេស ច្បាប់មក

និយាយលាយឡំនឹងរឿងកំប្លែងដើម្បីបង្កើតជាចំណុចងាយយល់ និងសំរាយអត្ថន័យផ្នែកច្បាប់ ។ អ្នកភូមិកោតសសើរចំពោះភាពរួសរាយរាក់ទាក់របស់លោក ភីតធ័រ ហ្វូសធ័រ ក្នុងពេលលោកឆ្លើយសំណួរ ។ ចំណែក វ៉ាន់ថាន់ ពៅដារ៉ា ដែលមានចំណេះដឹងស៊ីជម្រៅពីការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជាក់អ្នកភូមិអំពីតួនាទីដ៏សំខាន់របស់ក្រុមគាត់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងអំពីកិច្ចខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការចងក្រងប្រវត្តិសាស្ត្រនៃរបបប្រល័យពូជសាសន៍ ។ លោកស្រី ហេឡែន ចារីស ប្រធានផ្នែកកិច្ចការសាធារណៈរបស់សាលាក្តី បានបង្ហាញមុខក្នុងរយៈពេលខ្លី ដើម្បីស្វាគមន៍និងណែនាំខ្លួនគាត់ដល់អ្នកភូមិ ។ នៅចុងបញ្ចប់នៃសកម្មភាពនេះ អ្នកភូមិមួយចំនួនតូច និងដូនជី បានឆ្លៀតឱកាសជួបសន្ទនាជាមួយលោក រាជ សម្បត្តិ និងអរគុណចំពោះការងារដែលគាត់បានធ្វើ (សម្រាប់ប្រជាជន) ។ បន្ទាប់មក វ៉ាន់ថាន់ ពៅដារ៉ា បានផ្តល់នូវសៀវភៅការណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមដើម្បីឲ្យពួកគាត់ចែកជូនក្រុមគ្រួសារនិងអ្នកជិតខាងបន្ទាប់ពីពួកគាត់ត្រឡប់ទៅលំនៅដ្ឋានវិញ ។

ដំណើរទស្សនកិច្ចលើកទី៩នេះ មានការចូលរួមពីភ្នាក់ងារព័ត៌មានចំនួន៧ ។ លោក ដាំង វ៉ូត្រាំង អ្នកថតរូបសញ្ជាតិបារាំងមកពីអូវ៉ាយស្សិន បានចូលរួមថតរូបក្នុងដំណើរទស្សនកិច្ចនេះទាំងពីរថ្ងៃ ។ លោក ចន វីង អ្នកថតរូបសម្រាប់កាសែត ម៉ានុមហ្វូតូ ក៏បានចូលរួមដែរ ។ អ៊ីរីកា ឃីនេត មកពីសារព័ត៌មាន ឌឹខែមបូឌៀដេលីបានសម្ភាសអ្នកភូមិ៥នាក់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២ ដែលអ្នកទាំងនោះជាអតីតអ្នកទោសជាប់ឃុំឃាំងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកភូមិម្នាក់ជាអតីតអ្នកទោសនៅមន្ទីរស-២១ ។ កាសែតជាភាសាបារាំងកាំបូស័រ និងវិទ្យុបារាំង RFI និងមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ក៏បានចូលរួមយកការណ៍ពីសកម្មភាពនៅក្នុងទីតាំងអគារអង្គជំនុំជម្រះដែរ ។ បន្ថែមលើនេះ អ្នកកាសែតសញ្ជាតិអាល្លឺម៉ង់ម្នាក់និងអ្នកកាសែតសញ្ជាតិកាណាដាក៏បានសម្ភាសអ្នកភូមិដោយមានការជួយបកប្រែពីបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងដំណើរទស្សកិច្ចនេះ ។

ក្រៅពីមានបញ្ហាតិចតួច បញ្ហាភស្តុភារ រាប់តាំងពីការដឹកអ្នកភូមិចុះឡើង ការចែកអាហារ ការសម្របសម្រួលជាមួយអ្នកឧទ្ទេសនាម ការផ្ទេរថវិកាចំណាយថ្លៃធ្វើដំណើរឲ្យអ្នកភូមិវិញ ការចែកទស្សនាវដ្តី កូនសៀវភៅ និងអាវយឺតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានដំណើរការទៅយ៉ាងរលូន ។ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគ្រប់រូបមានការប្រុងប្រយ័ត្នជាងពេលមុនក្នុងការផ្ទៀងផ្ទាត់ឈ្មោះអ្នកដែលត្រូវអញ្ជើញមកដើម្បីចៀសវាងការអញ្ជើញឈ្មោះដដែលៗ ។ ក្នុងចំណោមអ្នកភូមិចំនួន៤៣២នាក់ (បុរស២៥១នាក់និងស្ត្រី១៨៧នាក់) ដែលបានចូលរួមមានអ្នកភូមិ១០នាក់មកពីខេត្តព្រៃវែង១៨នាក់មកពីខេត្តកំពង់ចាម ៥នាក់មកពីខេត្តសៀមរាប ២៦នាក់មកពីខេត្តស្វាយរៀង ៣៥នាក់មកពីខេត្តកំពត ៥០នាក់មកពីខេត្តតាកែវ ២១៤នាក់មកពីខេត្តកណ្តាល ១៨នាក់មកពីខេត្តពោធិ៍សាត់ ៦នាក់មកពីក្រុងកែប ១០នាក់ជាដូនជី និង៤០នាក់ទៀតជានិស្សិតមកពីសមាគមយុវសន្តិភាព ។ ទោះបីជាភាគរយនៃចំនួនមនុស្សដែលមានវត្តមានខ្ពស់ជាងចំនួនមនុស្សដែលបានអញ្ជើញសរុបស្មើនឹង៧២ភាគរយក៏ចំនួនអ្នកចូលរួមលើកនេះតិចជាងចំនួនអ្នកចូលរួមដំណើរទស្សនកិច្ចក្នុងខែមុនដែរ ដោយសារប្រជាជនមួយចំនួនជាប់រវល់ទៅចុះឈ្មោះបោះឆ្នោត ។

ក្នុងអំឡុងពេលទស្សនកិច្ច មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកក្រដាសស្ទាបស្ទង់មតិដល់ប្រជាជន ហើយក្រោយពីបញ្ចប់ទស្សនកិច្ចយើងក៏ប្រមូលក្រដាសនេះមកវិញបានចំនួន២២៧សន្លឹក ។ រហូតមកដល់ពេលនេះយើងបានធ្វើការស្ទាបស្ទង់មតិអ្នកភូមិចំនួន៣លើកហើយ ។ ការទៅជួបអ្នកភូមិឡើងវិញនឹងត្រូវធ្វើឡើងក្នុងពេលឆាប់ៗនេះ ដើម្បីស្ទាបស្ទង់អំពីលទ្ធផលនៃដំណើរទស្សនកិច្ច ។ បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជានឹងពាំនាំអំពីដំណើរវិវត្តន៍របស់តុលាការប្រាប់អ្នកភូមិ ហើយនិងធ្វើការជ្រើសរើសអ្នកភូមិដែលមានចំណាប់អារម្មណ៍នៅក្នុងវគ្គអប់រំដើម្បីយកមកបំប៉ននៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលនឹងពន្យល់ថាតើសវនាការតុលាការនឹងដំណើរការទៅយ៉ាងដូចម្តេចខ្លះ ។

**វ៉ែង ជាស៊ីល**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

“ការិយាល័យព័ត៌មានសាធារណៈ” មានផ្តល់ជូននូវសេវា៣យ៉ាង ៖

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អែម សុខឃីម តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។



ឯកឧត្តម ម៉ោញ សាផាន, ស្ល ប៊ុនស៊ូ និងបុគ្គលិកស្ម័គ្រចិត្តផ្នែកច្បាប់ នៅក្នុងវគ្គហ្វឹកហ្វឺនផ្នែកច្បាប់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា



ក្រុមនិស្សិតដែលបានចូលរួមវគ្គហ្វឹកហ្វឺនផ្នែកច្បាប់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា

# ឧក្រិដ្ឋកម្មដែលវិនិច្ឆ័យដោយអង្គជំនុំជម្រះវិសាមញ្ញ

បើតាមទស្សនៈច្បាប់នយោបាយ និងការអនុវត្តជាក់ស្តែង ការកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម គឺជាការងារដ៏លំបាក ។ បទឧក្រិដ្ឋជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិងអំពើព្រៃផ្សៃជាច្រើនទៀតដែលប្រព្រឹត្តឡើងដោយមន្ត្រីនិងកម្មាភិបាលខ្មែរក្រហមនៅមុននិងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ មិនអាចយកមកកាត់សេចក្តីបាន ។ ជំពូកនេះនឹងបកស្រាយអំពីដែនយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលបង្ហាញពីដែនកំណត់សមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានកំណត់ឲ្យធ្វើការផ្តោតការយកចិត្តទុកដាក់ទៅលើដំណើរការនៃការដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋសំខាន់ៗមួយចំនួនដែលជនជាប់ចោទសំខាន់ៗមួយក្រុមតូចបានប្រព្រឹត្តក្នុងអំឡុងពេលដ៏វែងឆ្ងាយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។

បន្ទាប់មក ជំពូកនេះនឹងធ្វើការពិភាក្សាយ៉ាងស៊ីជម្រៅទៅលើ“យុត្តាធិការតាមបទល្មើស”របស់តុលាការ ដោយធ្វើការពិភាក្សាទៅលើបទឧក្រិដ្ឋជាក់លាក់មួយចំនួនដែលតុលាការអាចវិនិច្ឆ័យទោសបាន ។ វិសោធនកម្មលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុញ្ញាតឲ្យតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនូវបទឧក្រិដ្ឋជាតិនិងអន្តរជាតិចំនួនប្រាំបី ។ បទឧក្រិដ្ឋទាំងនេះរួមមាន អំពើមនុស្សឃាត អំពើទារុណកម្ម ការធ្វើទុក្ខបុកម្នេញខាងសាសនា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកមសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ និងឧក្រិដ្ឋកម្មប្រឆាំងនឹងជនដែលត្រូវបានការពារជាអន្តរជាតិ ។ ជំពូកនេះក៏នឹងធ្វើការបកស្រាយយ៉ាងច្បាស់លាស់ស្តីអំពី“ធាតុផ្សំ”នៃបទល្មើសដែលមានជាអំពើនិងចេតនា ដែលព្រះរាជអាជ្ញាត្រូវបង្ហាញដើម្បីធានាទៅដល់ការចោទប្រកាន់របស់ខ្លួន ដើម្បីបង្ហាញពីនីត្យានុកូលភាព (ដែលត្រឹមត្រូវតាមច្បាប់) សំខាន់ៗមួយចំនួន ដែលតុលាការត្រូវប្រឈមមុខដោះស្រាយ ។ របៀបដែលចៅក្រមបកស្រាយច្បាប់និងកំណត់បទឧក្រិដ្ឋនីមួយៗដែលនឹងពិតជាមានការប៉ះពាល់ទៅដល់រយៈពេលរឿងក្តីដែលព្រះរាជអាជ្ញានិងមេធាវីការពារក្តីត្រូវបង្ហាញនៅក្នុងតុលាការ ។

ផ្នែកចុងក្រោយនៃជំពូកនេះនឹងពិភាក្សាអំពីបញ្ហាការពារខ្លួនតាមផ្លូវច្បាប់ ដោយការរៀបរាប់ប្រភេទនៃបណ្តឹងតវ៉ាដែលជនជាប់ចោទនឹងត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការបង្ហាញនូវនិទ្ទោសភាពរបស់ខ្លួន ។ ការការពារខ្លួនទាំងនេះ គឺមានសារសំខាន់ក្នុងការធានាឲ្យបាននូវភាពត្រឹមត្រូវនៃសវនាការ និងបង្ការ ការដាក់បន្ទុំឲ្យទទួលយកអំពើអយុត្តិធម៌ដែលប្រជាជនកម្ពុជាស្លូតត្រង់ជាច្រើនបានទទួលរងនូវការឈឺចាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## ដែនយុត្តាធិការ

ទោះបីជាសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមជាការបង្ហាញការដាក់ឲ្យមានការទទួលខុសត្រូវខ្ពស់បំផុតនៅក្នុងប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ក៏ដោយ ក៏តុលាការនេះត្រូវមានដែនយុត្តាធិការកំណត់ជាចាំបាច់លើការរំលោភបំពានមួយចំនួនដែលនៅតែញាំញីប្រជាជនកម្ពុជា ។ អំឡុងពេលសង្គ្រាមត្រជាក់ប្រទេសកម្ពុជាមានជម្លោះនយោបាយនិងយោធា ។ នៅចន្លោះឆ្នាំ១៩៧០ និងឆ្នាំ១៩៧៥ ក្នុងខណៈពេលដែលសង្គ្រាមនៅវៀតណាមបានជ្រាបចូលតាមព្រំដែននៃប្រទេសកម្ពុជា សង្គ្រាមស៊ីវិលដ៏ខ្លាំងក្លាមួយបានផ្ទុះឡើងរវាងពួកឧទ្ទាមខ្មែរក្រហមឆ្វេងនិយម និងរបបអភិរក្សបម្រើពួកផ្តាច់ការ(របបលន់នល់) ។ អំណាចរបស់បរទេសមានការពាក់ព័ន្ធគ្នាយ៉ាងស្មុគស្មាញ ហើយការរំលោភបំពានសិទ្ធិមនុស្សមានលើភាគីជម្លោះទាំងអស់ ។

ឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យបានកើតឡើងបន្ទាប់ពីខ្មែរក្រហមបានផ្តួលរំលំរបប លន់ នល់ ហើយខ្មែរក្រហមបានធ្វើវិសុទ្ធកម្មនយោបាយ និងបានជម្លៀសប្រជាជនចេញពីទីក្រុង ។ ផែនការរ៉ាឌីកាល់លុបបំបាត់ឥទ្ធិពលបរទេសនៅក្នុងប្រទេសកម្ពុជានិងផែនការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចខ្លួនទីពឹងខ្លួនរបស់ខ្មែរក្រហម គឺជាមូលដ្ឋាននាំឲ្យមានការឈឺចាប់បំផុតនៃសតវត្សរ៍ទី២០ ។

ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជានៅពុំទាន់មានសន្តិភាពនៅឡើយទេ ។ មួយទសវត្សរ៍ក្រោយឆ្នាំ១៩៧៩ គេឃើញមានការលេចពុះឡើងជាថ្មីនូវការចាប់អារម្មណ៍របស់អន្តរជាតិមកលើប្រទេសកម្ពុជា ក្នុងខណៈពេលដែលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានិងសម្ព័ន្ធមិត្តនៃរបបនេះប្រយុទ្ធប្រឆាំងនឹងក្រុមខ្មាំងខ្មែរក្រហមដែលរស់នៅក្នុងព្រៃ ។ ជាថ្មីម្តងទៀត ការរំលោភបំពានសិទ្ធិមនុស្សរបស់ភាគីទាំងពីរនៅតែកើតមាន ។ ការកាត់សេចក្តីបទល្មើសទាំងនេះក្នុងប្រវត្តិសាស្ត្រកម្ពុជាសម័យទំនើប គឺជាកិច្ចការដ៏សំខាន់បំផុតមួយ ហើយមានប្រទេសមួយចំនួនតូច ដែលមានដំណើរការកាត់សេចក្តីរបៀបនេះ ។

## យុត្តាធិការពេលវេលា

ដោយហេតុនេះ សាលាជម្រះក្តីមេដឹកនាំមានរយៈពេលកំណត់ដែលមាននៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ។ ដែនយុត្តាធិការទីមួយនេះ គឺទាក់ទិននឹងរយៈពេលនៃអំពើឧក្រិដ្ឋកម្មដែលបានកើតឡើង ។ យុត្តាធិការនេះត្រូវបានហៅថា យុត្តាធិការដោយពេលវេលារបស់តុលាការ ។ នៅក្នុងមាត្រា១-៨ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមខាងមុខនេះនឹងធ្វើការជំនុំជម្រះក្តីអំពើឧក្រិដ្ឋកម្មដែលបានកើតឡើងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩តែប៉ុណ្ណោះ ។ ដើម្បីចាប់ផ្តើមការកាត់សេចក្តីនៅអង្គជំនុំជម្រះវិសាមញ្ញ ព្រះរាជអាជ្ញាត្រូវតែបង្ហាញថា ឧក្រិដ្ឋកម្មបានកើតឡើងក្នុងអំឡុងពេលដូចខាងលើ ។ ទោះបីជាខ្មែរក្រហមបានប្រព្រឹត្តខុសច្បាប់នូវបទឧក្រិដ្ឋកម្មមុននិងក្រោយរយៈកាលនោះក៏ដោយ ក៏ភាពស្មុគស្មាញខាងនយោបាយក្នុងការវិនិច្ឆ័យទោសឧក្រិដ្ឋកម្មក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ និងឆ្នាំ១៩៨០ នៅតំបន់ឥណ្ឌូចិនធ្វើឲ្យការកំណត់ពេលវេលានេះមានភាពចាំបាច់ខាងនយោបាយ ។

## យុត្តាធិការបុគ្គល

បញ្ហាសំខាន់ទីពីរនៃដែនយុត្តាធិការរបស់តុលាការ ដែលជាបញ្ហាវិវាទដែលកើតចេញពីទស្សនៈនយោបាយនោះ គឺដែនយុត្តាធិការបុគ្គល ដែលកំណត់បុគ្គលដែលតុលាការអាចកាត់ទោសពីបទឧក្រិដ្ឋ ។ ព្រះរាជអាជ្ញានឹងពុំមានសិទ្ធិអំណាចវិនិច្ឆ័យទោសជនដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទឧក្រិដ្ឋក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនេះឡើយ ។ ផ្ទុយទៅវិញ ក្នុងមាត្រា១និងមាត្រា២នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញមានសមត្ថកិច្ចត្រឹមតែកាត់សេចក្តី"មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ" និង"ខ្លួនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះបទឧក្រិដ្ឋ ។ កម្មាភិបាលខ្មែរក្រហមថ្នាក់ទាបនិងកណ្តាល ទំនងជាមិនត្រូវបានតុលាការធ្វើការស៊ើបអង្កេតនិងចោទប្រកាន់នោះទេ ដូចដែលបានពិភាក្សានៅក្នុងជំពូកមួយ ។

ដែនយុត្តាធិការបុគ្គលនៅតែមានភាពខ្វែងគំនិតគ្នា ។ រាជរដ្ឋាភិបាលកម្ពុជាអះអាងថា ការកាត់សេចក្តីជនជាប់ចោទជាច្រើនរបស់តុលាការអាចនាំមានភាពអាម៉ាស់ខាងនយោបាយអស្ថិរភាពនិងការវិលត្រឡប់មកវិញត្រូវសង្គ្រាមស៊ីវិល ។ ក្រុមអ្នកវិភាគដែលគាំទ្រគោលជំហរនេះអះអាងថា ជនដែលនៅថ្នាក់ក្រោមពីមន្ត្រីកំពូលគួរតែកាត់ទោសដោយតុលាការធម្មតារបស់ប្រទេសកម្ពុជា ដោយសារប្រទេសកម្ពុជាមានប្រព័ន្ធតុលាការពុំទាន់ពេញលេញនិងមានធនធាននៅស្ងួចស្ដើងនៅឡើយ ទើបមិនមានការកាត់សេចក្តីមន្ត្រីថ្នាក់ទាបនិងកណ្តាល ។ ដោយហេតុនេះ ពួកអ្នករិះគន់គោលជំហររបស់រាជរដ្ឋាភិបាលកម្ពុជាគាំទ្រឲ្យមានការកាត់ទោសជនជាប់ចោទឲ្យធំទូលាយ នៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ ។

## យុត្តាធិការបទល្មើស

ជាចុងក្រោយ ដែនយុត្តាធិការនៃបទល្មើសរបស់តុលាការកំណត់ទៅលើប្រភេទនៃបទឧក្រិដ្ឋដែលតុលាការអាចវិនិច្ឆ័យទោសបាន ។ ការរឹតបន្តឹងដ៏សំខាន់នេះ កំណត់ឲ្យអង្គជំនុំជម្រះវិសាមញ្ញកាត់សេចក្តីនូវបទឧក្រិដ្ឋជាក់លាក់តែមួយចំនួនប៉ុណ្ណោះ ទោះបីជាមានការចោទប្រកាន់ផ្សេងៗទៀតជាច្រើនក៏ដោយ ។ ជាថ្មីម្តងទៀត ការបង្កើតសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនេះគឺជាប្រធានបទដែលត្រូវបានពិចារណានៅលើការអនុវត្តថា ការកាត់ទោសបទឧក្រិដ្ឋកាន់តែច្រើនអាចនឹងធ្វើឲ្យដំណើរការកាត់សេចក្តីមានភាពស្មុគស្មាញព្រមទាំងប្រើប្រាស់ពេលវេលា

និងធនធានជាច្រើនផងដែរ ។ ដូចនេះក្រុមអ្នកធ្វើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចិត្តធ្វើការកាត់សេចក្តីតែបទល្មើសធ្ងន់ធ្ងរបំផុតដូចក្រុមស្ថាបនិកដែលតុលាការចម្រុះនិងអន្តរជាតិធ្លាប់ធ្វើ ។

ដូចដែលបានពិភាក្សាយ៉ាងលម្អិតខាងក្រោមនេះ អង្គជំនុំជម្រះវិសាមញ្ញមានសមត្ថកិច្ចកាត់សេចក្តីបទឧក្រិដ្ឋចំនួនប្រាំបីដែលប្រព្រឹត្តឡើងដោយមនុស្សមួយចំនួនក្នុងរយៈកាលនោះតែប៉ុណ្ណោះ ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អនុញ្ញាតឲ្យតុលាការមានសិទ្ធិអំណាចកាត់សេចក្តីបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិចំនួន៥ រួមមាន អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មបំផ្លាញសម្បត្តិវប្បធម៌ និងឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលដែលត្រូវបានការពារដោយអន្តរជាតិ ។ មាត្រា៣នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏អនុញ្ញាតឲ្យតុលាការមានសិទ្ធិអំណាចកាត់សេចក្តីឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិដែរ គឺមនុស្សឃាត អំពើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញសាសនាក្រោមច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។

*គោលការណ៍គ្មានបទឧក្រិដ្ឋបើគ្មានច្បាប់ចែង*

មុនការពិនិត្យអំពើឧក្រិដ្ឋកម្មដែលមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វាមានសារសំខាន់ខ្លាំងណាស់ក្នុងការស្វែងយល់អំពីអត្ថន័យនៃគោលការណ៍គ្មានបទឧក្រិដ្ឋបើគ្មានច្បាប់ចែង (nullum crimen sine lege) ។ គោលការណ៍នេះចែងថា ពុំមានបុគ្គលណាម្នាក់ត្រូវបានកាត់ទោសពីបទឧក្រិដ្ឋដែលមិនមានចែងនៅក្នុងច្បាប់នៅពេលដែលបុគ្គលនោះបានប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ ។ ភាគច្រើននៃប្រព័ន្ធច្បាប់ពិភពលោកអនុវត្តគោលការណ៍នេះក្នុងគោលបំណងធានានូវសិទ្ធិរបស់បុគ្គល ។ គោលការណ៍គ្មានបទឧក្រិដ្ឋបើគ្មានច្បាប់ចែងមានសារសំខាន់យ៉ាងខ្លាំងសម្រាប់សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ពីព្រោះគោលការណ៍នេះមានន័យថាមេដឹកនាំខ្មែរក្រហមអាចត្រូវបានរកឃើញថាមានទោសកំហុសតែលើបទឧក្រិដ្ឋនៅចន្លោះឆ្នាំ១៩៧៥-៧៩តែប៉ុណ្ណោះ ថែមទាំងចែងថា អង្គជំនុំជម្រះវិសាមញ្ញត្រូវតែកំណត់និយមន័យឧក្រិដ្ឋកម្ម ដូចជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយអនុលោមទៅតាមច្បាប់អន្តរជាតិ នៅចុងទសវត្សរ៍ឆ្នាំ១៩៧០ ។

*ការទទួលខុសត្រូវដោយផ្ទាល់និងថ្នាក់លើ*

មុនការពិភាក្សាឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វាក៏មានសារសំខាន់ផងដែរដោយកត់សម្គាល់ថាជនជាប់ចោទអាចនឹងត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្តដោយការទទួលខុសត្រូវដោយផ្ទាល់ឬថ្នាក់លើ ។ នៅក្នុងមាត្រា២៩នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការទទួលខុសត្រូវដោយផ្ទាល់កំណត់ថា ជនជាប់ចោទ "មានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្ត" ឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងច្បាប់នេះ ។ ដូចនេះ ជនជាប់ចោទមិនចាំបាច់ប្រព្រឹត្តឧក្រិដ្ឋកម្មដោយខ្លួនឯងផ្ទាល់ ក៏ត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែរ ។ ច្បាប់ស្តីពីការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរ៉្វាន់ដា (ICTY and ICTR) មានចែងបទបញ្ញត្តិជាច្រើនដែលស្រដៀងគ្នាទៅនឹងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះដែរ ។ គោលការណ៍នេះគឺសំខាន់ណាស់ ពីព្រោះគេជឿជាក់ថា ជាទូទៅមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមិនបានប្រព្រឹត្តអំពើព្រៃផ្សៃដោយខ្លួនឯងផ្ទាល់នោះទេ ។ ការពិភាក្សាគ្នារវាងព្រះរាជអាជ្ញានិងមេធាវីការពារក្តីទំនងជាពិនិត្យជុំវិញ បញ្ហាថាតើជនជាប់ចោទបានបញ្ជា មានផែនការ ឬជួយនិងជំរុញរៀបចំផែនការឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់របស់ខ្លួនដែរឬទេ ។

ការទទួលខុសត្រូវរបស់ថ្នាក់លើនឹងអាចអនុវត្តទៅបាន ក្នុងករណីដែលជនជាប់ចោទត្រូវបានរកឃើញថាជាប់ពាក់ព័ន្ធបទឧក្រិដ្ឋកម្មដោយមិនបានធ្វើឬចូលរួមធ្វើ ។ មាត្រា២៩នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថាជនជាប់ចោទអាចទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្ត

ដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួន ប្រសិនបើជនជាប់ចោទ "បានបញ្ជានិងគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព ឬមានអំណាចគ្រប់គ្រងអ្នកនៅក្រោមបង្គាប់...ដោយបានដឹងថាអ្នកនៅក្រោមបង្គាប់ប្រព្រឹត្តឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ និងមិនបានចាត់វិធានការចាំបាច់និងសមហេតុផលដើម្បីបង្ការអំពើបែបនេះ ឬដើម្បីផ្តន្ទាទោសឧក្រិដ្ឋជន" ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិ បានអនុម័តនូវគោលការណ៍តែមួយដូចគ្នា ។ ក៏ប៉ុន្តែគេមិនបានដឹងច្បាស់ថា គោលការណ៍នេះស្ថិតនៅក្រោមច្បាប់អន្តរជាតិនៅក្នុងឆ្នាំ១៩៧៥ដែរឬយ៉ាងណានោះទេ ។ ទោះបីជាតុលាការនៅនូរឹមប៊ឺក បានបង្កើតឲ្យមានការទទួលខុសត្រូវរបស់ថ្នាក់លើចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធអន្តរជាតិក៏ដោយ ក៏នៅពុំច្បាស់លាស់ថា តើការទទួលខុសត្រូវរបស់ថ្នាក់លើនោះបានអនុវត្តចំពោះឧក្រិដ្ឋកម្មនៅក្រៅបរិបទនោះដែរឬយ៉ាងណា ។ ប្រសិនបើសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមកំណត់ថា ច្បាប់នេះមិនបានអនុញ្ញាតឲ្យមានការចោទប្រកាន់ដោយផ្អែកទៅលើគោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងឆ្នាំ១៩៧៥ ព្រះរាជអាជ្ញាត្រូវតែស្វែងរកភស្តុតាងសំខាន់ឲ្យបានច្រើនយកមកបង្ហាញ ។

ខ្សែបន្ទាត់រវាងការទទួលខុសត្រូវដោយផ្ទាល់និងរបស់ថ្នាក់លើ តែងតែមានភាពស្រពេចស្រពិល ដោយសារតែការបញ្ជានិងផែនការស្ថិតនៅក្នុងការសមគំនិតនិងការដឹងខ្លួនមិនបានចូលរួមប្រព្រឹត្ត ។ នៅក្នុងអង្គការចាត់តាំងដ៏ធំនិងស្មុគស្មាញ ដូចជារបបកម្ពុជាប្រជាធិបតេយ្យជាដើម មន្ត្រីគ្រប់ថ្នាក់ដែលត្រូវបានដកចេញពីការដឹកនាំរបស់បក្សនោះ ទំនងជាបានប្រព្រឹត្តអំពើទាំងឡាយដែលត្រូវបានហាមឃាត់ដែលទាក់ទិននឹងការបញ្ជានិងផែនការមិនច្បាស់លាស់តាមរយៈការិយាល័យធិបតេយ្យដែលមានច្រើនថ្នាក់នោះ ។ ប្រការដែលមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ជាឲ្យប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ឬប្រការដែលមេដឹកនាំទាំងនេះ គ្រាន់តែបានដឹងនូវបទឧក្រិដ្ឋនិងមិនបានធ្វើឲ្យអង្គជំនុំជម្រះវិសាមញ្ញមានការលំបាកក្នុងការស្វែងរកភស្តុតាង ។ ក៏ប៉ុន្តែ ការទទួលខុសត្រូវដោយផ្ទាល់និងការទទួលខុសត្រូវរបស់ថ្នាក់លើជាទូទៅមិនមែនជារឿងដាច់ដោយឡែកទាំងស្រុងនោះទេ ហើយព្រះរាជអាជ្ញានឹងប្រហែលជាអាចធ្វើការចោទប្រកាន់ជនជាប់ចោទដោយផ្អែកលើហេតុផលទាំងពីរបាន ។

## ធាតុផ្សំនៃបទឧក្រិដ្ឋដែលត្រូវធ្វើការកាត់សេចក្តី

រាល់ឧក្រិដ្ឋកម្មជាតិនិងអន្តរជាតិសុទ្ធតែមានធាតុផ្សំទាំងអស់ ។ ធាតុទាំងនេះជាផ្នែកដ៏សំខាន់នៃឧក្រិដ្ឋកម្មដែលធាតុនីមួយៗ ត្រូវបានបង្ហាញដើម្បីធានានូវការចោទប្រកាន់ ។ ស្ទើរតែឧក្រិដ្ឋកម្មទាំងអស់តម្រូវឲ្យព្រះរាជអាជ្ញាបង្ហាញថា ជនជាប់ចោទបានប្រព្រឹត្តការហាមប្រាមលើរូបរាងកាយ ។ ធាតុនេះជា "ធាតុផ្សំសម្ភារៈ" នៃបទឧក្រិដ្ឋដែលជាទូទៅទាក់ទិននឹងការសម្ងាប់ ការធ្វើឲ្យមានរបួសឬការប្រព្រឹត្តដោយខុសច្បាប់ទៅលើជនរងគ្រោះ ។ ម្យ៉ាងទៀត ក្នុងការចោទប្រកាន់ជនជាប់ចោទ ព្រះរាជអាជ្ញាត្រូវបង្ហាញថាជនជាប់ចោទបានប្រព្រឹត្តអំពើទាំងនេះដោយចេតនា ។ នេះជា "ធាតុផ្សំចេតនា" នៃបទឧក្រិដ្ឋដែលទាក់ទិននឹងចេតនាបង្កឲ្យមានផលប៉ះពាល់ទៅដល់មនុស្សមួយក្រុម ឬបុគ្គលណាម្នាក់ ឬការធ្វើមិនដឹងមិនឮនឹងការរំលោភបំពានដោយខុសច្បាប់របស់អ្នកនៅក្រោមបង្គាប់ ។ ចំពោះអំពើឧក្រិដ្ឋកម្មអន្តរជាតិមួយចំនួនព្រះរាជអាជ្ញាក៏ត្រូវបំពេញនូវធាតុបន្ថែមនៃបទឧក្រិដ្ឋចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់អន្តរជាតិ ដូចជា "ឧក្រិដ្ឋកម្មសង្គ្រាម" ដែលបានកើតឡើងនៅក្នុងរយៈកាលនៃជម្លោះប្រដាប់អាវុធ ។ ប្រសិនបើ ព្រះរាជអាជ្ញាអាចបង្ហាញនូវធាតុនីមួយៗ ចៅក្រមអាចនឹងធ្វើការចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋបាន ។ ផ្ទុយទៅវិញ ប្រសិនបើព្រះរាជអាជ្ញាមិនបានបំពេញឲ្យបាននូវគ្រប់ធាតុផ្សំទាំងអស់នៃបទឧក្រិដ្ឋទេ ចៅក្រមត្រូវចេញសាលក្រមសម្រេចមិនដាក់ទោសជនជាប់ចោទ ។

## ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍

មាត្រា៤នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុញ្ញាតឲ្យអង្គជំនុំជម្រះវិសាមញ្ញកាត់សេចក្តីអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អន្តរជាតិ ។ អំពើឧក្រិដ្ឋកម្មមួយត្រូវបានចាត់ទុកជាអំពើប្រល័យពូជសាសន៍ លុះត្រាតែបុគ្គលណាម្នាក់ប្រព្រឹត្តអំពើដែលត្រូវបានហាមឃាត់លើរូបរាងកាយ

ដោយមានចេតនាបំផ្លិចបំផ្លាញទាំងស្រុងឬមួយផ្នែកនៃក្រុមជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ» ។ ការតម្រូវចេតនាពិសេសនេះ ជាធាតុដ៏សំខាន់មួយនៃអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ និយមន័យដើមនៃអំពើប្រល័យពូជសាសន៍មានប្រភពមកពីអនុសញ្ញាស្តីពីការបង្ការនិងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ ដែលហៅកាត់ថា អនុសញ្ញាអំពើប្រល័យពូជសាសន៍ ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអនុម័តឲ្យប្រើប្រាស់នូវនិយមន័យចាស់នេះដែលមានចែងនៅក្នុងមាត្រា២នៃអនុសញ្ញាអំពើប្រល័យពូជសាសន៍ ។ ក៏ប៉ុន្តែ មានភាពខុសប្លែកគ្នាក្នុងការចោទប្រកាន់អំពើប្រល័យពូជសាសន៍ ។ មាត្រា៣នៃអនុសញ្ញាអំពើប្រល័យពូជសាសន៍ មានចែងនូវធាតុផ្សំចំនួនប្រាំសម្រាប់ការចោទប្រកាន់គឺ ការប៉ុនប៉ង ការរួមគំនិត ការប្រព្រឹត្តដោយផ្ទាល់ ការញុះញង់ និងការឃុបឃិត ។ ដោយឡែក ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាវិញ មានចែងនូវធាតុផ្សំតែបីប៉ុណ្ណោះសម្រាប់ការចោទប្រកាន់ឧក្រិដ្ឋកម្មគឺ ការប៉ុនប៉ង ការរួមគំនិត និងការចូលរួម ។ ដោយហេតុនេះ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាខុសពីអនុសញ្ញាអំពើប្រល័យពូជសាសន៍ ដោយការលុបចោលនូវធាតុផ្សំចំនួនពីរក្នុងការចោទប្រកាន់គឺ ការញុះញង់ និងការរួមគំនិត និងដោយបញ្ចូលនូវធាតុផ្សំមួយ គឺ«ការចូលរួម» ។

ក្រុមអ្នកធ្វើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ចូលនូវធាតុចោទប្រកាន់ «ការចូលរួម» ដែលគ្របទៅលើរបៀបនៃការប្រព្រឹត្តដោយផ្ទាល់ ការញុះញង់ និងការសមគំនិត បើទោះបីជាគេយល់ឃើញថា សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនឹងជាអ្នកអនុម័តលើការបកស្រាយបទចោទប្រកាន់នេះក៏ដោយ ។ នេះគឺជាបញ្ហាគតិយុត្តិដ៏សំខាន់មួយដោយសារតែមានអ្នកវិភាគជាច្រើនជឿជាក់ថា មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យជាច្រើនអាចនឹងត្រូវបានតុលាការធ្វើការចោទប្រកាន់ពីបទឃុបឃិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ជាជាងបទប៉ុនប៉ងឬសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ការយល់ដឹងរបស់អតីតមេដឹកនាំជាន់ខ្ពស់ទាំងនេះអំពីអំពើប្រល័យពូជសាសន៍នឹងប្រហែលជាមានភាពងាយស្រួលសម្រាប់ព្រះរាជអាជ្ញាបង្ហាញភ័ស្តុតាងជាងការប្រព្រឹត្តជាក់ស្តែងនូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់មេដឹកនាំទាំងនេះ ។ ការមិនរាប់បញ្ចូលនៃបទចោទប្រកាន់ដែលគ្របទៅលើការឃុបឃិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍នឹងជួយទៅដល់មេធាវីការពារក្តី បើទោះបីជាមានសារសំខាន់ក្នុងការកត់សម្គាល់ថាមាត្រា២៩នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពិតជាអនុញ្ញាតឲ្យមានការចោទប្រកាន់លើ«ការជួយនិងការជំរុញក្នុងការរៀបចំ» ប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដែលតុលាការផ្សេងៗទៀតចាត់ទុកថាជាបទល្មើសទាក់ទិននឹងការឃុបឃិត ។

*ធាតុផ្សំសម្ភារៈ* (Physical Element) – *អំពើដែលត្រូវបានហាមឃាត់*

អំពើប្រល័យពូជសាសន៍អាចប្រព្រឹត្តឡើងក្នុងមធ្យោបាយមួយក្នុងចំណោមមធ្យោបាយទាំងប្រាំនេះ គឺការសម្លាប់ទៅលើសមាជិកក្រុម ការធ្វើឲ្យរបួសយ៉ាងធ្ងន់ធ្ងរលើរូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម ការធ្វើដោយចេតនាឲ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងក្នុងគោលបំណងបំផ្លិចបំផ្លាញរាងកាយទាំងស្រុងឬមួយផ្នែក ការដាក់នូវវិធានការនានាដែលមានបំណងរារាំងមិនឲ្យមានការផ្តល់កំណើតទារក និងការបញ្ជូនកុមារដោយបង្ខំចេញពីក្រុមមួយទៅក្រុមមួយផ្សេងទៀត ។ អំពើទាំងនេះមានចែងនៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ហើយជនជាប់ចោទបានប្រព្រឹត្តយ៉ាងហោច អំពើមួយក្នុងចំណោមអំពើទាំងនេះសម្រាប់ការចោទប្រកាន់អំពើប្រល័យពូជសាសន៍ ។ ឯកសារស្តីពីធាតុនៃបទឧក្រិដ្ឋរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមានរៀបរាប់យ៉ាងពិស្តារអំពីលក្ខណៈនៃអំពើដែលត្រូវបានហាមឃាត់ និងបើទោះបីជាឯកសារទាំងនេះមិនត្រូវបានយកមកអនុវត្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក៏ដោយ ក៏ចៅក្រមអាចប្រើប្រាស់ឯកសារនេះសម្រាប់ជាការណែនាំ ។

*ធាតុផ្សំចេតនា* (Mental Element)

ក្នុងការបង្ហាញនូវធាតុផ្សំចេតនានៃអំពើប្រល័យពូជសាសន៍ ព្រះរាជអាជ្ញាត្រូវបង្ហាញថា ជនជាប់ចោទបានប្រព្រឹត្តអំពើមួយ

ក្នុងចំណោមអំពើខាងលើនេះប្រឆាំងនឹងក្រុមដែលទទួលបាននូវការការពារ "ដោយមានចេតនាបំផ្លិចបំផ្លាញទាំងស្រុងឬមួយផ្នែក" នៃក្រុមនោះ ។ និយមន័យអំពើប្រល័យពូជសាសន៍មាននិយាយអំពីក្រុមដែលទទួលបានការការពារចំនួនបួន គឺក្រុមជនជាតិ ជាតិពន្ធុ ពូជសាសន៍ និងសាសនា ។ ព្រះរាជអាជ្ញាត្រូវតែបង្ហាញថា ជនរងគ្រោះជាសមាជិកនៃក្រុមមួយក្នុងចំណោមក្រុមទាំងបួននេះ ដើម្បីធានានូវការចោទប្រកាន់អំពើប្រល័យពូជសាសន៍ ។ វាមិនសំខាន់ទេដែលថា ក្រុមណាមួយផ្សេងទៀតនឹងបំពេញតម្រូវការនៃក្រុមដែលទទួលបានការការពារទៅតាមការកំណត់និយមន័យអំពើប្រល័យពូជសាសន៍ក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ បើទោះបីជាអ្នកច្បាប់និងអ្នកស្រាវជ្រាវមួយចំនួនខិតខំប្រឹងប្រែងបញ្ចូលក្រុមសង្គមនិងសេដ្ឋកិច្ចយ៉ាងណាក៏ដោយ ។

ធាតុផ្សំចេតនានៃអំពើប្រល័យពូជសាសន៍ក៏ចាំបាច់តម្រូវឲ្យបង្ហាញថាអំពើប្រឆាំងនឹងក្រុមដែលទទួលបានការការពារ ត្រូវបានធ្វើឡើង "ដោយមានចេតនាបំផ្លិចបំផ្លាញទាំងស្រុងឬមួយផ្នែក"នៃក្រុមនោះ ។ ដូចនេះ ដោយបានប្រព្រឹត្តអំពើបែបនេះ ជនជាប់ចោទពិតជាមានចេតនាបំផ្លិចបំផ្លាញយ៉ាងហោចណាស់មួយផ្នែកនៃក្រុមនោះ ។ ពាក្យថា "ទាំងស្រុង" មានន័យថា ចេតនាបំផ្លិចបំផ្លាញក្រុមនោះទាំងមូល មិនថាសមាជិកនៃក្រុមនេះរស់នៅទីកន្លែងណានោះទេ ។ រីឯពាក្យ "មួយផ្នែក" មានន័យថា ការបំផ្លិចបំផ្លាញក្រុមដែលរស់នៅក្នុងប្រទេស តំបន់ ទីក្រុង ឬតំបន់តូចៗ ដែលត្រូវបានកំណត់ទុកជាស្រេច បើទោះបីជាសហគមន៍ដែលត្រូវបានកំណត់ទុកជាមុននោះ ជាផ្នែកមួយនៃក្រុមទាំងមូលដែលទទួលបានការការពារក៏ដោយ ។ វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការកត់សម្គាល់ថាចេតនាបំផ្លិចបំផ្លាញក្រុមមួយ "ទាំងស្រុងឬមួយផ្នែក" មិនមែនចាំបាច់តែជាចេតនាតែមួយ ឬទីមួយក្នុងការប្រព្រឹត្តអំពើដែលត្រូវបានហាមឃាត់នោះទេ ។ ចេតនាបែបនោះអាចនឹងរួមផ្សំជាមួយនឹងចំណង់ផ្សេងៗទៀត ក៏ប៉ុន្តែហេតុផលសន្មតរបស់ជនជាប់ចោទចំពោះអំពើរបស់ខ្លួនកាន់តែស្មុគស្មាញ ពេលនោះព្រះរាជអាជ្ញាមានលទ្ធភាពតិចតួចអាចបង្ហាញចេតនាច្បាស់លាស់ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។

មេធាវីអន្តរជាតិមួយចំនួនអះអាងថា មានធាតុទីបីនៃអំពើប្រល័យពូជសាសន៍ ។ ធាតុដែលមានលក្ខណៈចម្រូងចម្រាសនេះចាំបាច់តម្រូវឲ្យអំពើដែលត្រូវបានហាមឃាត់នេះ ជាផ្នែកមួយនៃ"គំរូជាក់ស្តែងនៃការប្រព្រឹត្តដែលមានស្រដៀងគ្នានេះ" ឬជាប្រភេទនៃការប្រព្រឹត្តដែលនាំមកនូវការបំផ្លិចបំផ្លាញក្រុមដែលទទួលបានការការពារ"ទាំងស្រុងឬមួយផ្នែក" ។ ទោះបីជាឯកសារស្តីពីធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិរាប់បញ្ចូលទាំងធាតុប្រភេទទីបីនេះក៏ដោយ ក៏វានៅតែជាបញ្ហាដែលថា សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមចាត់ទុកធាតុនេះជាប្រផ្នូលចាំបាច់មួយក្នុងការស្វែងរកនូវការទទួលខុសត្រូវអំពើប្រល័យពូជសាសន៍ ។ បច្ចុប្បន្ននេះ ពុំទាន់មានមតិយល់ស្របគ្នាច្បាស់លាស់ពីតុលាការ ឬអ្នកស្រាវជ្រាវទៅលើបញ្ហានេះនៅឡើយទេ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញធ្វើការពិភាក្សានូវបញ្ហានេះ តុលាការអាចបង្កើតនូវយុត្តិសាស្ត្រដ៏សំខាន់មួយទៅលើបញ្ហាច្បាប់ដែលពុំទាន់ត្រូវដោះស្រាយ ។

## ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

មាត្រា៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏បានផ្តល់អង្គជំនុំជម្រះវិសាមញ្ញនូវសិទ្ធិអំណាចក្នុងការកាត់សេចក្តីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងអំពើប្រល័យពូជសាសន៍ រួមមានការសម្លាប់រង្គាលនិងបទឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរប្រឆាំងនឹងប្រជាជនដែលកំណត់ទុក ។ ក៏ប៉ុន្តែតាមហេតុផលដែលរៀបរាប់ខាងក្រោមនេះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិកាន់តែមានភាពងាយស្រួលក្នុងការបង្ហាញក្នុងករណីរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាទូទៅ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមានឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារទ្រង់ទ្រាយធំឬជាខ្សែសង្វាក់ទៅលើជនស៊ីវិលដោយហេតុផលនយោបាយ ជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា ។

*ធាតុផ្សំសម្ភារៈ - អំពើដែលត្រូវបានហាមឃាត់*

មានអំពើជាច្រើនដែលអាចនាំឲ្យមានការចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ក៏ប៉ុន្តែ អ្នក

ស្រាវជ្រាវនៅមានមន្ទិលសង្ស័យថាតើ អំពើមួយគ្រប់គ្រាន់សម្រាប់ការចោទប្រកាន់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬថាតើអំពើច្រើនទើបអាចចោទប្រកាន់បទឧក្រិដ្ឋនេះបានឬយ៉ាងណា ។ បញ្ជីរាយឈ្មោះធាតុខាងក្រោមនេះ ដកចេញពីឯកសារស្តីអំពីធាតុផ្សំនៃបទល្មើសនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មានចែងអំពើដែលត្រូវបានហាមឃាត់ដែលអាចនាំឲ្យមានការចោទប្រកាន់អំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

*ការធ្វើមនុស្សឃាត* ៖ ការសម្លាប់មនុស្សម្នាក់ឬច្រើន ។

*ការសម្លាប់រង្គាល* ៖ ការសម្លាប់ឬការធ្វើដោយចេតនានូវស្ថានភាពរស់នៅដែលបានរៀបចំឡើងសម្រាប់ការបំផ្លិចបំផ្លាញប្រជាជនដែលជាផ្នែកមួយនៃការសម្លាប់រង្គាល ។

*ការដាក់ជាទាសករ* ៖ ការអនុវត្តនូវអំណាចទៅលើសិទ្ធិរបស់បុគ្គល (តាមរយៈការទិញ ការលក់ ការខ្ចី ឬការដោះដូរមនុស្ស) ។

*ការនិរទេស* ៖ ការនិរទេសដោយខុសច្បាប់ ឬការបញ្ជូនដោយបង្ខំនូវបុគ្គលដែលជនជាប់ចោទដឹងថាមានការទទួលស្គាល់ដោយច្បាប់ ។

*ការឃុំឃាំង* ៖ ការឃុំឃាំងបុគ្គលម្នាក់ឬច្រើនក្នុងករណីដែលជនជាប់ចោទបានដឹងថា បានរំលោភច្បាប់សំខាន់ៗនៃច្បាប់អន្តរជាតិ ។

*ការធ្វើទារុណកម្ម* ៖ ការបង្កការឈឺចាប់លើរូបរាងកាយ ឬសតិបញ្ញា ឬការធ្វើដោយខុសច្បាប់ចំពោះបុគ្គលដែលនៅក្រោមការគ្រប់គ្រងរបស់ជនជាប់ចោទមានការឈឺចាប់ ។

*ការរំលោភលើផ្លូវភេទ* ៖ ការបំពារបំពានលើផ្លូវភេទរបស់បុគ្គល ឬអង្គភេទដោយប្រើប្រាស់វត្ថុអ្វីមួយ ។ ការប្រព្រឹត្តអំពើបែបនេះដោយបង្ខំ ដោយការគំរាមកំហែង ឬប្រឆាំងនឹងបុគ្គលដែលបដិសេធប្រព្រឹត្តអំពើនេះ ។

*ការធ្វើទុក្ខបុកម្នេញ* ៖ ការដកហូតទាំងស្រុងនូវសិទ្ធិសំខាន់ៗរបស់បុគ្គលម្នាក់ឬច្រើន ដោយសារតែជននោះជាសមាជិកនៃក្រុមនយោបាយ ពូជសាសន៍ ជនជាតិ ជាតិពន្ធ វប្បធម៌ សាសនាភេទ ឬក្រុមផ្សេងៗទៀត ។

*អំពើអមនុស្សធម៌ផ្សេងៗទៀត* ៖ ការបង្កការឈឺចាប់ ឬរបួសយ៉ាងធ្ងន់ធ្ងរទៅដល់ជនរងគ្រោះតាមរយៈអំពើអមនុស្សធម៌ដែលមានចរិតលក្ខណៈស្រដៀងគ្នានឹងអំពើដែលរៀបរាប់ខាងលើ ។

ខុសពីលក្ខន្តិកៈនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលុបចោលនូវទាសភាពផ្លូវភេទ ពេស្យាកម្មដោយបង្ខំ ការបង្ខំឲ្យមានផ្ទៃពោះ ការបង្ខំមិនឲ្យមានការបង្កកំណើត អំពើហិង្សាខាងផ្លូវភេទ ការបាត់ខ្លួនមនុស្សដោយបង្ខំ និងអាប៉ាថេត ចេញពីអំពើដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ក៏ប៉ុន្តែច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាពិតជាបានអនុញ្ញាតឲ្យសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមអាចពិចារណាអំពើទាំងនេះជា«អំពើអមនុស្សធម៌ផ្សេងៗទៀត» ។

*ធាតុបរិបទ-ការវាយប្រហារ«ទ្រង់ទ្រាយធំឬជាខ្សែសង្វាក់»*

ការសម្រេចថា ការវាយប្រហារពិតជាមានលក្ខណៈ«ទ្រង់ទ្រាយធំឬជាខ្សែសង្វាក់»នោះ គឺជាធាតុនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលធ្វើឲ្យឧក្រិដ្ឋកម្មធម្មតាមួយក្លាយជាឧក្រិដ្ឋកម្មអន្តរជាតិ ។ មាត្រា៧នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិបានកំណត់ការវាយប្រហារទ្រង់ទ្រាយធំជាដំណើរការនៃ«ការប្រព្រឹត្តមួយពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើជាច្រើន» និងចាត់ទុកការវាយប្រហារជាខ្សែសង្វាក់ ជាអំពើពាក់ព័ន្ធនឹងឬស្ថិតក្នុងការធ្វើឲ្យជឿនលឿននៅមុខរបស់រដ្ឋមួយឬគោលនយោបាយចាត់តាំងដើម្បីប្រព្រឹត្តការវាយប្រហារបែបនេះ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងរ៉្វាន់ដាកំណត់ថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតម្រូវជាចាំបាច់នូវការវាយប្រហារទ្រង់ទ្រាយធំឬជាខ្សែសង្វាក់ ។ តុលាការទាំងពីរនេះ ផ្តោតការយកចិត្តទុកដាក់ទៅលើវិសាលភាពនៃឧក្រិដ្ឋកម្មដើម្បីកំណត់ថាការវាយប្រហារនេះមានលក្ខណៈទ្រង់ទ្រាយធំ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីចែងថាការវាយប្រហារជាខ្សែសង្វាក់អាស្រ័យទៅលើគោលនយោបាយច្បាស់លាស់ និងការចល័តនូវធនធានក្នុងការអនុវត្តគោលនយោបាយនេះ ។

យើងពុំមានភាពច្បាស់លាស់ទាំងស្រុងថា ការវាយប្រហារទ្រង់ទ្រាយធំឬជាខ្សែសង្វាក់នឹងក្លាយជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅចន្លោះឆ្នាំ១៩៧៥-៧៩នៅឡើយទេ ដោយ

បញ្ហាជនមួយចំនួនអះអាងថាការវាយប្រហារចាំបាច់ត្រូវមានលក្ខណៈទ្រង់ទ្រាយធំនិងជាខ្សែសង្វាក់ ។ ក៏ប៉ុន្តែទស្សនៈដែលសំខាន់នោះ គឺការវាយប្រហារអាចជួយបង្កើនការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រសិនបើការវាយប្រហារនេះជាផ្នែកមួយនៃការវាយប្រហារទ្រង់ទ្រាយធំ ឬត្រូវអនុវត្តតាមគោលនយោបាយចាត់តាំង ។ ប្រសិនបើព្រះរាជអាជ្ញាមិនអាចរកឃើញថា ជនជាប់ចោទបានប្រព្រឹត្តនូវអំពើដែលជាផ្នែកមួយនៃការវាយប្រហារទ្រង់ទ្រាយធំឬជាខ្សែសង្វាក់ ព្រះរាជអាជ្ញាត្រូវបង្ហាញបទល្មើសដែលក្រោមច្បាប់ជាតិដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដើម្បីធានានូវការចោទប្រកាន់របស់ខ្លួន ។

*ធាតុផ្សំនៃក្រុមដែលទទួលបានការការពារ*

ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបញ្ចូលធាតុបន្ថែមមួយទៀតទៅក្នុងនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺធាតុនៃក្រុមដែលទទួលបាននូវការការពារនៅក្នុងបទល្មើសឧក្រិដ្ឋកម្ម ។ ក្រុមដែលទទួលបានការការពារនេះមានចែងក្នុងមាត្រា៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមមានក្រុមជនជាតិ ជាតិពន្ធ នយោបាយ ពូជសាសន៍ឬសាសនា ។ ដោយជាអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការវាយប្រហារពិតជាបានប្រព្រឹត្តឡើងប្រឆាំងនឹងក្រុមមួយក្នុងចំណោមក្រុមទាំងនេះ ។ តុលាការផ្សេងៗទៀត ក្រោយសម័យសង្គ្រាមត្រជាក់ រួមមាន តុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងប្រទេសរ៉្វាន់ដា មិនបានចេញសេចក្តីសម្រេចថា ជនជាប់ចោទមានចេតនារើសអើងចំពោះក្រុមណាមួយក្នុងចំណោមក្រុមទាំងប្រាំនេះទេ ។ តុលាការអាចពិចារណាទៅលើអត្តសញ្ញាណរបស់ជនរងគ្រោះដែលជាផ្នែកមួយនៃលក្ខណៈនៃការវាយប្រហារ ។ សាលាជំនុំជម្រះក្តីខ្មែរក្រហម ក៏អាចបកស្រាយច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងលក្ខណៈស្រដៀងគ្នាទៅនឹងតុលាការទាំងនេះបានដែរ បើទោះជាច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបើកចំហឲ្យចៅក្រមអាចវិនិច្ឆ័យទោសនូវធាតុផ្សំចេតនារើសអើង ដែលជាផ្នែកមួយនៃសតិបញ្ញាប្រព្រឹត្តបទឧក្រិដ្ឋរបស់ជនជាប់ចោទក៏ដោយ ។ ព្រះរាជអាជ្ញាយល់ថា វាមានភាពងាយស្រួលជាងក្នុងការចោទប្រកាន់ជនជាប់ចោទ ហើយមេធាវីការពារក្តីយល់ថាកិច្ចការរបស់ខ្លួននឹងជួបការលំបាកច្រើនក្នុងការការពារកូនក្តីរបស់ខ្លួនពីការចោទប្រកាន់របស់ព្រះរាជអាជ្ញា ប្រសិនបើចៅក្រមមិនបានបង្កើត“ក្រុមដែលទទួលបានការការពារ”ក្នុងការដោះស្រាយបញ្ហាធាតុផ្សំចេតនារើសអើងដែលមានការលំបាកក្នុងការបង្ហាញនូវភ័ស្តុតាង ។

*ធាតុផ្សំចេតនា-ការដឹងនូវសារជាតិនៃការវាយប្រហារ “ទ្រង់ទ្រាយធំឬជាខ្សែសង្វាក់”*

នៅក្នុងបរិបទនៃកម្ពុជាប្រជាធិបតេយ្យ ដោយអាស្រ័យទៅលើនីតិវិធីដែលចៅក្រមធ្វើការបកស្រាយធាតុផ្សំចេតនានៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ធាតុផ្សំចេតនានេះពុំសូវមានការស្មុគស្មាញជាងធាតុផ្សំចេតនានៃការប្រល័យពូជសាសន៍ទេ ។ ដោយមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជនជាប់ចោទពិតជាបានដឹងថាខ្លួនបានចូលរួមក្នុងការវាយប្រហារទ្រង់ទ្រាយធំនិងជាខ្សែសង្វាក់ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងតុលាការព្រហ្មទណ្ឌអន្តរជាតិ បានចែករំលែកនូវគោលការណ៍នេះ ដែលបង្ហាញពីចេតនារបស់ជនជាប់ចោទដែលទាក់ទិននឹងអំពើដែលត្រូវបានហាមឃាត់ ។ ការប្រព្រឹត្តអំពើឧក្រិដ្ឋដោយពុំបានដឹងថាជាផ្នែកមួយនៃការវាយប្រហារទ្រង់ទ្រាយធំ ជាទូទៅ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ ដោយសារតែគ្មានធាតុផ្សំចេតនា ។ នៅក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើមេដឹកនាំខ្មែរក្រហមបានប្រព្រឹត្តនូវបទល្មើស ក៏ប៉ុន្តែមិនបានដឹងថាអំពើព្រៃផ្សៃ ឬគោលនយោបាយដែលខ្លួនប្រព្រឹត្តខុសច្បាប់នោះ មេដឹកនាំទាំងនេះទំនងជាត្រូវបានតុលាការសម្រេចឲ្យរួចទោសពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

## «ឧក្រិដ្ឋកម្មសង្គ្រាម» ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ

មាត្រា៦ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុញ្ញាតឲ្យអង្គជំនុំជម្រះវិសាមញ្ញកាត់សេចក្តីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវទាំងបួន

នៅឆ្នាំ១៩៤៩ ដែលជាសន្ធិសញ្ញាអន្តរជាតិដ៏ល្បីល្បាញនៃអង្គច្បាប់ដែលត្រូវបានហៅថា ច្បាប់មនុស្សធម៌អន្តរជាតិ ។ អនុសញ្ញានេះ ការពារក្រុមមួយចំនួនពីការរំលោភច្បាប់ ដូចជាឈ្លើយសឹកនិងជនស៊ីវិលជាដើម ។ ក៏ប៉ុន្តែ ចុងទសវត្សរ៍ឆ្នាំ១៩៧០ អ្នកប្រាជ្ញភាគច្រើនយល់ថា អនុសញ្ញាទីក្រុងហ្សឺណែវនេះបានអនុវត្តទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងបុគ្គលនៅក្នុងពេលដែលមានជម្លោះប្រដាប់អាវុធអន្តរជាតិ ។ គោលការណ៍នេះអាចកំណត់ជាសំខាន់លើការអនុវត្តច្បាប់ឧក្រិដ្ឋកម្មសង្គ្រាមចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដូចដែលបានពិភាក្សាខាងក្រោម ។

ក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធមិនមែនអន្តរជាតិ មាត្រា៣នៃអនុសញ្ញាទីក្រុងហ្សឺណែវនីមួយៗ ក៏អាចត្រូវបានយកអនុវត្តផងដែរ ។ មាត្រា៣នេះគ្របដណ្តប់ទៅលើគោលការណ៍និងវិធានសំខាន់ៗនៃច្បាប់មនុស្សធម៌អន្តរជាតិ រួមមានការហាមឃាត់ ការធ្វើមនុស្សឃាត ការបង្កការខូចខាត ការប្រព្រឹត្តយ៉ាងឃោរឃៅ ការធ្វើទារុណកម្ម ការចាប់យកធ្វើជាចំណាប់ខ្មាំង ការដេរប្រមាថដល់សេចក្តីថ្លៃថ្នូររបស់បុគ្គល និងកង្វះការជំនុំជម្រះដោយយុត្តិធម៌ ។ អ្នកស្រាវជ្រាវនិងក្រុមចៅក្រមខ្លះអះអាងថា ការរំលោភបំពានលើមាត្រា៣នេះ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ក៏ប៉ុន្តែក្នុងរយៈកាលឆ្នាំ១៩៧៥-៧៩ នេះមិនមែនជាទស្សនៈដែលទទួលបាននូវសំឡេងគាំទ្រភាគច្រើននៅក្នុងច្បាប់អន្តរជាតិទេ ។ ដោយហេតុនេះ សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមទំនងជាមិនជំនុំជម្រះបទឧក្រិដ្ឋកម្មដែលផ្អែកទៅលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលជម្លោះក្នុងស្រុកទេ ។

*ធាតុផ្សំសម្ភារៈ*

អំពើផ្សេងៗមួយចំនួនអាចជាអំពើជាក់ស្តែងដែលត្រូវបានហាមឃាត់មិនឲ្យមានឧក្រិដ្ឋកម្មសង្គ្រាម ។ ឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរួមមាន ការសម្លាប់ដោយចេតនា ការធ្វើទារុណកម្ម ឬការប្រព្រឹត្តដោយអមនុស្សធម៌ និងការធ្វើដោយចេតនាឲ្យមានការឈឺចាប់ ឬរបួសយ៉ាងធ្ងន់ធ្ងរ ។ អំពើមួយចំនួនផ្សេងៗទៀតដែលពាក់ព័ន្ធយ៉ាងច្បាស់នឹងព្រឹត្តិការណ៍នៃជម្លោះប្រដាប់អាវុធ ក៏ត្រូវបានហាមឃាត់ផងដែរ ។ អំពើទាំងនេះរួមមាន ÷

*ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ* ៖ ការបំផ្លិចបំផ្លាញឬការកាន់កាប់ទ្រព្យសម្បត្តិយ៉ាងច្រើន និងគ្មានត្រាប្រណីដោយគ្មានយុត្តិកម្មយោធា ។

*សេវាកម្មដ៏ចាំបាច់សម្រាប់អំណាចរបស់សត្រូវ* ៖ ការបង្ខិតបង្ខំជនណាម្នាក់ឲ្យចូលរួមប្រព្រឹត្តក្នុងប្រតិបត្តិការយោធាប្រឆាំងនឹងប្រទេសរបស់បុគ្គលនោះផ្ទាល់ឬកងកម្លាំងយោធា ។

*ការពុំទទួលបានការជំនុំជម្រះដោយយុត្តិធម៌* ៖ ការមិនអនុញ្ញាតឲ្យបុគ្គលម្នាក់ឬច្រើន ចូលរួមក្នុងដំណើរការជំនុំជម្រះក្តីដោយយុត្តិធម៌និងទៀងទាត់ ដោយបដិសេធនូវការធានាយុត្តិធម៌ដែលមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ។

*ការឃុំឃាំងឬបញ្ជូនដោយខុសច្បាប់* ៖ ការឃុំឃាំងបុគ្គលម្នាក់ឬច្រើនដោយខុសច្បាប់ ឬនិរទេស ឬបញ្ជូនបុគ្គលនេះទៅកាន់រដ្ឋ ឬទីកន្លែងផ្សេងមួយទៀតដោយការបំពានច្បាប់ ។

*ការចាប់ជនស៊ីវិលធ្វើជាចំណាប់ខ្មាំង* ៖ ការចាប់ ការឃុំឃាំង ឬការចាប់ជនស៊ីវិលធ្វើជាចំណាប់ខ្មាំងដោយគំរាមកំហែងថាចំណាប់ខ្មាំងនឹងត្រូវជាប់ឃុំឃាំងបន្ថែម ធ្វើឲ្យមានរបួស ឬត្រូវសម្លាប់ ឬដោយប្រើប្រាស់ចំណាប់ខ្មាំងដើម្បីបង្ខំឲ្យប្រទេសមួយឬអ្នកប្រព្រឹត្តផ្សេងទៀតឲ្យប្រព្រឹត្តតាមជាពិសេស ។

ដើម្បីបង្ហាញពីធាតុផ្សំសម្ភារៈ ជនជាប់ចោទត្រូវតែបានប្រព្រឹត្តអំពើមួយក្នុងចំណោមអំពើខាងលើនេះទៅលើបុគ្គល ឬទ្រព្យសម្បត្តិដែលត្រូវបានការពារដោយអនុសញ្ញាទីក្រុងហ្សឺ-ណែវ ។ ដោយកំណត់ថា បុគ្គលឬទ្រព្យសម្បត្តិ ត្រូវបានការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ ចៅក្រមត្រូវពឹងផ្អែកលើវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិដែលចែងថា បុគ្គលដែលមិនមែនជាយុទ្ធជននិងយោធាទាំងអស់ត្រូវទទួលបានការការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ ។ ជាទូទៅ យុទ្ធជន គឺជាបុគ្គលដែលជាប់ពាក់ព័ន្ធក្នុងជម្លោះប្រដាប់អាវុធ ។ បុគ្គលប្រភេទនេះ រាប់បញ្ចូលទាំងទាហានប្រយុទ្ធផ្ទាល់នៅសមរភូមិ ព្រមទាំងមេបញ្ជាការដែលបញ្ជាផ្ទាល់ពីទីបញ្ជាការ ។ បុគ្គលដែលមិនបានចូលរួមក្នុងជម្លោះជាទូទៅត្រូវបានការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ ។ អ្នកជំងឺនិងអ្នករបួសព្រមទាំងឈ្លើយសឹកត្រូវបានការពារដោយ

“ខ”ជាច្រើនដែលមាននៅក្នុងលិខិតូបករណ៍ច្បាប់អន្តរជាតិសំខាន់ទាំងនេះ ។ ជាក់ស្តែង អ្នកស៊ើបការណ៍ពុំត្រូវបានការពារដោយច្បាប់នេះទេ ។ ខ្មែរក្រហមតែងតែនិយាយថា ខ្លួនបាន“កម្ទេច” ឬ “កម្ចាត់” អ្នកស៊ើបការណ៍នៅក្នុងជួរបក្សរបស់ខ្លួន ។ ពាក្យថា “កម្ចាត់” ឬ “កម្ទេច” ទាំងពីរនេះ ជាពាក្យសម្ងាត់ដែលមានន័យថាសម្លាប់ ។ ចៅក្រមទំនងជានឹងកំណត់ថា មនុស្សដែលខ្មែរក្រហមសម្លាប់នោះ គឺសុទ្ធតែជាអ្នកស៊ើបការណ៍ ។

ទ្រព្យសម្បត្តិដែលទទួលបាននូវការការពារដោយច្បាប់ គឺទ្រព្យសម្បត្តិណាដែលមិនមែនជាគោលដៅយោធាដែលត្រឹមត្រូវតាមច្បាប់ ។ ក៏ប៉ុន្តែ ច្បាប់ការពារទ្រព្យសម្បត្តិក៏មានចែងថា បើទ្រព្យសម្បត្តិនេះជិតនឹងគោលដៅនៃយោធា វាមិនមែនជាឧក្រិដ្ឋកម្មសង្គ្រាមនោះទេ ប្រសិនបើទ្រព្យសម្បត្តិនេះត្រូវបានបំផ្លិចបំផ្លាញដោយចៃដន្យ ។ ជាចុងក្រោយនេះ ក្នុងកិច្ចការពារជនដែលមិនមែនជាយុទ្ធជននិងគោលដៅមិនមែនយោធា អ្នកវាយប្រហារត្រូវបន្ថយ ការស្លាប់ ការឈឺចាប់ និងការខូចខាតឲ្យនៅត្រឹមកម្រិតតិចតួចបំផុតតាមតែអាចធ្វើទៅបាន ។

ធាតុបរិបទ

គន្លឹះក្នុងការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមបង្ហាញថាឧក្រិដ្ឋកម្មនេះបានបង្កើតឲ្យមាននូវ“សម្ព័ន្ធភាពជម្លោះប្រដាប់អាវុធ” ។ នេះជាធាតុ“បរិបទ”នៃឧក្រិដ្ឋកម្មសង្គ្រាម ។ ក្នុងការចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មសង្គ្រាម ព្រះរាជអាជ្ញាត្រូវបង្ហាញថាជម្លោះប្រដាប់អាវុធបានកើតឡើងក្នុងពេលដែលមានអំពើឧក្រិដ្ឋកម្ម និងត្រូវបង្ហាញថាអំពើឧក្រិដ្ឋកម្មនេះមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធថែមទៀត ។ វាពុំទាន់ច្បាស់លាស់នៅឡើយ ថាតើចៅក្រមនឹងរកឃើញថាជម្លោះប្រដាប់អាវុធផ្ទៃក្នុងបានកើតឡើងនៅក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៧៩ដែរឬទេ ។ ក៏ប៉ុន្តែតុលាការនឹងអាចរកឃើញថាមានជម្លោះប្រដាប់អាវុធអន្តរជាតិក្នុងខណៈពេលដែលជម្លោះនៅតាមព្រំដែនកាន់តែរីកធំឡើងរវាងកម្ពុជាប្រជាធិបតេយ្យនិងប្រទេសវៀតណាមនៅក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ។

ធាតុផ្សំចេតនា

ដើម្បីធានាការចោទប្រកាន់ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ព្រះរាជអាជ្ញាត្រូវបង្ហាញថា ជនជាប់ចោទបានបង្កឲ្យមានផលប៉ះពាល់ “ដោយចេតនា” ។ ក្នុងករណីខ្មែរក្រហម រឿងរ៉ាវនៃការបញ្ជាឲ្យប្រព្រឹត្តការរំលោភបំពាន ការជួយនិងការជំរុញឲ្យរៀបចំប្រព្រឹត្ត ឬការដឹងនិងការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាមទាំងនេះ អាចបង្កើតឲ្យមាននូវធាតុ “ចេតនា” ដែលជាធាតុផ្សំចេតនានៃបទឧក្រិដ្ឋ ។

**(នៅមានត)**

**អូប្រី អារេដម៉ា**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀត ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុFM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជារៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧:៣០-៧:៤៥ ល្ងាច ។
- វិទ្យុFM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។
- វិទ្យុFM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង ៧:០០-៧:៣០ព្រឹក និងម៉ោង៦:៣០-៧:០០ល្ងាច ។
- វិទ្យុFM១០៣.២៥MHz ខេត្តបាត់ដំបងរៀងរាល់ថ្ងៃនៅម៉ោង ៩:០០-៩:៣០ព្រឹក និងម៉ោង៣:០០-៣:៣០ រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ឡាត់ សោភ័ណ និង ឡេង រតនៈ**

# ប្រវត្តិសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម កំណាកំណើត ការចរចា និងការបង្កើត

រយៈកាលនៃរបបខ្មែរក្រហមនៅកម្ពុជាត្រូវបានមើលឃើញថា ជារយៈកាលដ៏គួរឲ្យរន្ធត់បំផុតមួយនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើបនេះ ។ ក្នុងអំឡុងពេលពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យបានអនុវត្តវិធីសាស្ត្រដ៏សាហាវឃោរឃៅយ៉ាងគំហុកមួយ ក្នុងគោលបំណងប្រែក្លាយកម្ពុជាឲ្យទៅជាសង្គមកសិកម្ម (ដែលមានសុទ្ធតែជាជនជាតិខ្មែរ) ។ ដើម្បីសម្រេចឲ្យបាននូវគោលដៅបដិវត្តន៍នេះ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានបញ្ជានិងបណ្តែតបណ្តោយឲ្យមានការកាប់សម្លាប់យ៉ាងរង្គាល ការធ្វើទារុណកម្ម ការឃុំឃាំងដោយគ្មានជំនុំជម្រះក្តី ការបំបាត់ប្រព័ន្ធសុខាភិបាល ការធ្វើទុក្ខបុកម្នេញលើសាសនា និងការបង្ខំឲ្យធ្វើការហួសកម្លាំង និងការជម្លៀសប្រជាជនក្នុងទ្រង់ទ្រាយធំ ។ កងកម្លាំងបដិបក្ខក្នុងស្រុកសហការជាមួយកងកម្លាំងរបស់វៀតណាម បានផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យនៅខែមករា ឆ្នាំ១៩៧៩ ។ ការប៉ុនប៉ងក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស ដោយតុលាការក្នុងស្រុកបានចាប់ផ្តើម ។ ប៉ុន្តែ ការប៉ុនប៉ងទាំងនេះ មិនទទួលបានការចូលរួមច្រើនពីអន្តរជាតិទេ ហើយក៏មិនមានការចាប់ខ្លួននិងការដាក់ទណ្ឌកម្មទៅលើមន្ត្រីជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យណាមួយដែរ ។

ជារួម ឧក្រិដ្ឋកម្មដែលកើតមានឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនត្រូវបាននាំយកមកកាត់ទោសទេ ។ រហូតមកទល់ឆ្នាំ១៩៩៧ គឺមានរយៈកាលជិតពីរទសវត្សរ៍ដែលសហគមន៍អន្តរជាតិមិនមានសកម្មភាពអ្វីទាំងអស់ទាក់ទិនទៅនឹងបញ្ហានេះ ទើបអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមពិភាក្សាស្តីពីការបង្កើតសាលាក្តីមួយដើម្បីកាត់សេចក្តីឧក្រិដ្ឋជន ។ មានការពិភាក្សាដ៏តឹងតែងជាច្រើនទាក់ទងនឹងប្រភេទនិងដែនយុត្តាធិការរបស់“សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម”នេះ ។

នៅខែមករា ឆ្នាំ២០០១ រដ្ឋសភាជាតិនៃកម្ពុជាបានអនុម័តលើសេចក្តីព្រាងច្បាប់ ស្តីពីការបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលមានទម្រង់ជា“អង្គជំនុំជម្រះវិសាមញ្ញ (ដែលជាប្រព័ន្ធតុលាការចម្រុះនិងមានការចូលរួមទាំងជាតិនិងអន្តរជាតិ) ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលកើតមានឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់ពីការចរចាអស់រយៈពេលជិត៦ឆ្នាំ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានឈានដល់កិច្ចព្រមព្រៀងក្នុងការសហការគ្នាដើម្បីបង្កើតសាលាក្តីនេះឡើងនៅឆ្នាំ២០០៣ ។ នៅខែតុលា ឆ្នាំ២០០៤ រដ្ឋសភាកម្ពុជាបានអនុម័តទៅលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា និងធ្វើវិសោធនកម្មទៅលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលបានអនុម័តរួចហើយកាលពីឆ្នាំ២០០១ ហើយបានប្រកាសឲ្យចូលជាធរមាន ។

ប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហមមានសភាពស្មុគស្មាញ ។ ជាការលំបាកណាស់ក្នុងការស្វែងយល់អំពីដំណើរការដ៏តឹងតែងក្នុងដំណើរឆ្ពោះទៅកាន់ការទទួលខុសត្រូវ ប្រសិនបើគ្មានការស្វែងយល់ឲ្យបានច្បាស់លាស់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលគ្របដណ្តប់ដំណើរការនេះ ។ ជំពូកនេះនឹងរៀបរាប់ដោយសង្ខេបតាមកាលវេលាអំពីប្រវត្តិសាស្ត្រកម្ពុជា ចាប់តាំងពីការដួលរំលំនៃរបបកម្ពុជាប្រជាធិប-តេយ្យ នៅខែមករាឆ្នាំ១៩៧៩ ដោយផ្តោតជាសំខាន់ទៅលើកិច្ចខិតខំប្រឹងប្រែងទាំងក្នុងប្រទេសនិងក្រៅប្រទេសក្នុងការនាំយកអតីតមេដឹកនាំខ្មែរក្រហមទៅកាត់ទោសចំពោះបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្ត ។ ជំពូកនេះនឹងចាប់ផ្តើមពីព្រឹត្តិការណ៍ដែលធ្វើឲ្យមានការអាក់ខានដល់កិច្ចខិតខំប្រឹងប្រែងក្នុងការជំរុញឲ្យមានការទទួលខុសត្រូវអស់រយៈពេលជាងពីរទសវត្សរ៍ ។ ផ្នែកទីពីររួមមានការពិភាក្សាស្តីពីការចរចា ដែលចុងក្រោយឈានទៅដល់ការប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចព្រមព្រៀងរវាងអង្គការសហ-ប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា និងវិសោធនកម្មច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅខែតុលា

ឆ្នាំ២០០៤ ។ ផ្នែកទីបីនឹងធ្វើការវិភាគទៅលើដំណើរការវិវត្តន៍នយោបាយក្នុងប្រទេស ក៏ដូចជានយោបាយអន្តរជាតិ ដែលធ្វើឲ្យការបង្កើតសាលាក្តីនៅកម្ពុជាអាចដំណើរការទៅបាន ។ សេចក្តីបញ្ចប់នៃជំពូកនេះពិភាក្សាពីគោលជំហររបស់ក្រុមអ្នករិះគន់និងក្រុមគាំទ្រតុលាការចម្រុះនេះ ។

សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមបានក្លាយទៅជាប្រធានបទពិភាក្សាដ៏តឹងតែងមួយនៅក្នុងច្បាប់អន្តរជាតិក៏ដូចជានៅក្នុងជីវិតសម័យទំនើបរបស់ប្រជាជនកម្ពុជា សម្រាប់ការរស់នៅប្រកបដោយសុខដុមរមនានៅក្នុងទសវត្សរ៍នេះ ។ សាលាក្តីនេះក៏ជាលទ្ធផលនៃការធ្វើសម្បទានប្រកបដោយការពិចារណាខ្ពស់ ។ សមត្ថភាពរបស់សាលាក្តីដើម្បីបំពេញការទាមទាររបស់អ្នកគាំទ្រ និងការឆ្លើយតបទៅនឹងក្រុមអ្នកប្រឆាំងជាច្រើននោះគឺមានសារសំខាន់ណាស់ ប្រសិនបើកម្ពុជាចង់សម្រេចឲ្យបាននូវគោលដៅក្នុងដំណើរឆ្ពោះទៅកាន់យុត្តិធម៌និងការផ្សះផ្សាជាតិដែលអ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យបានរង់ចាំអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។

## ជម្លោះ និងនិទ្ទណ្ឌភាពរបស់ខ្មែរក្រហម ឆ្នាំ១៩៧៩-១៩៩៧

នៅខែធ្នូឆ្នាំ១៩៧៨ ឆ្លើយតបទៅនឹងការបង្កហេតុនិងការវាយប្រហារតាមបណ្តោយព្រំដែនជាបន្តបន្ទាប់ពីសំណាក់ខ្មែរក្រហម ក្រុមអ្នកតស៊ូកម្ពុជានិងកងកម្លាំងសម្ព័ន្ធមិត្តវៀតណាមបានធ្វើការវាយលុកចូលកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងរយៈពេលមិនដល់មួយខែផង កងកម្លាំងសម្ព័ន្ធមិត្តបានវាយបណ្តេញរបបខ្មែរក្រហមចេញពីទីក្រុងភ្នំពេញ និងវាយដណ្តើមកាន់កាប់ស្ទើរតែផ្ទៃប្រទេសទាំងមូល ។ ដោយមានជំនួយពីទីប្រឹក្សាចិនថ្នាក់ដឹកនាំខ្មែរក្រហមបានភៀសខ្លួនទៅភាគខាងលិចនៃប្រទេស និងបានបោះទីតាំងនៅក្នុងព្រៃក្រាស់នៃជួរភ្នំក្រវាញជាប់ព្រំដែនថៃ ។ ទោះជាលែងមានអំណាចនៅក្នុងប្រទេសក៏ដោយ ក៏ក្រុមខ្មែរក្រហមនៅតែបន្តការគំរាមកំហែងយ៉ាងច្រើនទៅលើសន្តិភាពនិងសន្តិសុខនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាទើបបង្កើតថ្មី និងដឹកនាំដោយសមមិត្ត ហេង សំរិន ដែរ ។ ដោយបានបោះទីតាំងនៅក្នុងព្រៃនិងដោយមានការជួយជ្រោមជ្រែងពីបរទេសមួយចំនួន ខ្មែរក្រហមមានលទ្ធភាពប្រមូលផ្តុំកម្លាំងនិងបង្កសង្គ្រាមទ័ពព្រៃ ប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងកងកម្លាំងវៀតណាមដែលមានប្រៀបជាង ។ ដូច្នេះ វាតម្រូវឲ្យមានវិធានការជាច្រើន មិនត្រឹមតែដើម្បីជំរុញឲ្យមានការទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដែលបានប្រព្រឹត្តមកលើប្រជាជនកម្ពុជាមុនខែធ្នូឆ្នាំ១៩៧៨ប៉ុណ្ណោះទេ ថែមទាំងបង្កើតឡើងនូវបទដ្ឋានមុនមួយដើម្បីឲ្យកម្មាភិបាលខ្មែរក្រហមនិងគូបដិបក្ខរបស់ខ្មែរក្រហម ខ្លាចញញើតមិនហ៊ានប្រព្រឹត្តអំពើឃោរឃៅនាពេលអនាគតទៀត គឺនៅក្នុងបរិបទមួយសំដៅកាត់បន្ថយសង្គ្រាមឲ្យបានច្រើន ។

## តើការកាត់សេចក្តីឆ្នាំ១៩៧៩ ជាជំហានដំបូងឆ្ពោះទៅកាន់យុត្តិធម៌ឬ?

ប្រាំបីខែបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម រដ្ឋាភិបាលថ្មីនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានព្យាយាមដោះស្រាយបញ្ហាទាក់ទិនទៅនឹងនិទ្ទណ្ឌភាពរបស់ខ្មែរក្រហម ។ ក្រសួងយុត្តិធម៌នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានរៀបចំការកាត់ទោសប៉ុល ពត អតីតនាយករដ្ឋមន្ត្រី និង អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យដោយកំបាំងមុខនៅទីក្រុងភ្នំពេញ ។ តុលាការប្រជាជនបដិវត្តន៍បានបញ្ចប់ការកាត់សេចក្តីក្នុងរយៈពេលប្រាំថ្ងៃ ។ នៅចុងបញ្ចប់ “ប៉ុល ពត និង អៀង សារី” ត្រូវបានរកឃើញថាបានប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងត្រូវបានកាត់ទោសប្រហារជីវិត ។ ប្រការដែលគួរឲ្យកត់សម្គាល់នោះគឺថា ការកាត់សេចក្តីនេះមិនទទួលបាននូវការគាំទ្រច្រើននោះទេ ។ ប៉ុន្តែ វាបានបង្កើតឲ្យមានជាបទដ្ឋានប្រវត្តិសាស្ត្រមួយ ។ វាជាការខិតខំប្រឹងប្រែងលើកទីមួយក្នុងការបង្រួបបង្រួមប្រជាជនកម្ពុជាជាមួយនឹងអតីតកាលដ៏សែនរន្ធត់របស់ខ្លួន ។ ហើយក៏ជាការកាត់សេចក្តីលើកទីមួយ ដែលបាននាំយកឧក្រិដ្ឋជនមកទទួលខុសត្រូវចំពោះអំពើទាំងឡាយដែលបានកំណត់នៅក្នុងអនុសញ្ញាប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ ។ ជាងនេះទៅទៀត ការកាត់សេចក្តីនេះត្រូវបានប្រព្រឹត្តទៅខណៈពេលដែលជនដៃដល់នៅបន្តកាន់កាប់តំបន់មួយចំនួននៃប្រទេស ហើយការចាប់ខ្លួនជនជាប់ចោទមិនទាន់អាចប្រព្រឹត្តទៅបាន ។

ការកាត់សេចក្តីត្រូវបានទទួលស្គាល់ពីសំណាក់សាធារណជន

ទូទៅនៅក្នុងប្រទេស (ភាគច្រើន ដោយឈរលើដីហរសីលធម៌ និងដីហរនយោបាយ) ប៉ុន្តែ ត្រូវបានបដិសេធដោយសហគមន៍អន្តរជាតិ ដែលចាត់ទុកថាជា«ការកាត់សេចក្តីក្លែងក្លាយ» ។ ទោះបីជាក្រុមរបស់ ប៉ុល ពត ត្រូវបានទម្លាក់ចេញពីអំណាចក៏ដោយ ក៏រដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាប្រឈមមុខនឹងការរិះគន់យ៉ាងច្រើននៅខាងក្នុង និងជាពិសេសនៅក្រៅប្រទេស ។ ប្រជាជនកម្ពុជាភាគច្រើនស្វាគមន៍ការដកកម្លាំងខ្មែរក្រហមចេញពីអំណាច ប៉ុន្តែប្រជាជនទាំងនេះក៏ មានការមិនពេញចិត្តចំពោះវត្តមានកងទ័ពនិងទីប្រឹក្សាវៀតណាមរាប់ពាន់នាក់នៅក្នុងប្រទេសដែរ ។ ប្រជាជនជាច្រើនផ្សេងទៀតបានរិះគន់ចំពោះគោលនយោបាយរដ្ឋាភិបាលថ្មីថាមិនមានអ្នកតំណាងច្បាស់លាស់ ។ នៅក្នុងកម្រិតអន្តរជាតិ ការបែងចែកមនោគមន៍វិជ្ជានៃនយោបាយសង្គ្រាមត្រជាក់បានគ្របដណ្តប់លើប្រធានបទស្តីអំពីយុត្តិធម៌ ។ អង្គការអន្តរជាតិនិងរដ្ឋាភិបាលបរទេសជាច្រើនបានចាត់ទុករបបសាធារណរដ្ឋប្រជាមានិតកម្ពុជាថាជាអាយ៉ងរបស់កុម្មុយនិស្តវៀតណាមដែលគាំទ្រដោយសហភាពសូវៀត ។ ប្រទេសដែលនៅក្រៅប្លុកសូវៀតបានចាត់ទុកការកាត់ក្តីថាជា «ការកាត់សេចក្តីក្លែងក្លាយ» ដែលត្រូវបានរៀបចំឡើងដើម្បីឲ្យឃើញថា អន្តរាគមន៍របស់វៀតណាមនៅកម្ពុជាគឺជាទង្វើត្រឹមត្រូវ ។ ជាងនេះទៅទៀត ការកាត់សេចក្តីបែបនេះនឹងធ្វើឲ្យឥទ្ធិពលរបស់សូវៀតនិងវៀតណាមក្នុងការពង្រីកអនុត្តរភាពរបស់ខ្លួននៅតំបន់ឥណ្ឌូចិនកាន់តែរីកធំធាត់ថែមទៀត ។ អ្នកជំនាញផ្នែកច្បាប់ជាច្រើនក៏បានរិះគន់ដែរ ចំពោះបរាជ័យនៃសាលាក្តីដែលមិនបានអនុវត្តបទដ្ឋានផ្លូវច្បាប់មួយ ដែលទទួលស្គាល់ជាអន្តរជាតិ ។ សេចក្តីមិនបានគោរពសិទ្ធិរបស់ចុងចោទក្នុងការសន្មតទុកជាមុនថាជាជនគ្មានទោស ។ ចុងចោទត្រូវបានប្រកាសមុនថាមានទោស ស្ទើរតែចំណងជើង«តុលាការប្រជាជនបដិវត្តន៍រៀបចំឡើងនៅទីក្រុងភ្នំពេញដើម្បីកាត់ទោសបនប្រល័យពូជសាសន៍ ប៉ុល ពត-អៀង សារី» ។ មួយថ្ងៃមុនការកាត់ក្តី លោក កែវ ចិន្តា ជាប្រធានតុលាការបានធ្វើសេចក្តីអត្ថាធិប្បាយថា ចុងចោទជាជនមានទោស ៖ «ការកាត់ទោស បន ប៉ុល ពត-អៀង សារី ពីបទឧក្រិដ្ឋប្រល័យពូជសាសន៍គឺ ដើម្បីបង្ហាញពីឧក្រិដ្ឋកម្មដែលពួកគេបានប្រព្រឹត្ត និងដើម្បីប្រមូលផ្តុំប្រជាជនកម្ពុជាឲ្យចូលរួមយ៉ាងសកម្មក្នុងការការពារនិងកសាងអំណាចប្រជាជន ហើយម្យ៉ាងទៀត គឺដើម្បីបង្ហាញឲ្យប្រជាជននៅលើពិភពលោកមើលឃើញពីមុខមាត់ពិតរបស់ឧក្រិដ្ឋជនដែលធ្វើជាតំណាងរបស់ប្រជាជនកម្ពុជា» ។ ជាងនេះទៅទៀត ប៉ុល ពត និង អៀង សារី ត្រូវបានកាត់ទោសដោយកំបាំងមុខ ហើយមិនមានការជជែកពិភាក្សារវាងចុងចោទដែលអវត្តមាននិងមេធាវីរបស់ខ្លួនដែលត្រូវបានចាត់តាំងនោះទេ ។ មេធាវីចុងចោទមិនត្រូវបានអនុញ្ញាតឲ្យត្រួតពិនិត្យមើលសាក្សីឡើយ ។ ជាចុងក្រោយ មេធាវីចុងចោទធ្វើការតវ៉ាតិចតួចបំផុត ដែលបន្ថយតួនាទីរបស់ចុងចោទពីអ្នកសមគំនិតក្នុងអំពើឧក្រិដ្ឋឲ្យទៅជាឧក្រិដ្ឋកម្មដែលរួមគំនិតនិងសម្លាប់ដោយចិន ។

ទោះបីជាជំនួយរបស់ចិនចំពោះខ្មែរក្រហមក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ និងរយៈពេលក្រោយមកទៀតត្រូវដឹងពុជាទូទៅក្តី ក៏ការកាត់សេចក្តីដែលសំដៅទៅលើគម្រោងផែនការប្រល័យពូជសាសន៍របស់ចិនបានបង្កើតឲ្យមានចំណាប់អារម្មណ៍មួយថា ការកាត់សេចក្តីនេះមានលក្ខណៈនយោបាយ ។ ការកាត់ទោស ប៉ុល ពត និង អៀង សារី នៅឆ្នាំ១៩៧៩ ត្រូវបានធ្វើឡើងបន្ទាប់ពីការឈ្លានពានរបស់ចិនទាំងកម្រោលចូលទឹកដីវៀតណាមនៅនិទាឃរដូវឆ្នាំ១៩៧៩ ដែលសាធារណរដ្ឋប្រជាមានិតចិនធ្វើឡើងដើម្បីផ្តល់មេរៀនមួយឲ្យវៀតណាម ដែលហ៊ានឈ្លានពានកម្ពុជាដែលជាសម្ព័ន្ធមិត្តរបស់ចិន ។ បន្ទាប់ពីការផ្សះផ្សាគ្នារវាងចិននិងសហរដ្ឋអាមេរិក និងបន្ទាប់ពីសង្គ្រាមវៀតណាមត្រូវបានបញ្ចប់ ចិននិងខ្មែរក្រហមបានរួបរួមគ្នាប្រឆាំងនឹងសហភាពសូវៀតនិងសម្ព័ន្ធមិត្តដែលមានវៀតណាមនិងឡាវ ដើម្បីតស៊ូរំដោះឥណ្ឌូចិន ។ អ្នកសង្កេតការណ៍អន្តរជាតិភាគច្រើនបានចាត់ទុកការកាត់ក្តីនេះថាជាផ្នែកមួយនៃនយោបាយវាយលុកនៅតំបន់អាស៊ីអាគ្នេយ៍របស់រដ្ឋាភិបាលក្រុងមូស្គូ ។

## នយោបាយសង្គ្រាមត្រជាក់ឆ្នាំ១៩៧៩-១៩៨៩ ជាឧបសគ្គក្នុងដំណើរទៅកាន់យុត្តិធម៌

មួយទសវត្សរ៍បន្ទាប់ពីការកាត់ទោសឆ្នាំ១៩៧៩ ការនាំយកខ្មែរក្រហមមកកាត់ទោសមិនមានការពិបាកទេ ។ ប្រទេសកម្ពុជា

បានក្លាយទៅជាសមរភូមិដ៏សំខាន់មួយនៃសង្គ្រាមត្រជាក់លើកទីពីរ ដែលធ្វើឲ្យកងកម្លាំងក្នុងស្រុក ក្នុងតំបន់ និងប្រទេសមហាអំណាចទាំងអស់វាយប្រហារគ្នាទៅវិញទៅមក ដែលមតិភាគច្រើនចាត់ទុកថាជាសង្គ្រាមប្រយោល ។ មហិច្ឆតាសង្គ្រាមត្រជាក់របស់ប្រទេសមហាអំណាចនិងកងកម្លាំងក្នុងតំបន់នៅឥណ្ឌូចិនបានគ្របដណ្តប់លើគោលដៅរួមរបស់ប្រទេសទាំងនេះ ក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ។

វត្តមានរបស់កងទ័ពវៀតណាមគាំទ្រដោយសហភាពសូវៀតនៅកម្ពុជា ការដួលរលំនៃរបបអភិរក្សនិយមរបស់សូមូហ្សា នៅនីការាហ្គា ការឈ្លានពានរបស់សូវៀតចូលប្រទេសអាហ្គានីស្ថាន និងព្រឹត្តិការណ៍ផ្សេងៗទៀត បានបង្កឲ្យមានជម្លោះពិភពលោក និងបានជំរុញឲ្យគូបដិបក្ខចិននិងសហរដ្ឋអាមេរិករួបរួមគ្នាជាធ្លុងមួយប្រឆាំងនឹងទីក្រុងមូស្គូ ។ ការឈ្លានពានរបស់សូវៀតបាននាំដល់ការបង្កើតឡើងនូវ«គោលការណ៍រីហ្គិន» ដែលនៅក្រោមគោលការណ៍នេះសហរដ្ឋអាមេរិកនឹងផ្តល់ថវិកាដល់ក្រុមប្រទេសតតិយលោកដែលធ្វើការប្រឆាំងនឹងនយោបាយវាតទីនិយមរបស់ប្រទេសកុម្មុយនិស្តដែលគាំទ្រដោយសហភាពសូវៀត ។ ដូចមូជីហាឌីន នៅអាហ្គានីស្ថាន និង កុងត្រាស៍ នៃនីការាហ្គា កងកម្លាំងខ្មែរក្រហមបានក្លាយទៅជាកូនអុកនៅក្នុងជម្លោះមួយ ដែលរីករាលដាលខ្លាំងជាងជម្លោះក្នុងតំបន់ទៅទៀត ។

ចិននិងសហរដ្ឋអាមេរិកបានលើកហេតុផលថា ការប្រយុទ្ធប្រឆាំងនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានិងកងកម្លាំងរបស់វៀតណាម បានជួយជំរុញសម្ព័ន្ធភាពជាមួយប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ដើម្បីប្រឆាំងនឹងវៀតណាមនិងសូវៀត ។ ជាងនេះទៅទៀត ការរក្សាទុកកម្លាំងខ្មែរក្រហមនឹងបំផ្លាញធនធានរបស់សូវៀត និងបណ្តាលឲ្យមានការខូចខាតដល់ធនធានយោធា និងធនធានហិរញ្ញវត្ថុរបស់វៀតណាម ។ ដើម្បីគាំទ្រក្រុមប្រឆាំងនឹងវៀតណាម ចិនបានផ្តល់ជំនួយយោធាដ៏សំខាន់មួយទៅឲ្យកងកម្លាំងដែលបែកបាក់របស់ខ្មែរក្រហម ។ មានរបាយការណ៍និយាយថា ចិនបានផ្តល់ជំនួយជិត១០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំទៅឲ្យក្រុមខ្មែរក្រហម ។ រដ្ឋាភិបាលថៃ ដោយព្រួយបារម្ភពីការគំរាមកំហែងពីសំណាក់វៀតណាមក៏បានចងសម្ព័ន្ធភាពជាមួយសហរដ្ឋអាមេរិកនិងចិនក្នុងការទ្រទ្រង់កងកម្លាំងខ្មាមកម្ពុជា ។ មន្ត្រីយោធាថៃបានយល់ព្រមដឹកជញ្ជូនជំនួយយោធា ស្បៀងអាហារ និងថ្នាំពេទ្យរបស់ចិនទៅជំរំខ្មែរក្រហមដែលស្ថិតនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ។ ការគាំទ្រពីសំណាក់ថៃនិងចិននិងជំនួយហិរញ្ញវត្ថុរបស់អាមេរិកបានធ្វើឲ្យកម្លាំងទ័ពព្រៃកាន់កាប់ទឹកដីភាគខាងលិចកម្ពុជាមួយចំនួននិងព្រមានភាគីបដិបក្ខអំពីលទ្ធភាពនៃជ័យជម្នះយោធា ។

ចិន សហរដ្ឋអាមេរិក និងប្រទេសអាស៊ីអាគ្នេយ៍ដទៃទៀតបានប្រើនយោបាយការទូតក្នុងការគាំទ្រក្រុមខ្មែរក្រហម និងក្រុមផ្សេងទៀតប្រឆាំងទៅនឹងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ សហភាពសូវៀតនិងសម្ព័ន្ធមិត្តរបស់ខ្លួន គឺក្រុមរដ្ឋតែមួយគត់ដែលគាំទ្រសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយកិច្ចខិតខំប្រឹងប្រែងរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីទទួលបានការទទួលស្គាល់ជាផ្លូវការនៅឯមហាសន្និបាតអង្គការសហប្រជាជាតិមិនបានទទួលផ្លែផ្កាអ្វីទាំងអស់ ។ ផ្ទុយទៅវិញ នៅឆ្នាំ១៩៨២ អង្គការអន្តរជាតិបានបោះឆ្នោតផ្តល់អាសនៈកម្ពុជានៅមហាសន្និបាតអង្គការសហប្រជាជាតិឲ្យទៅរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យដែលរួមមានក្រុមខ្មែរក្រហម កងកម្លាំងស្តាំនិយមរបស់សម្តេច សឺន សាន និងកម្លាំងរាជានិយមរបស់សម្តេច ព្រះនរោត្តម សីហនុ។ រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យគឺជាការចែករំលែកអំណាចគ្នារវាងក្រុមបី ដែលជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសអាស៊ីអាគ្នេយ៍ ចិន និងសហរដ្ឋអាមេរិក ក្នុងការបង្កើតជម្រើសនយោបាយមួយចំពោះរដ្ឋាភិបាលដែលគាំទ្រដោយវៀតណាមនៅក្នុងទីក្រុងភ្នំពេញ។ សម្តេច ព្រះនរោត្តម សីហនុ ត្រូវបានតែងតាំងជាប្រធានរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ សម្តេច សឺន សាន ជានាយករដ្ឋមន្ត្រី ហើយ ខៀវ សំផន ជាអនុប្រធាន។ ទោះបីជាសម្តេចព្រះ នរោត្តម សីហនុ ជាតំណាងរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏កម្លាំងខ្មែរក្រហមគឺជាកម្លាំងប្រយុទ្ធពិតប្រាកដ ហើយនៅក្នុងបរិស្ថាននៃសង្គ្រាមត្រជាក់ការនាំយកជនទាំងនេះទៅកាត់ទោស ពីបទឧក្រិដ្ឋដែលបានប្រព្រឹត្ត

ក្នុងទសវត្សរ៍ឆ្នាំ១៩៧០ មិនត្រូវបានយកមកពិចារណា ។

ហេតុដូច្នេះហើយ ទោះជាមានរបាយការណ៍កាន់តែច្រើន ស្តីពីអំពើឃោរឃៅរបស់កម្ពុជាប្រជាធិបតេយ្យយ៉ាងណាក៏ដោយ អង្គការសហប្រជាជាតិនៅតែបន្តគាំទ្រដល់ចលនាតស៊ូរបស់ខ្មែរក្រហម ហើយថែមទាំងផ្តល់ធម្មានុភាពនយោបាយទៅឲ្យរបបកម្ពុជាប្រជាធិបតេយ្យដែលដួលរលំនេះទៀតផង ។ ជាជាងស្វែងរកយុត្តិធម៌ពីឧក្រិដ្ឋកម្មឃោរឃៅ សហគមន៍អន្តរជាតិបានផ្តោតសំខាន់ទៅលើជម្លោះយោធានិងជម្លោះនយោបាយរ៉ាំរ៉ៃ ដែលបានរាំងខ្ទប់ដល់ដំណើរការកាត់សេចក្តីក្រុមខ្មែរក្រហមនិងបានធ្វើឲ្យការតស៊ូជាតិនិយមជ្រុលហួសហេតុរបស់ក្រុមនេះកាន់តែខ្លាំងក្លាឡើង ។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដែលមានក្រុមខ្មែរក្រហមជាសមាជិកខ្លាំងជាងគេ បានកាន់កាប់អាសនៈកម្ពុជានៅមហាសន្និបាតអង្គការសហប្រជាជាតិរហូតដល់ថ្ងៃចុះហត្ថលេខាសន្ធិសញ្ញាសន្តិភាពនៅឆ្នាំ១៩៩១ ។

## ការចរចាសន្តិភាព និងឧបសគ្គជាបន្តចំពោះការកាត់សេចក្តីពីឆ្នាំ ១៩៨៩ ដល់ ១៩៩១

នៅចុងទសវត្សរ៍ឆ្នាំ១៩៨០ ជម្លោះរវាងកម្លាំងខ្មែរក្រហមនិងកម្លាំងរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជានៅតែបន្ត ហើយសម្ពាធពីអន្តរជាតិក្នុងការនាំយកថ្នាក់ដឹកនាំខ្មែរក្រហមមកកាត់ទោសនៅតែមានទំហំតូចនៅឡើយ ។ អ្នកជំនាញអូស្ត្រាលី និងអាមេរិកាំងបានបង្កើតកម្មវិធីសិក្សាពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាក្នុងឆ្នាំ១៩៨២ ដើម្បីសិក្សាពីការរំលោភសិទ្ធិមនុស្សរបស់ខ្មែរក្រហម ។ ទោះជាយ៉ាងនេះក្តីសកម្មភាពរបស់ថ្នាក់ដឹកនាំនយោបាយនៅមានសភាពស្ងួចស្តើងនៅឡើយ ។ ចិន ប្រទេសអាស៊ីអាគ្នេយ៍មួយចំនួន និងសហរដ្ឋអាមេរិកបានចាត់ទុកខ្មែរក្រហមជាកូនអុកដ៏សំខាន់នៅក្នុងដំណើរការចរចាសន្តិភាពនៅកម្ពុជា ។ ទោះបីជាសង្រ្គាមត្រជាក់បានឈានមកដល់ទីបញ្ចប់នៅឆ្នាំ១៩៨៩ (នៅពេលជំនួយសេដ្ឋកិច្ចរបស់សូវៀតសម្រាប់កងកម្លាំងវៀតណាមបានធ្លាក់ចុះយ៉ាងខ្លាំង ហើយបង្ខំឲ្យវៀតណាមដកទ័ពចេញពីកម្ពុជា) ក៏អង្គការសហប្រជាជាតិនិងប្រទេសមហាអំណាចសំខាន់ៗមួយចំនួននៅមានកិច្ចការសំខាន់ដែលត្រូវធ្វើជាជាងការកាត់ទោសខ្មែរក្រហម ។ ដោយគ្មានជំនួយយោធានិងជំនួយហិរញ្ញវត្ថុកម្ពុជាក្រោមរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជា-មានិតកម្ពុជាកាន់តែខ្សោយទៅៗ ហើយលទ្ធភាពនៃសង្រ្គាមស៊ីវិលកាន់តែកើនឡើង ។ កិច្ចប្រជុំក្រៅផ្លូវការនៅទីក្រុងហ្សាកាតានិងការពិភាក្សាសន្តិភាពនៅទីក្រុងប៉ារីសជាច្រើនលើកក្នុងរវាងឆ្នាំ១៩៨៨ ដល់ឆ្នាំ១៩៩០ ក្នុងការស្វះស្វែងធ្វើឲ្យមានស្ថិរភាពនៅក្នុងកម្ពុជា និងតំបន់ជុំវិញបានរួមបញ្ចូលក្រុមខ្មែរក្រហមជាផ្នែកមួយសំខាន់នៅក្នុងការចរចាទាំងនេះ ។ ប្រសិនបើគ្មានការទទួលស្គាល់ផែនការសន្តិភាពពីក្រុមខ្មែរក្រហមទេនោះ វាហាក់ដូចជាថាកម្ពុជានឹងមិនអាចទទួលបានសន្តិភាពឡើយ ។

នៅឆ្នាំ១៩៩០ ឈ្មោះផ្លូវការរបស់កម្ពុជាត្រូវបានប្តូរពីសាធារណរដ្ឋប្រជាមានិតកម្ពុជាទៅជារដ្ឋកម្ពុជាដឹកនាំដោយនាយករដ្ឋមន្ត្រីវ័យក្មេង ហ៊ុន សែន ។ កម្ពុជាបានងាកចេញពីសេដ្ឋកិច្ចសង្គមនិយមទៅស្វែងរកការវិនិយោគទុនបរទេស ។ ប៉ុន្តែដោយគ្មានជំនួយសេដ្ឋកិច្ចនិងជំនួយយោធាពីសូវៀតនិងវៀតណាម ជីវិតកម្ពុជាបន្តរស់នៅទាំងលំបាកលំបិន ។ ការផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចទីផ្សារសេរីបានធ្វើឲ្យសេដ្ឋកិច្ចដ៏ទន់ខ្សោយរបស់កម្ពុជាកាន់តែដុនដាបជាងមុន ។ ហើយកម្លាំងខ្មែរក្រហមគ្រប់គ្រងតំបន់កាន់តែច្រើនឡើង ។

ដើម្បីសម្រេចឲ្យបានសន្តិភាពនៅកម្ពុជា សហគមន៍អន្តរ-ជាតិបានចូលធ្វើអន្តរាគមន៍ម្តងទៀត ដោយផ្តួចផ្តើមឲ្យមានកិច្ចខិតខំប្រឹងប្រែងជាច្រើនលើកនៅឆ្នាំ១៩៩១ ដើម្បីបញ្ចប់ជម្លោះរវាងភាគីបដិបក្ខទាំងអស់ ។ ដោយមានការជំរុញពីចិន គណៈប្រតិភូខ្មែរក្រហមបានចូលរួមជាមួយភាគីបីទៀតដែលតំណាងឲ្យកម្ពុជាក្នុងការពិភាក្សារកដំណោះស្រាយសន្តិភាព ។ ខ្មែរក្រហមគឺជាកម្លាំងខ្លាំងមួយនៅក្នុងប្រទេស ។ ដូច្នេះ សហគមន៍អន្តរជាតិជាថ្មីម្តងទៀតយល់ឃើញថា ការជួយជ្រោមជ្រែងរបស់ខ្លួន គឺមានសារសំខាន់ខ្លាំងណាស់សម្រាប់សន្តិភាពយូរអង្វែងនៅកម្ពុជា ។ ដោយយល់ឃើញថាការពិភាក្សាពីបញ្ហាកាត់ទោសអាចនឹងបំផ្លាញដល់ដំណើរការសន្តិភាព កិច្ចខិតខំប្រឹងប្រែងក្នុងការស្វែងរកយុត្តិធម៌ពីឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមត្រូវបានទុកឲ្យនៅម្ខាងដើម្បីជាប្រយោជន៍ដល់ការថែរក្សាដំណោះស្រាយសន្តិភាពនៅកម្ពុជា ។ ដោយមានការអំពាវនាវយ៉ាងខ្លាំងក្លាពីក្រុមប្រឹក្សា

សន្តិសុខ ភាគីជម្លោះទាំងបួនបានចុះហត្ថលេខាលើផែនការសន្តិភាព នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ។ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសបានបង្កើតឲ្យមានការចែករំលែកអំណាចដែលបានអំពាវនាវឲ្យភាគីទាំងបួនចូលរួមក្នុងក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទើបបង្កើតថ្មីមួយដែលជាតំណាងឲ្យកម្ពុជា ។ «នៅក្នុងដំណាក់កាលអន្តរកាលនេះ ឯករាជ្យជាតិ អធិបតេយ្យភាពជាតិ និងឯកភាពជាតិនឹងត្រូវតម្កល់ទុកសិន» ។ ផែនការនេះក៏រួមមានការអំពាវនាវឲ្យមានការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិរហូតដល់មានការបោះឆ្នោត និងរដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើងតាមការជ្រើសតាំងតាមលទ្ធិប្រជាធិបតេយ្យ ។

## ដំណាក់កាលអ៊ុនតាក់ ឆ្នាំ១៩៩២-១៩៩៣

កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ តម្រូវឲ្យអង្គការសហប្រជាជាតិដើរតួនាទីចម្បងនៅក្នុងបញ្ហាជាច្រើនដូចជា បង្កើតនិងរៀបចំការបោះឆ្នោត គ្រប់គ្រងការធ្វើសមាហរណកម្មរបស់ជនភៀសខ្លួនមកក្នុងប្រទេស ការដកអាវុធនិងការរំសាយកងទ័ពនិងការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាននៅក្នុងប្រទេស ។ ជាជាងការផ្តល់អំណាចក្នុងការបង្កើតឲ្យមានការកាត់ទោសសមាជិកខ្មែរក្រហមដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធមនុស្សធ្ងន់ធ្ងរពីអតីតកាល កងរក្សាសន្តិភាពអង្គការសហប្រជាជាតិ ដែលត្រូវបានបង្កើតឡើងក្រោមកិច្ចព្រមព្រៀង (អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ហៅកាត់ថា អ៊ុន តាក់) មានកាតព្វកិច្ចទទួលស្គាល់ខ្មែរក្រហមជាភាគីស្មើភាពមួយនៅក្នុងដំណាក់កាលអន្តរកាលនេះ ។

ការមិនព្រមអនុវត្តតាមកិច្ចព្រមព្រៀងរបស់ខ្មែរក្រហមបានចាប់ផ្តើមឡើងភ្លាមៗ ។ បន្ទាប់ពីការចរចាដោយគ្មានផ្លែផ្កាអស់រយៈពេលប្រាំខែ ភាគីខ្មែរក្រហមបានដកខ្លួនចេញពីកិច្ចសហប្រតិបត្តិការជាមួយបេសកកម្មរបស់អ៊ុនតាក់ ។ នៅពេលដំណើរការនេះបានជាប់គាំង ខ្មែរក្រហមត្រូវចាប់ផ្តើមបើកយុទ្ធនាការវាយប្រហារលើជនជាតិខ្មែរកាត់វៀតណាមនិងបុគ្គលិកអ៊ុនតាក់ ។ ខ្មែរក្រហមក៏បានបដិសេធមិនចូលរួមការបោះឆ្នោតដ៏ជោគជ័យមួយដែលរៀបចំឡើងដោយអ៊ុនតាក់នៅខែឧសភា ឆ្នាំ១៩៩៣ ដែលប្រជាជន៩០ភាគរយបានចូលរួមដែរ ។ សកម្មភាពរឹងទទឹងទាំងនេះគឺជាការប្រឆាំងទៅនឹងការគាំទ្រពីអន្តរជាតិក្នុងការបញ្ចប់ការកាប់សម្លាប់ និងបានធ្វើឲ្យឋានៈរបស់ខ្មែរក្រហមដែលនៅក្នុងកេរ្តិ៍ឈ្មោះរបស់សហគមន៍អន្តរជាតិកាន់តែថយចុះយ៉ាងខ្លាំង ។ ដោយបានរៀបចំការបោះឆ្នោតជាតិនិងបណ្តុះពន្លកសង្គមស៊ីវិលប្រកបដោយជោគជ័យ អ៊ុនតាក់បានជួយបន្ថយឥទ្ធិពលអង្គការខ្មែរក្រហមតាមផ្លូវនយោបាយ ។ ការចូលរួមនៅក្នុងសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមអាចចាត់ទុកថាជាបេសកកម្មពាក់កណ្តាលទីពីររបស់អង្គការសហប្រជាជាតិក្នុងការកសាងប្រជាធិបតេយ្យ និងធានាឲ្យបានយុត្តិធម៌និងនីតិរដ្ឋនៅកម្ពុជា ។

## ការចាប់ផ្តើមដោយខុសបន្ថែមក្នុងការធានាយុត្តិធម៌ឆ្នាំ១៩៩៤-១៩៩៦

បន្ទាប់ពីការបោះឆ្នោត រដ្ឋាភិបាលចម្រុះមួយត្រូវបានបង្កើតឡើងដោយគណបក្សរាជានិយមហ៊្វុនស៊ិនប៉ិចដែលទទួលបានសំឡេងឆ្នោតភាគច្រើននិងគណបក្សប្រជាជនកម្ពុជា ។ ប្រធានគណបក្សហ៊្វុនស៊ិនប៉ិចព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីទីមួយ និងសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រីទីពីរ ។ ប្រាំខែក្រោយមក រដ្ឋធម្មនុញ្ញថ្មីមួយត្រូវបានអនុម័ត គឺនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៣ ហើយប្រទេសនេះត្រូវបានប្តូរឈ្មោះថា «ព្រះរាជាណាចក្រកម្ពុជា» ។ នៅឆ្នាំ១៩៩៤ រដ្ឋសភាជាតិបានអនុម័តច្បាប់ស្តីពីការដាក់ក្រុមខ្មែរក្រហមឲ្យនៅក្រៅច្បាប់ ។

នៅឆ្នាំ១៩៩៤ នយោបាយអាមេរិកាំងចំពោះខ្មែរក្រហមក៏ចាប់ផ្តើមមានឡើង ។ សភាអាមេរិកបានអនុម័តច្បាប់យុត្តិធម៌ស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ដោយអំពាវនាវឲ្យរដ្ឋាភិបាលអាមេរិកគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទាំងឡាយក្នុងការនាំយកសមាជិកខ្មែរក្រហមមកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ច្បាប់នេះ បានបង្កើតការិយាល័យពិសេសសម្រាប់ស៊ើបអង្កេតឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជានៅក្នុងក្រសួងការបរទេសនិងផ្តល់ហិរញ្ញវត្ថុដល់កម្មវិធីសិក្សាពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា នៅសាកលវិទ្យាល័យយែល និងបង្កើតការិយាល័យមួយនៅទីក្រុងភ្នំពេញដើម្បីប្រមូលភស្តុតាងសំខាន់ៗសម្រាប់សាលាក្តី ។ ការិយាល័យ

នេះបានក្លាយទៅជាមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានធ្វើការប្រមែប្រមូលយ៉ាងលឿននូវព័ត៌មានទាក់ទងនឹងអំពើឃោរឃៅទាំងឡាយក្នុងរបបខ្មែរក្រហមតាមរយៈ ការធ្វើសម្ភាសន៍ ការសិក្សាពីដែនទីរណ្ដៅសាកសព និងការប្រមែប្រមូលឯកសារជាច្រើនដែលទទួលបានពីរាជរដ្ឋាភិបាលកម្ពុជានិងពីប្រភពឯកជនផ្សេងៗទៀត ។

ទោះជាយ៉ាងនេះក្ដី ការខិតខំប្រឹងប្រែងក្នុងការជំរុញឲ្យមានការទទួលខុសត្រូវនៅកម្ពុជាត្រូវបានអាក់ខានទៅវិញ នៅពេលព្រះមហាក្សត្រ នរោត្តម សីហនុ ព្រះរាជទានទោសជាផ្លូវការដល់អតីតឧបនាយករដ្ឋមន្ត្រី អៀង សារី ដែលត្រូវបានកាត់ទោសប្រហារជីវិតដោយសាលាក្ដីឆ្នាំ១៩៧៩ ។ ការលើកលែងទោសត្រូវបានធ្វើឡើង ដោយសារ អៀង សារី បានដកខ្លួនចេញពីក្រុមខ្មែរក្រហម ហើយចុះចូលជាមួយរាជរដ្ឋាភិបាលដែលទើបបង្កើតថ្មី ។ ខ្លឹមសារនៅក្នុងព្រះរាជក្រឹត្យលើកលែងទោសបានការពារ អៀង សារី ពីទោសប្រហារជីវិតដែលធ្វើឡើងដោយកំបាំងមុខ និងការពារប្រឆាំងទៅនឹងការកាត់ទោសក្រោមច្បាប់ស្ដីពីការដាក់ក្រុមខ្មែរក្រហមឲ្យនៅក្រៅច្បាប់ឆ្នាំ១៩៩៤ ។ ទោះជាយ៉ាងនេះក្ដី វានៅមិនទាន់ច្បាស់នៅឡើយទេដែលថា អៀង សារី នឹងត្រូវបានការពារពីការចោទប្រកាន់នាពេលអនាគតពីបទឧក្រិដ្ឋដែលគាត់បានប្រព្រឹត្តនៅចុងទសវត្សរ៍ឆ្នាំ១៩៧០ ឬយ៉ាងណា ។

កងកម្លាំងខ្មែរក្រហមបានឈានដល់ចំណុចបំបែកនៅឆ្នាំ១៩៩៦ ។ គណបក្សប្រជាជនកម្ពុជានិងគណបក្សហ៊្វុនស៊ិនប៉ិចបានធ្វើយុទ្ធនាការដោយជោគជ័យក្នុងការទាក់ទាញកម្លាំងផ្ដាច់ខ្លួនខ្មែរក្រហម ដោយធ្វើការសន្យាថា កម្មាភិបាលទាំងនោះនឹងត្រូវបានអនុញ្ញាតឲ្យគ្រប់គ្រងតំបន់មួយចំនួន ផ្ដល់តួនាទីសំខាន់ៗមួយចំនួននៅក្នុងកងយោធពលខេមរភូមិន្ទ និងរួចផុតពីការកាត់ទោសនាពេលអនាគត ។ យុទ្ធសាស្ត្រនេះមានប្រសិទ្ធភាពគួរសម ហើយបានបំបែកកម្លាំងសេសសល់របស់អង្គការខ្មែរក្រហម ។

នៅខែមិថុនា ឆ្នាំ១៩៩៧ កម្ពុជាប្រឈមមុខទៅនឹងការខិតខំប្រឹងប្រែងដ៏ឥតប្រយោជន៍មួយទៀតក្នុងការនាំយកសមាជិកខ្មែរក្រហមមកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយ នៅពេល ប៉ុល ពត ត្រូវបានកាត់ទោស ដែលអ្នករិះគន់ជាច្រើនបានហៅថា "ការកាត់ទោសក្លែងក្លាយ"មួយទៀត ។ កងកម្លាំងខ្មែរក្រហមបានចាប់ឃុំឃាំង ប៉ុល ពត និងសមាជិកបីរូបផ្សេងទៀតដែលត្រូវបានចោទប្រកាន់ពីបទសម្លាប់អតីតរដ្ឋ មន្ត្រីក្រសួងការពារជាតិរបស់ខ្មែរក្រហម សុន សេន និងក្រុមគ្រួសារ ។ ការកាត់ទោសនេះត្រូវបានធ្វើឡើងដោយ"តុលាការប្រជាជន" នៅតំបន់អន្លង់វែងភាគពាយ័ព្យនៃប្រទេស ។ បន្ទាប់ពីការកាត់សេចក្ដីដ៏ខ្លីមួយនៅកណ្ដាលវាល ប៉ុល ពត និងសមាជិកបីរូបទៀតត្រូវបានកាត់ទោសឲ្យជាប់គុកអស់មួយជីវិត ។ តុលាការនេះពិចារណាតែការចោទប្រកាន់ប្រឆាំងនឹង ប៉ុល ពត ដែលជាប់ពាក់ព័ន្ធទៅនឹងករណីស្លាប់របស់ សុន សេន ។ តុលាការនេះបានបដិសេធការប្រគល់ខ្លួន ប៉ុល ពត ទៅឲ្យតុលាការអន្តរជាតិដើម្បីកាត់សេចក្ដីពីឧក្រិដ្ឋ-កម្មដែលបានប្រព្រឹត្តឡើងនៅពេលខ្មែរក្រហមកាន់អំណាច ។ ប៉ុល ពត ទទួលយកការជាប់គុកមួយជីវិតនៅក្នុងផ្ទះ ដោយមានការការពារពីអតីតសមមិត្តខ្មែរក្រហមរបស់គាត់ ។ ប៉ុល ពត ស្លាប់ដោយលក្ខខណ្ឌធម្មជាតិនៅក្បែរព្រំដែនខ្មែរ-ថៃ នៅខែមេសា ឆ្នាំ១៩៩៨ ។

## រយៈពេលនៃការចរចាឆ្នាំ១៩៩៧-២០០៦

ដោយសារការបែកបាក់របស់ក្រុមខ្មែរក្រហមចុងទសវត្សរ៍ឆ្នាំ១៩៩០គឺជាការចាប់ផ្ដើមនៃកិច្ចខិតខំប្រឹងប្រែងពិតប្រាកដមួយក្នុងការនាំយកមកកាត់ទោសនូវជនទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ។ នៅខែមេសា ឆ្នាំ១៩៩៧ គណៈកម្មការអង្គការសហប្រជាជាតិសម្រាប់សិទ្ធិមនុស្សបានបើកទ្វារឲ្យមានការចរចារវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនស្ដីពីកម្ពុជា គណៈកម្មការនេះបានស្នើឲ្យអង្គការសហប្រជាជាតិជួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការកាត់ទោសជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សពីអតីតកាល ។ ពីរខែក្រោយមក សហនាយករដ្ឋមន្ត្រីព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងសម្ដេច ហ៊ុន សែន បានផ្ញើលិខិតផ្លូវការមួយស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីធានាឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើឃោរឃៅក្នុងរបបខ្មែរក្រហម ។ ទោះជាយ៉ាងនេះក្ដីដំណើរការនេះបានជាប់គាំងទៅវិញ

នៅខែកក្កដាឆ្នាំ១៩៩៧ ដោយសារតែសភាពការណ៍ស្មុគស្មាញជាបន្តបន្ទាប់ ដែលអ្នកវិភាគភាគច្រើនបានហៅថាជា"រដ្ឋប្រហារ" ដែលបានកាត់បន្ថយឥទ្ធិពលរបស់ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និងធ្វើឲ្យសម្តេច ហ៊ុន សែន ក្លាយជានាយករដ្ឋមន្ត្រីកាន់អំណាចតែម្នាក់ឯងនៅក្នុងប្រទេស ។ ភាពចលាចលនយោបាយក្នុងឆ្នាំ១៩៩៧ បានធ្វើឲ្យមានការខ្វល់ខ្វាយពីសំណាក់អង្គការសហប្រជាជាតិ ដែលបានបន្តការចរចានេះជាបន្តបន្ទាប់ដោយប្រុងប្រយ័ត្នបំផុត ។ បន្ទាប់ពីមានការពន្យារពេលអស់មួយរយៈមក អគ្គលេខាធិការអង្គការសហប្រជាជាតិបានចាត់តាំងអ្នកជំនាញការមួយក្រុមដើម្បីធ្វើការប៉ាន់ប្រមាណអំពីលទ្ធភាពក្នុងការនាំយកអតីតមេដឹកនាំខ្មែរក្រហមមកកាត់ទោស និងដើម្បីផ្តល់យោបល់អំពីដំណើរការច្បាប់ដ៏ល្អមួយក្នុងការសម្រេចឲ្យបាននូវគោលដៅនេះ ។ ក្រុមនេះដែលរួមមានលោក នីនៀន ស្ទីវហ៊ិន ជនជាតិអូស្ត្រាលី លោក មូរីទៀន រ៉ាហ្សូមៀរ ឡាឡះ និងជនជាតិអាមេរិកាំង ស្ទីវហ៊ិន រេតន័រ ត្រូវបានអនុញ្ញាតឲ្យធ្វើកិច្ចការបីយ៉ាង ។ កិច្ចការទាំងនោះរួមមាន ពិនិត្យភស្តុតាងនិងកំណត់អំពីប្រភេទឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយក្រុមខ្មែរក្រហមនៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ប៉ាន់ប្រមាណអំពីលទ្ធភាពនៃការនាំយកមេដឹកនាំខ្មែរក្រហមទៅកាត់ទោស និងស្ទាបស្ទង់មតិសាធារណៈជាតិនិងអន្តរជាតិក្នុងការកាត់ទោសខ្មែរក្រហម ។

នៅខែកុម្ភៈឆ្នាំបន្ទាប់ ក្រុមនេះបានចេញរបាយការណ៍មួយថា មានករណីកើតឡើងពិតប្រាកដដែលបង្ហាញពីការប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្ទុយទៅនឹងច្បាប់សិទ្ធិមនុស្សជាតិនិងអន្តរជាតិ ។ របាយការណ៍នេះក៏បានបង្ហាញដែរថា សារជាតិនៃអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការកម្ពុជានឹងធ្វើឲ្យការកាត់ទោសនៅក្នុងស្រុកមិនអាចដំណើរការបាន ។ ក្នុងចំណោមជម្រើសផ្លូវច្បាប់បី(តុលាការអន្តរជាតិ តុលាការចម្រុះ និងតុលាការក្នុងស្រុក) របាយការណ៍នេះបានចេញសេចក្តីសន្និដ្ឋានថា ជម្រើសផ្លូវច្បាប់ដ៏ល្អបំផុតគឺ បង្កើតតុលាការអន្តរជាតិពិសេសមួយដែលមានអំណាចកាត់សេចក្តីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តក្នុងអំឡុងពេលចាប់ពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃទី៧ មករា ១៩៧៩ ។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាអ្នកកាន់អំណាចនៅក្នុងរដ្ឋាភិបាលបន្ទាប់ពីព្រឹត្តិការណ៍ឆ្នាំ១៩៩៧ បានមានប្រតិកម្មភ្លាមៗប្រឆាំងទៅនឹងការរកឃើញរបស់ក្រុមនេះ ហើយបានអះអាងថា ការកាត់ទោសខ្មែរក្រហមនឹងប្រឈមមុខនឹងគ្រោះថ្នាក់នៃការនាំប្រទេសទៅកាន់សង្គ្រាមស៊ីវិលឡើងវិញ ។ ក្នុងសំបុត្រមួយច្បាប់ផ្ញើទៅជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិនៅខែមីនា ឆ្នាំ១៩៩៩ សម្តេចបានព្រមានថា "ប្រសិនបើរៀបចំមិនបានល្អ ការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងធ្វើឲ្យមានការភិតភ័យដល់សមាជិកខ្មែរក្រហមដទៃទៀតដែលចុះចូលរួចហើយ ហើយអ្នកទាំងនោះនឹងវិលត្រឡប់ចូលព្រៃវិញ ហើយនឹងបង្កសង្គ្រាមទ័ពព្រៃនៅកម្ពុជាថ្មីម្តងទៀត ។

សភាពការណ៍វិវត្តធំៗពីរបាននាំដល់ការផ្លាស់ប្តូរគោលជំហរនេះ ។ ព្រឹត្តិការណ៍ទីមួយកើតឡើងនៅខែធ្នូ ឆ្នាំ១៩៩៨ គឺនៅពេលមេដឹកនាំខ្មែរក្រហមពីររូប ខៀវ សំផន និង នួន ជា បានប្រកាសផ្តាច់ខ្លួនចេញពីបក្សកុម្មុយនិស្តកម្ពុជា ។ សម្តេច ហ៊ុន សែន បានបកស្រាយថា ការចាកចេញទាំងនេះគឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការផ្សះផ្សាចំពោះឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ដោយបញ្ជាក់ថា "កម្ពុជាគួរតែជីកកប់អតីតកាលនិងសម្លឹងមើលទៅអនាគត" ។ ព្រឹត្តិការណ៍ទីពីរកើតឡើងនៅខែមីនា ឆ្នាំ១៩៩៩ នៅពេលមេដឹកនាំខ្មែរក្រហមមួយរូបទៀត តាម៉ុក ត្រូវបានចាប់ខ្លួននៅក្បែរព្រំដែនកម្ពុជា-ថៃ និងបញ្ជូនខ្លួនមកភ្នំពេញ ។

## ការបំបែកភាពទ័លច្រក

ជាមួយនឹងការចុះចូលរបស់ ខៀវ សំផន និង នួន ជា និងការចាប់ខ្លួន តាម៉ុក ដែលត្រូវបានស្គាល់ថា"មេពេជ្ឈឃាត" សម្តេច ហ៊ុន សែន ហាក់យល់ឃើញថា ខ្មែរក្រហមលែងជាការគំរាមកំហែងធំដុំដល់សន្តិសុខរបស់កម្ពុជាទៀតហើយ ។ ក្រុមអ្នករិះគន់សម្តេច ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជា បាននិយាយប្រឆាំងថា សម្រាប់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ការចរចាពីសាលាក្តី គ្រាន់តែជាមធ្យោបាយក្នុងការកម្ទេចចោលថ្នាក់ដឹកនាំខ្មែរក្រហមដែលសេសសល់និងដើម្បីបង្ហាញពីសមត្ថភាពនយោបាយរបស់ខ្លួនក្នុងនាមជាមេដឹកនាំកម្ពុជាម្នាក់ដែលអាចលុបបំបាត់

អតីតរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រុមអ្នករិះគន់បានបន្តទៀតថា នៅពេលសម្រេចបានគោលដៅទាំងនោះ សម្តេច ហ៊ុន សែន នឹងលែងចាប់អារម្មណ៍ពីការចរចាជាមួយអង្គការសហប្រជាជាតិទៀតហើយ ។

ភាពតានតឹងនៅក្នុងរាជរដ្ឋាភិបាលកម្ពុជាកាន់តែមានសភាពខ្លាំងឡើងប៉ុន្មានខែបន្ទាប់ពីការចាប់ខ្លួន តាម៉ុក ។ សម្តេច ហ៊ុន សែន បានអំពាវនាវឲ្យបញ្ឈប់រាល់ការពិភាក្សាទាក់ទងនឹងការបង្កើតតុលាការអន្តរជាតិ ដោយអះអាងថា ការកាត់ទោស តាម៉ុក នឹងធ្វើឡើងនៅក្នុងតុលាការកម្ពុជា ។ រាល់អ្នកជំនាញការច្បាប់ពីខាងក្រៅនឹងត្រូវបានអញ្ជើញឲ្យមកចូលរួមស្តាប់ការកាត់ក្តី ប៉ុន្តែអ្នកទាំងនេះគ្រាន់តែមានតួនាទីជាអ្នកសង្កេតការណ៍ប៉ុណ្ណោះ ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានសង្កត់ធ្ងន់ដែរថា ការធ្វើអន្តរាគមន៍របស់អន្តរជាតិទៅក្នុងកិច្ចការផ្ទៃក្នុង គឺជាការរំលោភទៅលើអធិបតេយ្យភាពជាតិរបស់កម្ពុជា ។ ទោះជាយ៉ាងនេះក្តី បញ្ហាស្តីពីការកាត់ទោសដោយប្រព័ន្ធច្បាប់តុលាការកម្ពុជាដូចដែលបានកត់សម្គាល់នៅក្នុងរបាយការណ៍របស់ក្រុមអ្នកជំនាញការច្បាប់របស់អង្គការសហប្រជាជាតិគឺមានការខ្វះចន្លោះជាច្រើន ។ អ្នកអង្កេតការណ៍អន្តរជាតិភាគច្រើនបាននិយាយថា តុលាការកម្ពុជាមិនអាចធ្វើការកាត់ទោស តាម៉ុក តាមស្តង់ដាយុត្តិធម៌ពិភពលោកបានទេ ប្រសិនបើគ្មានជំនួយពីសហគមន៍អន្តរជាតិ ។

ភាពទាល់ច្រករវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាត្រូវបានបំបែកនៅសម័យប្រជុំរបស់ស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅឆ្នាំ១៩៩៩ ។ ដោយមានការគាំទ្រដ៏ធំធេងពីអន្តរជាតិ ស្នងការជាន់ខ្ពស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានអនុម័តសេចក្តីសម្រេចមួយ ដោយជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជាបន្តសហការជាមួយសហគមន៍អន្តរជាតិទាក់ទិននឹងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ រដ្ឋាភិបាលជាច្រើនបានគាំទ្រចំពោះការចូលរួមរបស់កម្ពុជាក្នុងដំណើរការដូវច្បាប់ដើម្បីធានាឲ្យបាននូវសន្តិសុខ បូរណភាព និងឯករាជ្យភាពរបស់តុលាការ ។

នៅក្នុងជំហានឆ្ពោះទៅការសម្របសម្រួលនេះ សម្តេច ហ៊ុន សែន បានផ្ញើសំបុត្រមួយច្បាប់ជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិដោយពន្យល់ថា ការកាត់ទោស តាម៉ុក និងមេដឹកនាំផ្សេងទៀតនឹងនៅតែធ្វើឡើងក្នុងប្រព័ន្ធតុលាការកម្ពុជា ប៉ុន្តែដំណើរការនេះមិនអាចគេចផុតពីការផ្លាស់ប្តូរ ។ ដើម្បីធានាឲ្យបានថា ការកាត់ទោសនឹងអនុលោមទៅតាមច្បាប់អន្តរជាតិ អ្នកជំនាញការច្បាប់អន្តរជាតិត្រូវបានអញ្ជើញឲ្យចូលរួមយ៉ាងសកម្មក្នុងដំណើរការកាត់ក្តី ។ ជម្រើសរបស់តុលាការចម្រុះត្រូវបានលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំជាបន្តបន្ទាប់ រវាងសម្តេច ហ៊ុន សែន និងសមាជិកព្រឹទ្ធសភាអាមេរិក ចន ឃែរី នៅពេលគោលគំនិតមួយត្រូវបានលើកឡើងថា តុលាការនេះនឹងរួមមានទាំងចៅក្រមកម្ពុជានិងចៅក្រមអន្តរជាតិ ។ ដូច្នេះ នៅក្នុងវគ្គដំបូងនេះ ការចរចាផ្តោតទៅលើកិច្ចខិតខំប្រឹងប្រែងក្នុងការសម្របសម្រួលចំពោះការប្រកួតប្រជែងគ្នាដើម្បីផលប្រយោជន៍កម្ពុជានិងផលប្រយោជន៍អន្តរជាតិ ។

ការពិភាក្សាលម្អិតដទៃទៀតនឹងត្រូវលើកយកមកពិភាក្សានៅក្នុងការចរចាជាបន្តបន្ទាប់ទៀត ។ តើច្បាប់ដែលយកទៅប្រើគឺជាច្បាប់ជាតិឬច្បាប់អន្តរជាតិ? តើនីតិវិធីអ្វីខ្លះនឹងត្រូវយកមកអនុវត្ត ដើម្បីធានាឲ្យបាននូវស្តង់ដាយុត្តិធម៌អន្តរជាតិ ភាពមិនលម្អៀង និងដំណើរការដូវច្បាប់? តើការកាត់ទោសនេះនឹងត្រូវរៀបចំបែបណា ហើយទទួលបានថវិកាមកពីណា? ដើម្បីបកស្រាយប្រធានបទសំខាន់ៗទាំងនេះ ទាំងអង្គការសហប្រជាជាតិ ទាំងរាជរដ្ឋាភិបាលកម្ពុជាបានតែងតាំងអ្នកជំនាញការច្បាប់ក្នុងស្រុកនិងអន្តរជាតិដើម្បីសហការគ្នាធ្វើសេចក្តីព្រាងច្បាប់មួយ ។ ភាគីអង្គការសហប្រជាជាតិដឹកនាំដោយនាយកដ្ឋានច្បាប់នៃការិយាល័យកិច្ចការច្បាប់ ចំណែកសម្តេច ហ៊ុន សែន បានបង្កើតក្រុមការងាររាជរដ្ឋាភិបាលទទួលបន្ទុកសាលាក្តីខ្មែរក្រហម ដើម្បីដឹកនាំការចរចា ។ ការចរចារវាងក្រុមអ្នកជំនាញការទាំងនេះបានចាប់ផ្តើមនៅចុងខែសីហា ឆ្នាំ១៩៩៩ ។ ភាគីទាំងពីរបានធ្វើការពិភាក្សាគ្នារហូតដល់ចេញជាលទ្ធផលនៅខែតុលា ឆ្នាំ២០០៤ ដែលរដ្ឋសភាកម្ពុជាបានអនុម័តកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា និងវិសោធនកម្មទៅលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**(នៅមានត)**

**វ៉ៃលី ង៉ាយលី**

# តស៊ូដើម្បីជីវិតថ្មីលើទឹកដីចាស់

ខ្ញុំបាទឈ្មោះ លី សម្បត្តិ សូមសរសេរអំពីប្រវត្តិជីវិតពិតរបស់ឪពុកម្តាយខ្ញុំក្នុងរបបខ្មែរក្រហម ។ តាមការរៀបរាប់របស់អ្នកទាំងពីរ ធ្វើឲ្យខ្ញុំជាកូនមិនអាចបំភ្លេចបាននូវការឈឺចាប់ ការធ្វើបាបទាំងផ្លូវកាយនិងផ្លូវចិត្ត និងការតស៊ូពុះពារឧបសគ្គគ្រប់បែបយ៉ាង ដើម្បីរួចរស់ជីវិតពីរបបផ្តាច់ការដ៏សាហាវឃោរឃៅនេះឡើយ ។

ឪពុកខ្ញុំឈ្មោះ ងួន សាំងលី មានស្រុកកំណើតនៅភូមិទួលរកា ឃុំចាក់អង្រែក្រោម ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ គាត់ជាអតីតសិស្សថ្នាក់ទី៣ទំនើបនៃវិទ្យាល័យឯកជនមួយក្នុងទីក្រុងភ្នំពេញ ។ ចំណែកអ្នកម្តាយឈ្មោះ សោម ឡេង មានស្រុកកំណើត នៅឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល ។ ឪពុកខ្ញុំបានប្រាប់ថា នៅឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានវាយកម្ទេចទាហានកន្សែងរបស់សេនាប្រមុខ លន់ នល់ ។ ក្រោយមក ខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ និងបានបណ្តេញប្រជាជនទាំងអស់ឲ្យធ្វើដំណើរទៅតាមបណ្តាខេត្ត ដោយប្រាប់ថា ពួកអាមេរិកនឹងមកទម្លាក់គ្រាប់បែកនៅភ្នំពេញ ។ ខ្មែរក្រហមសន្យាថា ទៅតែបីថ្ងៃទេនឹងអាចត្រឡប់មករស់នៅដូចដើមវិញហើយ មិនចាំបាច់យកអ្វីទៅតាមខ្លួនច្រើនទេ ។ គ្រួសារខ្ញុំក៏បានរៀបចំអីវ៉ាន់ចេញទាំងភ័យស្លន់ស្លោ ។


ឪពុកម្តាយនិងបងប្រុសរបស់ លី សម្បត្តិ

ឪពុកខ្ញុំបន្តថា ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងគ្រួសារទៅតាមផ្លូវជាតិលេខ៧ គឺតាមផ្លូវតាខ្មៅចុះទៅស្អាង ព្រែកតូចក្នុងខេត្តកណ្តាល ។ នៅតាមផ្លូវមានឡានម៉ូតូកកស្ទះដើរមិនរួច ។ អ្នកខ្លះស្រែកយំរកកូនចៅដោយវង្វេងក្នុងហ្វូងមនុស្ស ។ ឪពុកខ្ញុំបានឃើញសាកសពជាច្រើននៅតាមផ្លូវ ។ គាត់មិនហ៊ាននិយាយអ្វីទេ ហើយបាននាំគ្រួសារដើររហូតដល់ស្រុកស្អាង ។ នៅពេលទៅដល់ខ្មែរក្រហមបានចែកគ្រួសារនីមួយៗទៅតាមភូមិ ។ របស់របរគ្រប់បែបយ៉ាងត្រូវអង្គការអាវខ្មៅ ស្នើយកមកដាក់ជារបស់រួម ។ ខ្មែរក្រហមបានចែកពោតយកមកបុកធ្វើជាម្ហូប ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានប្រកាសថា អង្គការនឹងនាំយកគ្រួសារមួយចំនួនទៅតំបន់មានហូបចុកគ្រប់គ្រាន់ ។ ក្រុមគ្រួសារឪពុកខ្ញុំក៏បានទៅចុះឈ្មោះជាមួយគ្រួសារឯទៀតដែរ ។ គ្រួសារដែលបានចុះឈ្មោះត្រូវបានដឹកតាមឡាន ហើយបន្តដំណើរតាមរថភ្លើងនៅមុំស្ថានីយ៍ប្រទះឡាងក្នុងខេត្តកណ្តាល ។ បន្ទាប់ពីរង់ចាំអស់រយៈពេលបីថ្ងៃ នៅពេលយប់រថភ្លើងបានមកដឹកប្រជាជនទៅដាក់នៅស្ថានីយ៍ត្រពាំងជង ។ បន្ទាប់មក ខ្មែរក្រហមបានយករទេះគោមកដឹកប្រជាជនបន្តទៀត និងចែកតាមភូមិផ្សេងៗ ។ ក្រុមគ្រួសារឪពុកខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅនៅភូមិបាក់ព្រីង ក្នុងខេត្តពោធិសាត់ ។ សម្រាកនៅទីនោះបានមួយយប់ ខ្មែរក្រហមបានឲ្យគ្រួសារឪពុកខ្ញុំទៅបោកស្រូវប្រូតស្រូវ និងបែនស្រូវតាំងពីព្រលឹមរហូតដល់យប់ម៉ោង

១១ ។ មួយថ្ងៃក្រោយមក កម្មាភិបាលខ្មែរក្រហមបានបញ្ជាឲ្យឪពុកខ្ញុំ ទៅច្រូតស្រូវនៅក្នុងទឹកត្រឹមដើមទ្រូង ។ ត្រឡប់មកពីធ្វើការវិញ ឪពុកខ្ញុំមានជំងឺគ្រុនញាក់ ។ គាត់បានទៅសុំច្បាប់សម្រាកមួយថ្ងៃ ប៉ុន្តែ ប្រធានកងមិនអនុញ្ញាត ហើយថែមទាំងព្រលយពាក្យថា "គ្រុនញាក់គ្រុនញ័រ គ្រុនគ្រាក់ទ័រ បានតែក្បាលមួយដងពូថៅទេបានឆាប់ជា" ។ ឪពុកខ្ញុំត្រូវបង្ខំចិត្តទៅធ្វើការទាំងឈឺ ។ ដៃជើងរបស់គាត់មានតែស្បែកដណ្ដប់ឆ្អឹង ។ ដោយសារហូបមិនគ្រប់គ្រាន់ និងគ្មានអនាម័យ ឪពុកខ្ញុំកើតជំងឺរាកមួល ។ ម្ដាយខ្ញុំបានដើរជីកឫសឈើដើម្បីធ្វើថ្នាំព្យាបាល ។

មួយរយៈក្រោយមក ប្រធានកងបានប្រកាសជ្រើសរើសអ្នកស្ម័គ្រចិត្តធ្វើកងជីលេខមួយ ។ ឪពុកខ្ញុំក៏ស្ម័គ្រចិត្តចូលធ្វើការក្នុងកងនោះ ។ ចំណែកម្ដាយខ្ញុំវិញត្រូវមេកងចាត់តាំងឲ្យដកសំណាបនិងស្ទូងស្រូវ ។ ដោយឃ្លានខ្លាំងពេក ឪពុកខ្ញុំបានបេះបោចស្លឹកឈើ ចាប់ពស់ ថ្កែន និងរើសចំណីហូបផ្ដេសផ្ដាសបណ្ដាលឲ្យកើតជំងឺហើមដៃហើមជើង ។ គាត់ក៏បានទៅលួចទឹកត្នោតយកមកហូបដើម្បីឲ្យដៃជើងរបស់គាត់បាត់ហើម ប៉ុន្តែត្រូវខ្មែរក្រហមតាមទាន់ចាប់ចងស្លាបសេក ហើយបណ្ដើរទៅកន្លែងធ្វើស្ករត្នោត ។ ឪពុកខ្ញុំត្រូវកងទ័ពខ្មែរក្រហមវាយបែកឈាមពេញខ្លួន ។ បន្ទាប់ពីអប់រំកសាងហើយ កងទ័ពទាំងនោះបានដោះលែងគាត់ឲ្យមកផ្ទះវិញ ។

ពេលចេញទៅធ្វើការម្ដងៗ ឪពុកខ្ញុំនិងអ្នកឯទៀតដើរសម្លឹងមើលកួរស្រូវនិងវត្ថុផ្សេងៗដើម្បីចំណាំទុក ។ យប់ឡើង គាត់ក៏បបួលគ្នាមកលួចបូតស្រូវនិងចាប់សត្វកង្កែប ជីងចក់ ថ្កែន យកមកហូបដើម្បីចម្អែតក្រពះ ។ ស្រូវដែលបានមកគាត់ មិនហ៊ានបុកធ្វើអង្ករទេ ព្រោះខ្លាចកងឈ្លបតាមទាន់យកទៅវៃចោល ។ គាត់បានយកស្រូវទៅលីងនៅក្នុងព្រៃ ហើយហូបទាំងសំបកតែម្ដង ។ មានម្ដងនោះកងឈ្លបតាមគាត់ទាន់ម្ដងទៀត ហើយចាប់គាត់ចងស្លាបសេកបណ្ដើរទៅកន្លែងឈ្លបភូមិ ។ សំណាងល្អ មេឈ្លបនោះចិត្តធម៌ គ្រាន់តែណែនាំបន្តិចបន្តួច ហើយក៏អនុញ្ញាតឲ្យមកផ្ទះវិញ ។ ឪពុកខ្ញុំនិយាយថា គាត់ដូចមានជីវិតថ្មីម្ដងទៀតអ៊ីចឹង ។

ក្រោយមកទៀត ក្រុមគ្រួសារឪពុកខ្ញុំត្រូវបានផ្លាស់ឲ្យទៅរស់នៅភូមិទួលខ្មែរ ជិតព្រៃនាមបឹងទន្លេសាប ។ ខ្មែរក្រហមបានចែកការងារឲ្យគាត់ធ្វើដូចជា លើកភ្លឺស្រែ ភ្ជួររាស់ និងដាំបន្លែ ។ មេកង បានប្រកាសរកអ្នកស្ម័គ្រចិត្តចូលធ្វើកងជីលេខមួយ ប៉ុន្តែគ្មានអ្នកណាចង់ធ្វើទេ មានតែឪពុកខ្ញុំនិងមិត្ត ណាន (ពីមុនធ្វើការនៅធនាគារជាតិ)ប៉ុណ្ណោះ ដែលស្ម័គ្រចិត្ត ។ ពូណាន បានសួរឪពុកខ្ញុំថា "មិត្ត លី ស្គាល់លុយដុល្លារទេ" ហើយគាត់ក៏ដកលុយមកបង្ហាញ ។ ពេលនោះ កងឈ្លបមើលឃើញហើយចាប់គាត់ទៅណែនាំ ។ តាំងពីថ្ងៃនោះមក ឪពុកខ្ញុំលែងឃើញមុខគាត់រហូត ។

ថ្ងៃមួយ ឪពុកខ្ញុំត្រូវបានកងឈ្លបចាប់ចងស្លាបសេកបណ្ដើរយកទៅសម្លាប់ ដោយចោទថាគាត់ជាទាហានពាក់ស័ក្តិមួយ ។ សំណាងល្អ ប្រធានកងឈ្មោះ ស៊ឹម មកធានាថាឪពុកខ្ញុំជាកម្មករធម្មតាទេ ។ មេកង ស៊ឹម បានយកឪពុកម្ដាយខ្ញុំទៅនៅជាមួយ ។ ពេលយប់ មេកង ស៊ឹម មិនឲ្យឪពុកម្ដាយខ្ញុំចេញពីផ្ទះទេ ព្រោះរៀងរាល់យប់ឈ្លបតែងដើរចាប់អ្នកភូមិយកទៅវាយចោល ។

ក្រោយមក ខ្មែរក្រហមបានបំបែកឪពុកម្ដាយខ្ញុំពីមេកង ស៊ឹម ដោយប្រាប់ថាឲ្យទៅរកត្រីនៅព្រៃនាមជ្រៅៗ ។ មេកង ស៊ឹម ក៏បានសុំទៅជាមួយដែរ ។ មួយខែក្រោយមក មេកង ស៊ឹម បានស្ដាប់វិទ្យុផ្សាយថា កងទ័ពវៀតណាមវាយបែកភ្នំពេញហើយ ហើយថាខ្មែរក្រហមបានបាក់ទ័ពរត់មកខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបងច្រើនណាស់ ។ ព្រឹកព្រលឹមនេះភ្លាម មេកង ស៊ឹម បានប្រាប់ឲ្យឪពុកម្ដាយខ្ញុំរត់ ចំណែក គាត់ត្រូវត្រឡប់ក្រោយវិញដើម្បីទៅយកម្ដាយ ។ ឪពុកម្ដាយខ្ញុំបានបបួលអ្នករកត្រីទាំងអស់ជិះទូកទាំងយប់ទៅខេត្តសៀមរាប ។ ប៉ុន្តែដោយសារតែយប់ងងឹតនិងមានភ្លៀងធ្លាក់ខ្លាំងផង អ្នកទាំងអស់គ្នាបានវង្វេងទិស ។ ពេលភ្លឺឡើងបានដឹងថាខ្លួននៅកណ្ដាលបឹងទន្លេសាប ។ ពេលនោះ ម្ដាយខ្ញុំមានជំងឺគ្រុនញាក់ ។ ពេលទូកទៅដល់ក្បែរច្រាំង កាណូតធំបានមកសណ្ដោងទូកតូចៗចូលច្រាំងនៅភូមិព្រែកកំពង់ឃ្លាំង ឃុំដីដែក ខេត្តសៀមរាប ។ នៅទីនោះ អង្គការរណសិរ្សបានចែកអង្ករសាលីឲ្យដាំហូប ហើយបានអំពាវនាវឲ្យប្រជាជនត្រឡប់ទៅភូមិកំណើតវិញ ។ ឪពុកម្ដាយខ្ញុំនិងក្រុមគ្រួសារបាននាំគ្នាធ្វើដំណើរមកស្រុកកំណើតវិញ ។

ការតស៊ូដើម្បីរស់នៅលើទឹកដីចាស់មានពន្លឺជាថ្មីម្តងទៀត ។ ឪពុកខ្ញុំសោកស្តាយយ៉ាងខ្លាំង ព្រោះគាត់មិនបានជួបមេកង ស៊ឹម និងម្តាយរបស់គាត់ដែលជាអ្នកមានគុណដ៏លើសលប់ ។ ឪពុកម្តាយខ្ញុំសង្ឃឹមយ៉ាងមុតមាំថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងកាត់សេចក្តីដោយយុត្តិធម៌និងត្រឹមត្រូវដើម្បីឲ្យប្រជាជនទាំងអស់បានស្ងប់ចិត្ត ។ ខ្ញុំនិងប្រជាជនទាំងអស់នឹងរង់ចាំមើលថាតើតុលាការនឹងធ្វើការកាត់ទោសដោយរបៀបណា?

**លី សម្បត្តិ**

*លិខិតពីមិត្តអ្នកអាន*

# ពឹង ហៀចាង

ខ្ញុំចាប់អារម្មណ៍ចំពោះអត្ថបទស្តីពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលបានចុះផ្សាយនៅក្នុងទស្សនាវដ្តីស្វែងរកការពិត ។ នៅក្នុងទស្សនាវដ្តីនេះក៏មានចុះផ្សាយអត្ថបទចម្លើយសារភាពនិងរឿងរ៉ាវរបស់ជនរងគ្រោះពីរបបខ្មែរក្រហមដែរ ។ នៅក្នុងនោះខ្ញុំចូលចិត្តអានរឿងរ៉ាវជីវិតរបស់ជនរងគ្រោះជាងគេ ។ ក្រៅពីនេះខ្ញុំឃើញរូបថតជនរងគ្រោះពីសម័យខ្មែរក្រហមដែលមានភិនភាគពណ៌សម្បុរជាជនជាតិចិន វៀតណាម និងជនជាតិភាគតិច ដូចជា ចាម ស្ទៀង ជាដើម ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះទស្សនាវដ្តីស្វែងរកការពិត ហើយសូមសំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តផ្ញើទស្សនាវដ្តីលេខក្រោយៗទៀតមកឲ្យខ្ញុំតាមរយៈប្រៃសណីយ៍ ។ តាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំក៏បានស្គាល់សៀវភៅ “ក្មេងមានសំណាង” ជាស្នាដៃរបស់ លឿង អ៊ុង ។

តាម៉ុក “អ្នកសម្លាប់” ជាកូនកសិករក្រីក្រ ។ ក្នុងវ័យ១០ឆ្នាំ តាម៉ុកបួសជាព្រះសង្ឃ ។ បន្ទាប់មក តាម៉ុក បានចូលជាសមាជិកបក្សកុម្មុយនិស្ត ។ នៅឆ្នាំ១៩៩៩ តាម៉ុក ត្រូវបានចាប់ខ្លួននៅព្រំដែនថៃនិងជាប់ឃុំឃាំង ។ តាម៉ុក ប្រាប់មេធាវីរបស់គាត់ថា ÷ “ខ្ញុំមិនដែលសម្លាប់មនុស្សម្នាក់ឡើយ សូម្បីតែចេតនាគិតក៏គ្មានផង” ។ ក្រោយពីសម្រាកនៅមន្ទីរពេទ្យដោយជំងឺលើសឈាម និងជំងឺរបេង តាម៉ុក ស្លាប់ពីសប្តាហ៍មុននេះក្នុងវ័យ៨០ឆ្នាំ ។ ទោះបីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនបានបាត់បង់ជីវិតជាបន្តបន្ទាប់ ខ្ញុំគិតថា លោកស្រី មីសែល លី និង ឯកឧត្តម ស៊ាន វិសុទ្ធ កំពុងតែធ្វើការងារមួយដែលមានប្រយោជន៍សម្រាប់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

បន្តមកទៀតនេះខ្ញុំសូមរៀបរាប់ពីជីវិតខ្ញុំក្នុងរបបខ្មែរក្រហម ។ ខ្ញុំបានរត់ទៅជំរំជនភៀសខ្លួនខាវអ៊ីដាង ម៉ៃ រ៉ាត់ ខេត្តឈុនបុរី ប្រទេសថៃ ។ ម៉ៃរ៉ាត់ មានមាត់សមុទ្រដ៏ស្រស់ស្អាត ។ ថ្ងៃមួយម្ចាស់ក្សត្រីនៃប្រទេសថៃ ហែហមដោយទាហានជាច្រើនបានមកលេងម៉ៃរ៉ាត់ ។ នៅថ្ងៃនោះ ម្ចាស់ក្សត្រីថៃបានឈប់និយាយជាមួយក្មេងប្រុសម្នាក់គឺខ្ញុំ ។ ក្រោយមកមានការថតរូប ។ ក្នុងនោះមានជាប់រូបខ្ញុំមួយចំហៀងខ្លួនផងដែរ ។ ជារៀងរាល់ថ្ងៃនៅជំរំខាវអ៊ីដាង មានបញ្ចាំងខ្សែភាពយន្តចិននៅក្នុងអគារមួយខ្នង ។ នៅជុំវិញអគារនោះមានហាងជាច្រើន ។ ក្នុងចំណោមហាងទាំងនោះ ម្តាយខ្ញុំមានកន្ត្រែងលក់ទឹកកកមួយ ។ នៅខាងឆ្វេងដៃមានហាងគុយទាវចិន ឯនៅខាងឆ្វេងមានហាងគុយទាវគោក ។

គ្រួសារខ្ញុំរស់នៅក្នុងជំរំអស់រយៈពេលយ៉ាងយូរទម្រាំយើងទៅដល់សហរដ្ឋអាមេរិក ។ នៅជំរំជនភៀសខ្លួន មានផ្ទះជាច្រើនទើបនឹងសង់ថ្មីសម្រាប់ជនភៀសខ្លួនថ្មី ។ ជំរំ២០០០មានសុទ្ធតែអតីតខ្មែរក្រហមរស់នៅ រីឯនៅជំរំ២០០១ មានសុទ្ធតែជនជាតិខ្មែរកាត់ចិននិងចិនទាំងពីរ ។ ពេលខ្ញុំនៅជំរំ ជួនកាលខ្ញុំទៅលេងមាត់សមុទ្រ ។ មានម្តងនោះបងថ្លៃខ្ញុំនាំខ្ញុំទៅមើលកុន “Enter the Dragon” របស់ ប្រូស លី ។ ខ្ញុំទៅហូបបបរនៅហាងចិននៅក្បែរនោះបានពីរដងដែរ ។ ខ្ញុំនៅចាំថា បបរនោះឆ្ងាញ់ណាស់ ក្នុងបបរមានខ្ទឹមបារាំង ម្រេច សាច់ជ្រូកចំណិត ឈាមជ្រូក និងនំប៉័ងបំពង ។ នៅជំរំ គ្រូបង្រៀនខ្ញុំសុទ្ធតែជាខ្មែរកាត់ចិន ។ នេះជារឿងធម្មតាពីព្រោះនៅម៉ៃរ៉ាត់ ប្រជាជនស្ទើរតែទាំងអស់ ជាកូនកាត់ចិនមានតែមួយភាគតូចប៉ុណ្ណោះជាជនជាតិខ្មែរ ។

ការរស់នៅជំរំរបស់ក្រុមគ្រួសារសាច់ញាតិខ្ញុំបានទទួលការឧបត្ថម្ភពីគ្រួសារ ថមសាន់ ។ ថ្ងៃមួយស្រាប់តែមានសេចក្តីប្រកាសថា ប្រជាជនជម្លៀស៥០គ្រួសារនឹងត្រូវបញ្ជូនទៅរស់នៅកន្លែងផ្សេង ។ នៅក្នុងបញ្ជីនោះក៏មានឈ្មោះឪពុកខ្ញុំដែរ ។ ខ្ញុំសប្បាយ

ចិត្តដែលគ្រួសារខ្ញុំបានទៅរស់នៅកន្លែងថ្មីប្រសើរជាងនេះ ។

ខ្ញុំធ្លាប់មើលភាពយន្តឯកសារខ្មែរក្រហម ។ ភាពយន្តនោះជួយឲ្យ ខ្ញុំចងចាំពីអតីតកាល ។ ខ្ញុំចាំបាន ថ្ងៃដែលខ្មែរក្រហមមានកាន់គ្រាប់បែកនៅនឹងដៃ ។ ខ្ញុំចាំថាមានខ្មែរក្រហមពីរនាក់ជិះកង់ស្រែកបញ្ជាខ្ញុំថា "ទៅធ្វើការ ឆាប់ទៅធ្វើការភ្លាម" ។ កាលណោះខ្ញុំអាយុទើបតែបាន៥ឆ្នាំប៉ុណ្ណោះ ។ ពេលខ្ញុំកំពុងអង្គុយលេងនៅមុខផ្ទះ ស្រាប់តែនារីខ្មែរក្រហមពីរនាក់ជិះកង់តម្រង់មកខ្ញុំ ហើយប្រាប់ខ្ញុំម្តងហើយម្តងទៀតថាឲ្យទៅធ្វើការ ។ ថ្ងៃមួយពេលខ្ញុំកំពុងនៅរោងបាយ ស្រាប់តែនារីខ្មែរក្រហមពីរនាក់នោះជិះកង់តម្រង់មកខ្ញុំ ។ គ្រាន់តែឃើញនារីខ្មែរក្រហមនោះភ្លាម បេះដូងខ្ញុំលោតកាន់តែខ្លាំង ខ្ញុំគិតថា ឱ!ម្ចាស់ថ្លៃអើយ ជីវិតខ្ញុំចប់ក្នុងថ្ងៃនេះហើយ ។ ក្រោយមកទាហានវៀតណាមចូលមកដេញខ្មែរក្រហមចូលព្រៃអស់ ។

សូមអរគុណដល់ ទស្សនាវដ្តីស្វែងរកការពិត ។ ខ្ញុំនឹងសរសេរសំបុត្រមកជាបន្តទៀត ។

**ពីន ហៃចាន**

*(អត្ថបទលិខិតពីមិត្តអ្នកស្តាប់វិទ្យុខេត្តកំពត)*

# កូនប្រុសប្រាំនាក់ស្លាប់ក្នុងរបបខ្មែរក្រហម

អត្ថបទនេះនាងខ្ញុំបានសរសេរពីជីវិតពិតរបស់លោកយាយ គល់ ហេង ដែលសព្វថ្ងៃរស់នៅ ជាមួយកូនប្រុសពៅឈ្មោះ ចាប គាន ក្នុងភូមិអន្លង់គគីរ ឃុំកណ្តាល ស្រុកកំពត ខេត្តកំពត ។

យាយបានតំណាលប្រាប់ខ្ញុំថា យាយមានកូនប្រុសទាំងអស់ប្រាំមួយនាក់ ។ នៅក្នុងសម័យសង្គមរាស្ត្រនិយមគាត់រស់នៅក្នុងភូមិជុំគ្រៀល ឃុំក្បាលរមាស ហើយផ្ទះរបស់គាត់ស្ថិតនៅខាងកើតវត្តជុំគ្រៀល ។ បន្ទាប់ពីខ្មែរក្រហមចូលលុកលុយប្រទេសកម្ពុជា កាន់កាប់ទឹកដីនិងក្តោបក្តាប់អំណាចទូទាំងប្រទេសមកនោះ គាត់ត្រូវព្រាត់ប្រាសកូនអស់នៅតែកូនប្រុសពៅម្នាក់ប៉ុណ្ណោះ ។

មេដឹកនាំខ្មែរក្រហម បានផ្លាស់គាត់ពីភូមិមួយទៅភូមិមួយដូចប្រជាជនដទៃទៀតដែរ ។ ក្នុងរបបខ្មែរក្រហមអស់រយៈពេលជាង៣ឆ្នាំ យាយត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើការផតឈប់ឈរ និងត្រូវបានពង្រាត់ពីកូនចៅទៀត ។ យាយពោលទាំងទឹកភ្នែកថា នៅថ្ងៃមួយពេលគាត់កំពុងស្ទូង ស្រាប់តែឃើញឈ្លបបណ្តើរកូនប្រុសរបស់គាត់ ចងដៃនឹងខ្សែអង្រឹង វាយបណ្តើរប្រាបឲ្យដើរលឿនបណ្តើរ ដោយពួកវាបានស្រែកខ្លាំងៗថា "មិត្តឯងខ្ជិល មិត្តឯងក្បត់នឹងអង្គការមហាលោតផ្លោះរបស់យើង ។ ដូច្នេះអង្គការយកមិត្តឯងទៅកសាង" ។ ការពិតកូនរបស់យាយមានជំងឺគ្រុនចាញ់ដូច្នេះបានជាទៅបម្រើការងារឲ្យអង្គការមហាលោតផ្លោះមិនបាន ។

យាយបន្តនូវពាក្យពេចន៍ដ៏សែនឈឺចាប់និងអួលណែនដើមក ថា គាត់រន្ធត់ស្ទើរស្លុតស្មារតី ព្រោះគាត់មានកូនប្រុស៦នាក់ត្រូវខ្មែរក្រហមត្របាក់យកអស់៥នាក់ ។ ពួកវាត្របាក់កូនគាត់ដូចស៊ីសាច់គោសាច់ក្របី ។ លោកយាយព្រាត់ប្រាសកូនបង្កើតកូនប្រសា និងចៅប្រុសស្រីដោយគ្មានអ្វីជាទីសង្ឃឹមទៀតឡើយ ។ កូនប្រុសទី៥របស់យាយត្រូវពួកខ្មែរក្រហមមួយក្រុមយកទៅដោយប្រាប់ថា ទៅបម្រើអង្គការធ្វើជាកម្លាំងស្រួចនិងជនគំរូ ។ ចាប់ពីពេលនោះមក កូនប្រុសទី៥របស់យាយបានបាត់ដំណឹងរហូត ។ យាយបន្តថា គាត់ពុំហ៊ានតវ៉ាអ្វីទេ ព្រោះខ្លាចគេយកកូនពៅនិងរូបគាត់ទៅទៀត ។ កូនប្រុសច្បងរបស់យាយគឺជាប៉ារបស់នាងខ្ញុំក៏ត្រូវបែកគ្នាពីគាត់ដែរ ។ ស្ថិតនៅក្នុងរបបខ្មែរក្រហម យាយចេះតែស៊ើបរកដំណឹងកូនទាំងអស់ ប៉ុន្តែគ្មានដំណឹងសោះ នៅពេលយប់យាយតែងតែអង្គុយយំព្រោះនឹកកូននិងចៅ ហើយយាយតែងតែលើកដៃសំពះបួងសួងទេវតាឲ្យជួយប្រាប់ថាកូនគាត់នៅទីណា និងសូមឲ្យរបបផ្តាច់ការខ្មែរក្រហមឆាប់រលាយរលត់ ទើបប្រជារាស្ត្រយើងទូទាំងប្រទេសបានសេចក្តីសុខរុងរឿងឡើងវិញ ។ យាយមានបន្ទុកយ៉ាងធ្ងន់នៅរបបខ្មែរក្រហម ម្តាយរបស់យាយមានអាយុ៨០ឆ្នាំ ត្រូវមេកងនារីធ្វើបាបនិងបង្អត់បាយ ដោយនិយាយថា ចាស់ហើយមិនឲ្យស៊ីទេ ខាតកម្លាំងពលកម្មអង្គការ ។ យាយចេះតែលួចយករបបរបស់យាយឲ្យម្តាយហូប

ពេលអន្ធការងងឹតអន្ធការតែងតែបន្លស់បែបគាត់ម្តងម្កាល ។

ក្រោយពេលកងទ័ពរណសិរ្សជាតិកម្ពុជាបានរំដោះប្រជាជន និងប្រទេសជាតិបានសុខសាន្តហើយ យាយខំស្វះស្វែងរកកូនចៅ ហើយបានជួបតែកូនប្រុសពៅប៉ុណ្ណោះ ។ ជាច្រើនថ្ងៃខែកន្លងផុត ទៅយាយបានវិលមកនៅភូមិជុំគ្រៀលក្នុងគោលបំណងមករក កូនប្រុសច្បង ប៉ុន្តែពេលមកដល់យាយបានជួបតែកូនប្រសា និងចៅស្រី២នាក់ប៉ុណ្ណោះ ។ ម្តាយក្មេកនិងកូនប្រសាបានឱបគ្នា ដោយទឹកភ្នែក ។ បន្ទាប់មកទៀត យាយបានជួបកូនប្រសាទី២ រីឯកូនទី៣និងកូនប្រសាត្រូវបាត់ដំណឹងឈឹង ។ អ្នកភូមិរស់នៅ ជាមួយប្រាប់ថា កូនទី៣គេ(ខ្មែរក្រហម)យកទៅសម្លាប់អស់ ហើយ ។ ក្នុងនាមជាម្តាយ យាយនៅតែប្រឹងប្រែងស៊ើបសួររក កូន និងចៅដែលនៅសេសសល់ពីចង្កូមមច្ចុរាជ ។ ថ្ងៃមួយកូនប្រុស ទី៥របស់យាយបានផ្ញើសំបុត្រមកពីភ្នំពេញ យាយត្រេកអរ ណាស់ក៏ឡើងទៅជួបជុំកូននៅភ្នំពេញ ហើយនាំកូនមកធ្វើបុណ្យ នៅស្រុកកំណើត ។ ក៏ប៉ុន្តែនៅក្នុងអំឡុងឆ្នាំ១៩៨៤ កូនទី៥ របស់យាយក៏ត្រូវខ្មែរក្រហមស្ទាក់បាញ់ប្រហារនៅកណ្តាលផ្លូវ ជាតិលេខ៤ស្ថិតនៅទឹកដីកំពង់ស្ពឺ ក្នុងខណៈពេលបើករថយន្តដឹក ក្រណាត់របស់ក្រសួងពាណិជ្ជកម្មពីក្រុងព្រះសីហនុមកភ្នំពេញ ។ យាយពោលថា "កូនខ្ញុំបានរួចពីក្រញាំបិសាចហើយ តែយមរាជ នៅតែតាមយកជីវិតកូនរបស់ខ្ញុំទៀត" ទុកឲ្យគាត់រស់នៅតែពីរ នាក់ម្តាយ និងកូនដូចលលកញីឈ្មោល ។

យាយត្រេកអរណាស់នៅពេលឮដំណឹងថាមានការកាត់ទោស ខ្មែរក្រហម គាត់មានចំណាប់អារម្មណ៍យ៉ាងខ្លាំង គាត់ថាដាច់ខាត ត្រូវតែកាត់ទោសខ្មែរក្រហម ។ នេះជាសច្ចៈធម៌ យុត្តិធម៌ ចំពោះ ប្រជាជនទូទាំងប្រទេសកម្ពុជារបស់យើង ។

នាងខ្ញុំសូមថ្លែងអំណរគុណដ៏ធំធេងដល់មជ្ឈមណ្ឌលឯកសារ កម្ពុជាដើម្បីស្វែងរកការពិត ហើយបើមានការខុសឆ្គងមេត្តា អធ្យាស្រ័យដល់នាងខ្ញុំ ។

**ភូមិជុំគ្រៀល ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦**

**ចាប ចិន្តាភក្តី**

# សេចក្តីប្រកាសរកកូនប្រាំនាក់



អ៊ុក ម៉ានិល
កូនពៅរបស់ ឃួន អន

នាងឈ្មោះ ឃួន អន ត្រូវជាម្តាយសព្វថ្ងៃរស់នៅក្នុងភូមិរទាំង ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល សូមសួររកកូនទាំង៥នាក់ ៖

១) កូនស្រីច្បងឈ្មោះ អ៊ុក អាន់ និងស្វាមីឈ្មោះ ឃួន សេង (កូនប្រសាធ្វើទាហានខាងគណនីករ) និងចៅប្រុសម្នាក់ (មិនចាំឈ្មោះ) ។

២) កូនប្រុសទី២ឈ្មោះ អ៊ុក ដាន (នៅលីវ) ធ្វើទាហានពាក់ស័ក្តិ២ ។

៣) កូនប្រុសទី៣ឈ្មោះ អ៊ុក ភី (នៅលីវ) ធ្វើទាហានពាក់ស័ក្តិ១ ។

៤) កូនប្រុសទី៤ឈ្មោះ អ៊ុក ផេង ធ្វើទាហាននិងប្រពន្ធឈ្មោះ មុំ ព្រមទាំងកូនស្រី ។ គ្រួសារទាំងអស់នេះបានរស់នៅ កំពង់សោមឆ្នាំ១៩៧០ក្នុងសម័យលន់នល់ បន្ទាប់ពីឆ្នាំ១៩៧៥គ្រួសារទាំងនេះបានបាត់ខ្លួនរហូតមក ។

៥) បច្ចុប្បន្ននៅសល់កូនប្រុសពៅម្នាក់ឈ្មោះ អ៊ុក ម៉ានិល និងភរិយាឈ្មោះ ប៉ាត សាវី ព្រមទាំងកូនស្រីឈ្មោះ អ៊ុក សូលក្ខិណា និងចៅស្រីឈ្មោះ សេង ទូច (កូនស្រីរបស់ អ៊ុក អ៊ាន់ ដែលបានបែកចេញពីឪពុកម្តាយ សព្វថ្ងៃ រស់នៅជាមួយជីដូន) កំពុងរស់នៅភូមិរទាំង ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

ដូច្នេះបើកូនៗបានឃើញសេចក្តីប្រកាសនេះសូមមករកម្តាយ ឬញាតិមិត្តណាបានស្គាល់ឈ្មោះទាំងអស់នេះ សូមជួយផ្តល់ ដំណឹងតាមទូរស័ព្ទលេខ ០៩២ ២៩២ ៣២៤ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកប្អូនស្រីជីដូនមួយ

ខ្ញុំបាទឈ្មោះ សេក សារ៉ុន បងជីដូនមួយនៅភូមិព្រះទន្លេ ឃុំសំព័រ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។ ខ្ញុំបាទសូមសួរឈ្មោះ សេក សុភី និង សេក សាត់ ហៅ ប្រាក់ ដែលត្រូវជាកូនរបស់មីង ចាន់ គឹមស្រ៊ុន ហៅ សាន ដែលត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកទួលស្លែងនិងសម្លាប់ចោលនៅក្នុងឆ្នាំ១៩៧៨ ។

នៅក្នុងឆ្នាំ១៩៧៨ ខ្ញុំបាទ សេក សារ៉ុន និង សេក សុភី ត្រូវខ្មែរក្រហមចាប់ដាក់គុកនៅជ្រៃអូរញ្ញៅ ។ ក្រោយឆ្នាំ១៩៧៩ ប្អូនស្រីបានបែកពីបង ។

ដូចនេះបើប្អូនបានឃើញសេចក្តីប្រកាសនេះឬបងប្អូនណាបានស្គាល់ឈ្មោះនេះសូមទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ក្រុងភ្នំពេញ ឬតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ដំណឹងសួររកឪពុកឈ្មោះ អ៊ុម សំអុល

នាងខ្ញុំឈ្មោះ មន្ថា (ហៅក្រញាញ់ កើតឆ្នាំ១៩៦៨) និងប្អូនប្រុសឈ្មោះ សាមឿន (ហៅ វែម៉ុង កើតឆ្នាំ១៩៧០) សព្វថ្ងៃរស់នៅប្រទេសប៊ែលហ្សិក សូមសួររកឪពុកឈ្មោះ អ៊ុម សំអុល (នាមដើម អ៊ុក មួយ អាយុ៦៨ឆ្នាំ) មានស្រុកកំណើតនៅរការកោង ។ ឪពុករបស់នាងខ្ញុំជាជនភៀសខ្លួនម្នាក់ ហើយដែលត្រូវបានចេញទៅប្រទេសទី៣នៅក្នុងឆ្នាំ១៩៨០-៨១បន្ទាប់ពីគាត់បានធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះ ឃែរ (CARE) នៅមន្ទីរថ្មីងកុមារសង្កាត់ទី១៤នៃជំរំជនភៀសខ្លួនខាវអ៊ីដាងប្រទេសថៃ ម្តាយឈ្មោះ សុខា (ឈ្មោះថ្មី គឹម សុម៉ាលី) បានបែកចេញពីឪពុកខ្ញុំទៅធ្វើការនៅជំរំថ្មីជាប្រធានមន្ទីរវះកាត់ជនពិការនៅអង្គការមនុស្សធម៌អាល្លឺម៉ង់មួយ ។ កាលរស់នៅប្រទេសកម្ពុជា គាត់ទាំងពីររស់នៅខេត្តបាត់ដំបង ធ្វើការនៅរោងចក្រផ្នែកជួសជុលម៉ាស៊ីន ។

ប្រសិនបើអស់លោក លោកស្រី មាមីងពូ បានស្គាល់ឬជួបលោក អ៊ុម សំអុល រស់នៅប្រទេសណាសូមមេត្តាជួយផ្តល់ព័ត៌មានមកនាងខ្ញុំតាម អ៊ីម៉ែល ផ្ញើលិខិត ឬទូរស័ព្ទមកយើងខ្ញុំតាមអាសយដ្ឋានខាងក្រោមនេះ ។ សូមអរគុណ ។

*Mme Montha Kim,145Rue Neuve, B-1640 Rhode-st-Gene`se(Belgique)*

*Tel: 00 33 2 381 0527; email: kimanfrov@yahoo.fr or fb663380@skynet.be*


មន្ថា និងប្អូនប្រុស សាមឿន
នៅជំរុំខាវអ៊ីដាង


មន្ថា និងប្អូនប្រុស សាមឿន
នៅជំរុំខាវអ៊ីដាង


សុខា ម្តាយរបស់ មន្ថា
នៅជំរុំខាវអ៊ីដាង

# ចូលរួមឃ្លាំមើលដំណើរការកាត់ទោស
# មេដឹកនាំខ្មែរក្រហម

## ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា



ជនរងគ្រោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យមកធ្វើទស្សនកិច្ចនៅវាលពិឃាតបឹងជើងឯក



អគាររដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ



មេឃុំធ្វើទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា



មេឃុំក្នុងបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ



ជនរងគ្រោះក្នុងបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ

- ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ ចាប់ដំណើរការនៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៦។
- ដំណើរការទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ជារៀងរាល់ថ្ងៃអង្គារ៍ក្នុងសប្តាហ៍ទី៤នៃខែនីមួយៗ នៅក្នុងឆ្នាំ២០០៦។ មកទល់នឹងខែតុលានេះ មានប្រជជន៥០០០នាក់រួចមកហើយដែលបានចូលរួម។
- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាករកម្ពុជាមានទីតាំងនៅតាមផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ទំនាក់ទំនងជាមួយមន្ត្រីផ្នែកកិច្ចការសាធារណៈ ទូរស័ព្ទលេខ ០២៣ ២១៩ ៨១៤ ព័ត៌មានបន្ថែមសូមមើលគេហទំព័រ www.cambodia.gov.kh/krt ឬ www.eccc.gov.kh។
- មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ វិថីព្រះសីហនុ (ខាងកើតវិមានឯករាជ្យ) ប្រអប់សំបុត្រ១១១០ ទំនាក់ទំនងជាមួយលោក វ៉ាន់ថាន់ ពៅដារ៉ា ទូរស័ព្ទលេខ ០១២ ៨៤៦ ៥២៦ ព័ត៌មានបន្ថែម សូមមើលគេហទំព័រ www.dccam.org។

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.

A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 83, November 2006 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.